

នៅតែ

# កំពុងបាត់បង់ដីធ្លី

ការបណ្តេញចេញដោយបង្ខំ
និងការគំរាមកំហែងនៅកម្ពុជា

២០១០

គណៈកម្មាធិការប្រប្រិត្តិកម្មសិទ្ធិមនុស្សកម្ពុជា (CHRAC) គឺ ជាការរួបរួមគ្នានូវអង្គការមិនមែន រដ្ឋាភិបាល ជាសមាជិកចំនួន ២១។ គណៈកម្មាធិការនេះបានត្រូវបង្កើតកាលពីឆ្នាំ ១៩៩៤ នៅទីក្រុងភ្នំពេញ ដោយក្រុម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និង សមាគមនានា ដែលធ្វើការដើម្បីលើកកំពស់ និង គោរពនូវ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និង នីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។

ក្រុមការងារសិទ្ធិលំនៅដ្ឋាន (HRFT) គឺជាការរួបរួមគ្នានូវអង្គការជាសមាជិកចំនួន ១៣។ ក្រុមការងារនេះត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០០៣ដោយក្រុមអង្គការមិនមែនរដ្ឋាភិ–បាលជាតិ និង អន្តរជាតិ ព្រមទាំង សមាគមនានា ដែលធ្វើការដើម្បីបង្ការនូវការជន្លៀសដោយបង្ខំ និង លើកកំពស់នូវសិទ្ធ លំនៅដ្ឋាន នៅក្នុង ប្រទេសកម្ពុជា។

*ទំនាក់ទំនង : chrac@online.com.kh*

២០១០

*រូបភាព*

*ក្របមុខ : កងយោធពលខេមរៈភូមិន្ទ ការពារគ្រឿងចក្រប៊ុលឌូសើ របស់ក្រុមហ៊ុន ស៊ូហ្គីភ្នំពេញ ខណៈពេលដែល ប្រជាជននៅឃុំអមលាំង ក្នុងខេត្តកំពង់ស្ពឺកំពង់ព្យាយាមបញ្ឈប់ការឈូសឆាយដី។*

*ក្របក្រោយ : កំណាត់ឈើអុស ត្រូវបានគេដាក់លក់នៅតាមផ្លូវទៅកាន់ ឃុំព្រៃពាយ ស្រុកឈូក ខេត្តកំពត បន្ទាប់ពីក្រុមហ៊ុនបានកាប់ឈើព្រៃចោលសំរាប់ការអភិវឌ្ឍន៍។*

# មាតិកា

អារម្ភកថា ........ ១

ទិដ្ឋភាពទូទៅ ........ ២

ស្ត្រីនៅខេត្តកំពតក្រោកឈរឡើងប្រយុទ្ធដើម្បីសមុទ្ររបស់ពួកគាត់ (កំពត) ........ ៥

អ្នកស្រុកប៉ូស្រាវីករាយក្នុងខណៈដែលកសិករទាំងឡាយប្រកបការងារដោយខ្លួនឯង មិនស៊ីឈ្នួលគេ (មណ្ឌលគីរី) ........ ៨

ទឹកជ្រោះបានប្រែក្លាយទៅជាជ្រោះទឹកភ្នែក (ពោធិសាត់) ........ ១១

លើកផ្លាកជិន្ទួសទីងមោងដើម្បីបង្អើលអ្នកដណ្តើមយកដីធ (កោះកុង) ........ ១៤

ក្នុងខណៈពេលដែលភ្លៀងចាប់ផ្តើមធ្លាក់ ទឹកភ្នែករបស់អ្នកភូមិ ក៏ចាប់ផ្តើមហូរដែរ (សៀមរាប) ........ ១៧

"ពួកយើងទាំងអស់គ្នានឹងស្លាប់ ប្រសិនបើពួកយើងពុំមានដីធ្លីទេនោះ" (បាត់ដំបង) ........ ២០

"ខ្ញុំគ្រាន់តែចង់បានឪពុកខ្ញុំ និងវាលស្រែខ្ញុំត្រឡប់មកវិញតែប៉ុណ្ណោះ" (កំពង់ឆ្នាំង) ........ ២២

ការបំបាត់ព្រៃពីបុរាណ និងការឆកយកនូវមធ្យោបាយចិញ្ចឹមជីវិតជាប្រពៃណី របស់អ្នកភូមិ (កំពង់ឆ្នាំង) ........ ២៥

អ្នកភូមិព្រៃពាយកំពុងបាត់បង់នូវក្តីសង្ឃឹម (កំពត) ........ ២៧

ការប្រយុទ្ធលើកចុងក្រោយរបស់អ្នកភូមិជ័យជំនះដើម្បីដីធ្លីរបស់ខ្លួន (ក្រចេះ) ........ ២៩

ភាពស្មៀមស្ងាត់ក្លែងក្លាយនៅខេត្តកំពង់ស្ពឺ (កំពង់ស្ពឺ) ........ ៣១

ឧបសម្ព័ន្ធ:

យន្តការផ្សេងៗក្នុងការដោះស្រាយជម្លោះ ........ ៣៣

បណ្តឹងសហគមន៍ ........ ៣៥

# អារម្ភកថា

គណៈកម្មធិការសកម្មភាពសិទ្ធិមនុស្សកម្ពុជា (CHRAC

អស់រយៈកាលជាងដប់ឆ្នាំកន្លងមកហើយ គេបានឃើញថាប្រទេសកម្ពុជា មានការកើនឡើងយ៉ាងខ្លាំងក្លា នូវចំនួនដីសម្បទានសេដ្ឋកិច្ច[១] ដែលរដ្ឋាភិបាលបានធ្វើឡើង ដោយមិនមានការចូល រួមពីសំណាក់សហគមន៍ ទៅលើដីធ្លីទាំងឡាយ ដែលភូមិទាំងឡាយស្ថិតនៅលើនោះ ហើយការចិញ្ចឹមជីវិតរបស់អ្នកភូមិទាំងនោះក៏អាស្រ័យ ទៅលើដីនោះផងដែរ។

នៅពេលដែលអ្នកភូមិទាំងឡាយបានដឹងថា ដីរបស់ពួកគេត្រូវបានលក់ដោយអយុត្តិធម៌ ពួកគេមានសិទ្ធិ ប្តឹងទៅអាជ្ញាធររដ្ឋអំណាចមូលដ្ឋាននៅថ្នាក់ស្រុក។ ប្រសិនបើបញ្ហារបស់ពួកគេមិនត្រូវបានធ្វើការដោះស្រាយ នៅទីនោះទេ ច្បាប់ភូមិបាលកម្ពុជាអនុញ្ញាត្តិឱ្យយកបណ្តឹងសារទុក្ខរបស់ខ្លួនទៅប្តឹងជំទាស់នៅថ្នាក់លើ គឺនៅថ្នាក់ ខេត្ត ឬ ថ្នាក់ក្រុង ហើយនៅទីបំផុត គឺប្តឹងទៅស្ថាប័នគ្រប់គ្រងជាតិ ។

នៅក្នុងខែមិថុនា និងខែតុលា ឆ្នាំ២០០៨ សហគមន៍ទាំងឡាយទូទាំងប្រទេសកម្ពុជាបានដាក់ជូនជាផ្លូវការ នូវពាក្យបណ្តឹងស្តីពីជម្លោះដីធ្លីទៅអាជ្ញាធរខេត្ត និងអាជ្ញាធររដ្ឋាភិបាលថ្នាក់ជាតិនានា។ នៅក្នុងខែសីហា ឆ្នាំ ២០០៩ សហគមន៍ទាំងឡាយបានដាក់ជូនជាថ្មីម្តងទៀត ប្រកបដោយសន្តិវិធី និងការគោរព ជាលើកទីបី នូវពាក្យបណ្តឹងចំនួន ៣២ ។ ពាក្យបណ្តឹងទាំងនោះ ទាក់ទងទៅនឹងដីសម្បទានសេដ្ឋកិច្ច និងជម្លោះដីធ្លី ដែលបានប៉ះពាល់ដល់ប្រជាជនប្រមាណ ១២.០០០ គ្រួសារ នៅក្នុងភូមិចំនួន១៦៤ ក្នុងខេត្តចំនួន ១៩ ទាក់ទងទៅនឹងដីជម្លោះប្រមាណ ៧០០.០០០ ហិចតា។

តើអ្វីខ្លះដែលសហគមន៍ទាំងឡាយចង់បាន តាមរយៈ ការដាក់ពាក្យបណ្តឹងទាំងនោះ? គឺគ្រាន់តែចង់ឱ្យមានកិច្ចប្រជុំមួយជាមួយមន្ត្រីជាប់ទាក់ទង ចង់ឱ្យបញ្ហាដីធ្លីរបស់ពួកគេ ត្រូវបានដោះស្រាយ ហើយធ្វើការស៊ើបអង្កេត និងយកការលំបាករបស់ពួកគេមកថ្លឹងថ្លែងឱ្យបានម៉ត់ចត់ យ៉ាងហោចណាស់ក៏ ដូចជាតាម ផ្លូវច្បាប់ ដូចនឹងការថ្លឹងថ្លែងនៃ សាជីវកម្មដែលបានផ្តល់ដីថ្មីៗផងដែរ។

នៅខែកញ្ញា ឆ្នាំ២០០៩ គណៈកម្មធិការសកម្មភាពសិទ្ធិមនុស្សកម្ពុជា (CHRAC) បានចេញផ្សាយ របាយការណ៍ដែលមានចំណងជើងថា "Losing Ground : Forced Evictions and Intimidation in Cambodia" (ការបាត់បង់ដីធ្លី: ការជន្លៀសដោយបង្ខំ និងការបំផិតបំភ័យនៅកម្ពុជា) ដែលជារបាយ ការណ៍មួយ ដែលចែករំលែកនូវរឿងរ៉ាវនានាផ្ទាល់ខ្លួនមួយចំនួន នៃប្រជាជន ដែលនៅពីក្រោយការបាត់បង់ដីធ្លី និងការជម្លៀស ដែលកំពុងបន្ត ដែលបានដាក់មុខមនុស្សម្នាក់ទៅនឹងវិបត្តិដ៏ធំធេងនៃប្រទេសនេះ។[២] រឿងរ៉ាវទាំងអស់នោះ គឺបាន និយាយអំពីប្រជាជនទាំងឡាយមកពីសហគមន៍នានា ដែលបានដាក់ពាក្យបណ្តឹងកាលពីខែសីហាកន្លងទៅ។

របាយការណ៍លើកទីពីនេះក៏បានស្វែងរកការ ស្រាវជ្រាវ និងបានពិពណ៌នានូវករណីដទៃទៀតជាច្រើននៅ ក្នុងពាក្យបណ្តឹងឆ្នាំ២០០៩ ហើយនឹងដើម្បីធ្វើការស៊ើបអង្កេត នូវអ្វីៗ ដែលបានកើតឡើងចាប់តាំងពីពេលនោះមកផងដែរ។ តើមានបញ្ហាជាក់លាក់ខ្លះដែលជាប់ទាក់ទិនទៅនឹងពាក្យ បណ្តឹងទាំងនោះ? នៅពេលដែលសហគមន៍ ទាំងឡាយបានស្វែងរកការទាក់ទងជាមួយរដ្ឋាភិបាលរបស់ខ្លួនតាមរយៈនីតិវិធីច្បាប់ តើបានលទ្ធផលអ្វីខ្លះទៅ? និយាយរួម ការស្រាវជ្រាវបង្ហាញថានៅក្នុងខណៈពេលដែលមានការព្យាយាមសើៗមួយចំនួនដើម្បីដោះស្រាយនូវ បញ្ហាទាំងនេះដូចដែលបានបញ្ជាក់នៅក្នុងពាក្យបណ្តឹងទាំងនោះ សហគមន៍ដ៏ច្រើនលើសលប់ដែលបានដាក់ពាក្យ បណ្តឹងទាំងឡាយក្នុង ឆ្នាំ ២០០៩ មិនបានឃើញមានការធ្វើឱ្យប្រសើរឡើងអ្វីសោះឡើយ ឬក៏ពួកគេត្រូវបានផ្តល់នូវ ជម្រើសទាំងឡាយដើម្បីជួយសម្រាលនូវស្ថានភាពដ៏លំបាករបស់ពួកគេសោះឡើយ។ ផ្ទុយទៅវិញ សហគមន៍ជា ច្រើនបានជួបប្រទះនូវការគំរាមកំហែង ការបំផិតបំភ័យ ការដណ្តើមយកដីធ្លី និងការធ្វើដីសម្បទានជាច្រើនទៀត ដែលចេះតែកើនឡើងឥតឈប់ឈរ ។

រឿងរ៉ាវរបស់ពួកគេទាំងឡាយមាននៅទីនេះ សម្រាប់អាន។ ស្រដៀងគ្នាទៅនឹងរបាយការណ៍លើកទីមួយរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRAC) ស្តីពីការបាត់បង់ដីធ្លី (Losing Ground) ប្រជាជនទាំងនោះ បានអនុញ្ញាតិឱ្យពួកយើងប្រើប្រាស់ឈ្មោះពិតប្រាកដរបស់ពួកគេ ថ្វីបើមានហេតុការណ៍ដែលថា ការធ្វើដូច្នោះ បានធ្វើឱ្យពួកគេក្លាយជាមុខសញ្ញានៃការធ្វើទុក្ខទោសក៏ដោយ។ របាយការណ៍រួមគ្នានេះ នឹងមិនអាច មានជារូបរាងបានឡើយ ប្រសិនបើគ្មានសេចក្តីក្លាហានដ៏អស្ចារ្យ និងការប្តេជ្ញាចិត្តដើម្បីរៀបរាប់នូវដំណើររឿង របស់ពួកគេក្នុងការ ខិតខំប្រឹងប្រែងដើម្បីថែរក្សាដីធ្លីរបស់ពួកគេ និងសហគមន៍ ដទៃ ទៀត វប្បធម៌ និងមុខរបរ ចិញ្ចឹមជីវិតរបស់ពួកគេ។ របាយ ការណ៍នេះបានបង្ហាញប្រកបដោយការឈឺចាប់នូវមនុស្សជាតិ ដែលកំពុងរស់នៅ ក្នុងក្តីមហន្តរាយ ។

---

[១] *ដីសម្បទានសេដ្ឋកិច្ច គឺជាកិច្ចសន្យាជួលដីរយៈពេលវែងដែលរដ្ឋាភិបាលបានផ្តល់ទៅឱ្យសាជីវកម្ម កសិ–ឧស្សាហកម្មទាំងឡាយ។ យោងទៅតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដីសម្បទានសេដ្ឋកិច្ចអាចធ្វើទៅបាន ប្រសិនបើដីនោះត្រូវបានធ្វើចំណាត់ថ្នាក់ និងបានចុះបញ្ជី ជាដីឯកជនរបស់រដ្ឋរួចហើយ។ ចំពោះការពន្យល់ពិស្តារ នៃបទបញ្ញត្តិច្បាប់ភូមិបាល សូមមើលរបាយការណ៍ Losing Ground (ការបាត់បង់ដីធ្លី)។*

[២] *Losing Ground: Forced Eviction and Intimidation in Cambodia, (ការបាត់បង់ដីធ្លី: ការជន្លៀសដោយបង្ខំ និងការបំផិតបំភិយនៅកម្ពុជា) របស់គណៈកម្មការសកម្មភាពសិទ្ធិមនុស្សកម្ពុជា ខែកញ្ញា ឆ្នាំ២០០៩ អាចទទួលពត៌មាននេះបាន តាមរយៈគេហទំព័រ http:// www.chrac.org/eng/CHRAC%20 statement%20 in %20 2009/ Losing%20 Ground %20FINAL…compressed. pdf*

# ទិដ្ឋិភាពទូទៅ

"កុមារី ស សុខា អាយុ ១២ ឆ្នាំ បាននិយាយ អង្វរក-ទាំងទឹកភ្នែកហូររហាមថា "ឥឡូវនេះខ្ញុំចង់អោយឪពុករបស់ខ្ញុំត្រឡប់មកវិញ និងខ្ញុំចង់បានដីស្រែរបស់ខ្ញុំមកវិញតែ ប៉ុណ្ណោះ"។

"នាងបានបន្ថែមថា វាអយុត្តិធម៌ណាស់ ចំពោះការកាត់ទោសរបស់តុលាការទៅលើឪពុករបស់នាង ដែលត្រូវ បានចាប់ខ្លួន និងដាក់គុក ដោយសារតែរូបគាត់ធ្វើស្រែនៅលើដីរបស់គាត់នៅក្នុងខេត្តកំពង់ឆ្នាំង។"

លោកអាចារ្យ ស៊ីម លាប អាយុ៦២ឆ្នាំ ដែលបានបែកក្រុមគ្រួសារ និងបាត់ខ្លួនអស់រយៈពេល ៣៥៦ថ្ងៃ កំពុងធ្លាក់ខ្លួនទ្រុឌទ្រោមនៅក្នុងពន្ធនាគារក្នុងទីក្រុងសៀមរាប ក្រោយពេលគាត់ត្រូវបានចាប់ខ្លួន និងកាត់ ទោសអោយជាប់គុកខុសច្បាប់ នៃមនុស្សមក-ពីខាងក្រៅពីររូប ដែលបានធ្វើស្រែនៅលើដីរបស់អ្នកភូមិ។

អេង សំអាត អ្នកពិការមួយរូប ដែលនៅតែមានការបាត់បង់សម្បៀង និងជីវភាពរស់នៅរបស់គាត់ទាំងស្រុង ដោយសារគម្រោងធារាសាស្ត្រនៅក្នុងខេត្តពោធិ៍សាត់នោះ និយាយថា "ខ្ញុំ បានដេកកណ្តាលថ្នល់ ដើម្បីអោយឡានកិនខ្ញុំ"

សឿន ស្រីអូន អាយុ ២៧ឆ្នាំ ដែលទើបតែមកដល់ដោយមានពរកូនតូចនៅនឹងចង្កេះ ដើម្បីចូលរួមនោះកិច្ច ពិភាក្សាអំពីស្ថានការណ៍ នៃការបាត់បង់ដីធ្លីរបស់ខ្លួននៅក្នុងខេត្តកំពតនោះបានសួរថា "តើពួកគេបានធ្វើការ ឈូសឆាយចំការល្ហុងរបស់អ្នកឬ "?

ស្វាយ ច្រឹប អាយយុ ៤៤ឆ្នាំ ដែលកំពង់តែមានផ្ទៃពោះហើយរំពឹងថា នឹងឆ្លងទន្លេក្នុងពេលឆាប់ៗនេះនោះ បានឆ្លើយតបថា "នោះហើយដែលខ្ញុំមានការព្រួយបារម្ភនោះ "ហើយឥឡូវនេះចំការរបស់ពូ ខនត្រូវបានគេ ឈូសចោលអស់ហើយ " ។

លោកយាយ ទន់ សាំង ដែលរស់នៅក្នុងស្រុកគាស់ក្រឡ ខេត្តបាត់ដំបងបានសួរថា "ហេតុអ្វីបានជាពួកគេ មកដីរបស់យើង ដោយមិនអោយពួកយើងធ្វើស្រែបាន?" – " ពួកយើងទាំងអស់គ្នានឹងស្លាប់ ប្រសិនបើយើង គ្មានដីធ្វើស្រែនោះ "។

ករណីសិក្សាដែលបានលាតត្រដាងនៅក្នុងរបាយ ការណ៍នេះ ផ្តល់នូវបង្អួចមួយទៅក្នុងជីវិតនៅពីក្រោយជំលោះ ដីធ្លីដែលកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះផ្តល់បច្ចុប្បន្នភាពមួយលើជម្លោះដីធ្លី និងភូមិ ដែលមានការប៉ះពាល់ដោយសារបញ្ហានេះ និងធ្វើការព្យាយាមដោះស្រាយចំងល់ របស់ប្រជាពលរដ្ឋ តួយ៉ាង ដូចជាលោកយាយ សាំង និងអ្នកដ៏ទៃ ទៀត-ដែលបានសួរខាងលើ ក៏ដូចជាសំណួរចម្លើយ "ថាតើនឹងមានអ្វីកើតឡើងបន្តទៅទៀត? "។



*កងយោធពលខេមរៈភូមិន្ទ ការពារ គ្រឿងចក្រប៊ុលឌូស៊ើ របស់ក្រុមហ៊ុន ស៊ូហ្គីភ្នំពេញ ខណពេលដែល ប្រជាជននៅឃុំអមលាំង ក្នុងខេត្តកំពង់ស្ពឺកំពង់ព្យាយាមបញ្ឈប់ការឈូសឆាយដី។*



*ផែនទីកំណត់តំបន់កសិឧស្សាហកម្មរបស់ក្រុមហ៊ុន អេច អិល អេច ដែលមានទីតាំងក្នុងតំបន់ ជំរកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលមានផ្ទៃដីចំនួន ៩៩៨៥ ហិកតា។ ទំហំដី–នេះត្រូវបានផ្ទេរពីសម្បត្តិរដ្ឋ ទៅជាសម្បត្តិឯកជន មុនពេលប្រគល់អោយក្រុមហ៊ុន អេច អិល អេច (ច្បាប់ចម្លងនៃអនុក្រឹត្រមួយច្បាប់ក៏បានភ្ជាប់ជាមួយផងដែរ នៅផ្នែកខាងឆ្វេងនៃផែនទី)*

ការប្រមូលករណីសិក្សាចំនួន១១នេះ វាគ្រាន់តែជាការបង្ហាញនូវឧទាហរណ៍មួយចំនួន នៃជម្លោះដីធ្លីដ៏ខ្លាំងបំផុត ដែលកំពុងតែបានកើតមានពាសពេញប្រទេសកម្ពុជា ដែលបានបង្កឡើងដោយ " គំរោងអភិវឌ្ឍន៍ ឧស្សាហកម្ម " នៅក្នុងអំឡុងពេលជិត២ទស្សវត្សន៍នេះ។

ទីណាដែលយើងបានទៅដល់ យើងបានឃើញភាពភ័យតក់ស្លុតយ៉ាងខ្លាំងខ្លានៃការចាប់ខ្លួនរបស់ប្រជាពលរដ្ឋ ការស្រែកទ្រហ៊ោយំរកម៉ែជួយ អំពីការបាត់បង់ដីធ្លី ការនិយាយ–អង្វរក របស់ក្រុមកុមារសុំអោយមានដោះលែងឪពុក ម្តាយរបស់ខ្លួនដែលត្រូវបានគេចាប់ដាក់គុក ពីបទចោទប្រកាន់ដោយគ្មានភស្តុតាង ពាក់ពន្ធ័ទៅនឹង ជម្លោះដីធ្លី។

ពីទំព័រមួយទៅទំព័រមួយ យើងឃើញភាពរងទុក្ខវេទ–នាលំបាករបស់អ្នកស្រុកក្រីក្រ ប្រឈមមុខទល់នឹងក្រុម ឈ្មួញ ឬក្រុមហ៊ុនដែលជាអ្នកមាន និងមានអំណាចខ្លាំងខ្លា ដែលបានចូលទៅច្បាមយកដីរបស់ពួកគាត់ ដោយគ្មានក្តីអាណិតអាសូរ ឬលើកលែងអោយឡើយ។

នៅពេលដែលបញ្ហាជម្លោះដីធ្លី កើតមានឡើង ដោយមនុស្សមកពីគ្រប់ស្រទាប់ ពីមន្ត្រីយោធា ពីមន្ត្រីរដ្ឋភិបាល រហូត–ដល់ អ្នកជំនួញដែលជាអ្នកមាននោះមក បុគ្គលមានអំណាចមួយចំនួនបាននាំមុខគេនៅ ក្នុងជម្លោះទាំងនេះពាសពេញប្រទេស កម្ពុជា។

ចាប់ពីខេត្តកោះកុងឆ្នេរសមុទ្រ រហូតដល់ខេត្តកំពង់ស្ពឺ ដែលមានភ្នំ ស្ថិតនៅខាងលិចទីក្រុងភ្នំពេញ រហូតដល់ខេត្តឧត្តរ–មានជ័យតាមបណ្តោយព្រំដែនខ្មែរថៃ កសិករបានទទួលរងនូវផលប៉ះពាល់ដូចគ្នា ដោយស្នារដៃក្រុម ហ៊ុនធ្វើចំការ ដែលប្រដាប់ដោយអាវុធ ព្រមទាំងមានប្រាក់កាស និងអំណាច។

ឈ្មោះសេដ្ឋីដែលជាអ្នកជំនួញផង ជាសមាជិកព្រឹទ្ធសភាផង និងជាអ្នកច្បាមយកដីធ្លីផងនោះ ត្រូវបានគេឮ ពាសពេញនៅក្នុងសហគមន៍ ចាប់ពីតំបន់ខាងត្បូងដល់ខាងជើងទូទាំងប្រទេស ថាជាអ្នកពាក់ព័ន្ធនៅក្នុង ជម្លោះដីធ្លីជាមួយប្រជាពលរដ្ឋរាប់ពាន់នាក់។ ម្យ៉ាងវិញទៀត ឈ្មោះឈ្មួញស្រីម្នាក់ទៀត ដែលជាអ្នកមាន និង មានអំណាច ជាអ្នកគាំទ្រដល់ស្ថាប័នកាកបាទក្រហមកម្ពុជា និងជាមិត្តភក្ត្រជិតស្និទជាមួយភរិយាសម្តេច នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ជាមនុស្សម្នាក់ល្បីល្បាញផងដែរ នៅក្នុងតំបន់ផ្សេងៗ នៃប្រទេសកម្ពុជា ដែលជាកន្លែងជម្លោះដីធ្លីកើតមានឡើងនោះ។ នៅមានរឿងធ្ងន់ធ្ងរជាងនេះទៀតនោះ គឺយុទ្ធសាស្ត្រ "អភិវឌ្ឍន៍" ថ្មីៗនេះរបស់រដ្ឋាភិបាលក្នុងការគាំទ្រក្រុម ហ៊ុន ដោយមាន កង–កម្លាំងយោធា និងកងកម្លាំងប្រដាប់អាវុធដ៏ទៃទៀត និងអនុញ្ញាតិអោយក្រុមហ៊ុន ជួលទាហាន ដើម្បីការពារដីថ្មីរបស់ខ្លួន ដែលបានជម្រុញអោយជម្លោះដីធ្លីកាន់តែមានភាពធ្ងន់ធ្ងរថែមទៀត។

សកម្មភាពនៅក្នុងទម្រង់ឆ្លៀតយកផលប្រយោជន៍ និងការគ្មានទោសទណ្ឌនេះ អ្នកយាមអោយក្រុមហ៊ុន ដែលជា–

ទាហាន របស់រដ្ឋាភិបាល នឹងបាញ់ទៅលើប្រជាពលរដ្ឋ ទៅលើគោក្របីណា ដែលហ៊ានចូលទៅក្នុងដី ចៅហ្វាយថ្មីរបស់ខ្លួន។ ជាឧទាហរណ៍ ចំការអំពៅនៅកោះកុង ទាំងរដ្ឋាភិបាល និងតុលាការមិនខ្វល់រវល់អ្វី ជាមួយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋឡើយ។

ប៉ុន្តែការចាប់ច្បាមយកដីធ្លី មិនត្រឹមតែប្រព្រឹត្តឡើងដោយក្រុមហ៊ុន និងអ្នកជំនួញកម្ពុជានោះទេ ក្រុមហ៊ុន បរទេសក៏បានព្រឹត្តអំពើមិនល្អនេះដែរទៅលើប្រជាជនក្រីក្រកម្ពុជា ដោយការប្រើអំណាច ឬប្រាក់កាស ដើម្បី ទទួលបានការអនុញ្ញាតពីអាជ្ញាធរក្នុងស្រុក និង តុលាការ ដែលជាធម្មតាកើតមាននៅក្នុងដៃគូក្រុមហ៊ុនកម្ពុជា។ ក្រុមហ៊ុនវៀតណាម អូស្ត្រាលី បារាំង សឹង្ហបុរី កូរ៉េ ចិន ក្រុមហ៊ុនដ៏ទៃៗទៀត និងក្រុមអ្នកជំនួញ បានចូលមកបំផ្លិចបំផ្លាញព្រៃសហគមន៍ និងដីស្រែចំការ ដើម្បីបើកផ្លូវសំរាប់ចំការកៅស៊ូ ឬកសិឧស្សាហកម្ម ផ្សេងៗ។

គណៈពេលដែលភាគច្រើននៃអ្នករងគ្រោះដោយសារជម្លោះដីធ្លីជាអ្នកក្រ និងគ្មានអំណាច ជាប្រជាពលរដ្ឋ កម្ពុជាដែលរស់នៅតំបន់ដីទំនាបនោះ ប្រជាជនជនជាតិភាគតិច ដែលរស់នៅតំបន់ភ្នំ និងដីសណ្តរ ក៏មិនមានសុវត្ថិភាពដូចគ្នាដែរ។

ចាប់ពីជនជាតិភាគតិច សួយ នៅក្នុងខេត្តកំពង់ស្ពឺ រហូត–ដល់ ជនជាតិភាគតិច ស្មៀងនៅក្នុងខេត្តក្រចេះ ជនជាតិភាគតិចភ្នងនៅខេត្តមណ្ឌលគីរី ការបាត់បង់ដីធ្លីតំណាងអោយការចាប់ផ្តើមនៃការបញ្ចប់ប្រពៃណី ជំនឿ និងការរស់នៅរបស់ខ្លួន ដែល–ជាកន្លែង គ្រឿងចក្ររបស់ក្រុមហ៊ុនកម្ពុជា ឬបរទេសបានទៅដល់។

ដោយធ្លាក់ទៅក្នុងអន្ទាក់បទពិសោធន៍នៃការឈឺចាប់បែបនេះហើយ ប្រជាពលរដ្ឋបាននាំគ្នាធ្វើការតវ៉ាដោយសន្តិវិធី នៅកន្លែងដែលពួកគេបានទទួលរងផលប៉ះពាល់ (នៅក្នុងភូមិរបស់ខ្លួន ឬនៅខាងក្រៅពន្ធនាគារ និង តុលាការ) ឬមានការដើរហែរជាក្បួនចម្ងាយរាប់សិបគីឡូម៉ែត្រ ដើម្បីបញ្ចេញកំហឹងរបស់ខ្លួននៅខាងមុខ ភូមិគ្រឹះរបស់សម្តេចនាយករដ្ឋមន្ត្រី ដែល–ជួន កាលបានត្រឹមតែត្រូវគេបង្ខំអោយត្រឡប់ទៅផ្ទះវិញ ដោយគ្មានដំណោះស្រាយអ្វីឡើយ។

ដោយមានការប្រឈមមុខនឹងសង្គ្រាមផ្លូវច្បាប់យ៉ាងស្រួចស្រាវនោះ ប្រជាពលរដ្ឋខ្លះបានធ្វើការជ្រើសរើសយកការស្រុះស្រួលជាមួយក្រុមហ៊ុន ដោយមានការយល់ព្រមទទួលយកសំណងខ្លះៗ ឬក៏ផ្នែកខ្លះនៃដីរបស់ ខ្លួនវិញជាជាងមិនបានអ្វីសោះ។

ក្រុមហ៊ុនខ្លះ ដូចជាក្រុមហ៊ុនចំការអំពៅរបស់សមាជិកព្រឹទ្ធសភា មានការជាប់ពាក់ពន្ធ័រទៅនិងក្រុមហ៊ុនដ៏ទៃទៀតដែលស្ថិត នៅក្រោមឈ្មោះសមាជិកនៃក្រុមគ្រួសាររបស់ខ្លួន ដើម្បីអោយបានទទួលដី សម្បទានសេដ្ឋកិច្ចអោយកាន់តែច្រើន ដែលអាចផ្ទុយទៅនិងច្បាប់ដីធ្លីឆ្នាំ២០០១។

ភាគច្រើននៃក្រុមហ៊ុនទាំងនេះត្រូវបានគេផ្តល់ដីសម្បទានសេដ្ឋកិច្ចច្រើនជាងអ្វីដែលច្បាប់បានកំណត់ គឺមិនអោយលើស–ពី មួយម៉ឺនហិកតា ដែលចែងនៅក្នុងច្បាប់។ យោងតាមអនុក្រិត្យស្តីពីការសម្បទានដីសេដ្ឋកិច្ច ការធ្វើសម្បទានណាដែលលើសពីចំនួនកំណត់នេះ ហើយប្រគល់អោយមុនពេលច្បាប់ឆ្នាំ២០០១នោះ និងត្រូវគេធ្វើការសើររើឡើងវិញ ហើយការចរចារនិងត្រូវធ្វើឡើងដោយមានការសើររើបន្ថយនូវទំហំដី។ មកទល់បច្ចុប្បន្ននេះចំការធំៗមួយចំនួននៅតែស្ថិតនៅលើសចំនួនរហូតទៅដល់ទៅ៣០ដងនៃចំនួនកំណត់។

ក្រុមហ៊ុនទាំងនោះរួមមានក្រុមហ៊ុភាភីម៉ិច ដែលគេបាន–ផ្តល់ អោយចំនួន៣១០០០០ហិកតានៅខេត្តកំពង់ឆ្នាំង និងពោធិសាត់។ ក្រុមហ៊ុនគ្រីនស៊ីដែលជារបស់សេដ្ឋីមុខជំនួញដែលជាសមាជិកព្រឹទ្ធសភា ត្រូវបានគេផ្តល់អោយ ចំនួន១០០០០ហិកតា នៅក្នុងខេត្តស្ទឹងត្រែង ចំការអំពៅគឺជាក្រុមប្អូនស្រីរបស់គាត់ ដែលត្រូវបានគេផ្តល់អោយសរុបទាំងអស់ចំនួន២០០០០ហិកតា នៅក្នុងខេត្តកោះកុង កំពង់ស្ពឺ និងឧត្តរមានជ័យ។

ទោះបីជាស្ថិតក្នុងករណីណាក៏ដោយ ប្រជាពលរដ្ឋមានភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថាដីនោះគឺជាដីរបស់ពួក គេ ដែលរដ្ឋាភិបាល និងតុលាការតែងតែធ្វើមិនដឹងមិនលឺចំពោះ–ពាក្យ បណ្តឹងរបស់ខ្លួន។ វាដំណើរការទៅ ដោយគ្មានការនិយាយ "ពេលលុយនិយាយ ការពិតត្រូវបានស្ងប់ស្ងាត់"

ករណីជំលោះដីធ្លីនៅក្នុងរបាយការណ៍ ដែលបានធ្វើនៅក្នុងបច្ចុប្បន្នភាពនេះ គ្រាន់តែជាចំនុចកំពូលនៃផ្ទាំង ទឹកកកអណ្តែតនៃដីដែលគេបានច្បាមយក និងបញ្ហាជំលោះដីធ្លី ដែល ធ្វើអោយ–រង្គោះរង្គើគ្រឹះនៃការបង្កើត សហគមន៍ទូទាំងប្រទេស កម្ពុជា។

បើគ្មានវិធានការណ៏ ប្រសិទ្ធិភាពត្រូវបានប្រកាន់យកដើម្បីសើរើ និន្នាការបច្ចុប្បន្ននោះទេ ការច្បាមយកដីធ្លី ជំលោះដីធ្លីនិងចាកផុតពីការគ្រប់គ្រង ក្នុងបុព្វហេតុនៃការរស់នៅ វប្បធម៌ប្រពៃណីរបស់ប្រជាជនក្រីក្រ ខណពេលដែលពួកឈ្មួញកំពូលៗមួយចំនួនតូច នៅតែបន្តកំណត់នូវជោគវាសនារបស់ខ្លួននោះ។

# ស្ត្រីនៅខេត្តកំពតក្រោកឈរឡើងប្រយុទ្ធដើម្បីសមុទ្ររបស់ពួកគាត់

## កំពត



*ក្រុមស្ត្រីអ្នកលក់ដូរ កំពុងតែមមាញឹកក្នុងការលក់ត្រីរបស់ពួកគាត់ដែលចាប់បានក្នុងទឹកជ្រៅនៅឯសមុទ្រក្នុងខេត្តកំពត។ ដោយឡែកសំរាប់អ្នកដែលនេសាទនៅទឹករាក់នឹងត្រូវបាត់បង់មុខរបរ របស់គាត់នៅពេលដែលក្រុមអ្នកអភិវឌ្ឍន៍ធ្វើការ ចាក់ដីលុបសមុទ្រនៅក្នុងស្រុកទឹកឈូ។*

**ករណី: ឃុំបឹងទូក ស្រុកទឹកឈូរ ខេត្តកំពត**

ជម្លោះ: ជម្លោះរវាងភូមិចំនួនបីជាមួយនឹងក្រុមហ៊ុនចំនួនពីរ គឺកំពង់ផែកំពត ដែលកម្មសិទ្ធិរបស់លោក វិញ ហ៊ួរ (Vinh Huor) និងក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យកែវជា ដែលត្រូវទទួលបានការអនុញ្ញាតិឱ្យចាក់ដីបំពេញសមុទ្ទ ចំនួន ១.000 ហិចតានៅភូមិរលួស និងចំនួន ២00 ហិចតានៅកែបថ្មី និងភូមិទទឹងថ្ងៃ ដើម្បីបើកផ្លូវឱ្យមាន ការសាងសង់កំពង់ផែថ្មីពីរទៀត ។

ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើង:

នៅខែមករា ឆ្នាំ២0១0: ក្រសួងកសិកម្ម បានចេញលិខិតមួយដោយបង្គាប់ឱ្យក្រុមហ៊ុនបញ្ឈប់ការសាងសង់ជាបណ្តោះ អាសន្ននៅកែបថ្មី ភូមិទទឹងថ្ងៃ ដោយសារកំហុសដែលក្រុមហ៊ុនបានធ្វើក្នុងការ អនុវត្តសេចក្តីណែនាំរបស់ក្រសួង ។ រដ្ឋាភិបាលមិនទាន់ធ្វើសេចក្តីសម្រេចជាចុងក្រោយ ទៅលើអ្វីដែលជាអនាគតនៅលើដីនោះនៅឡើយទេថាតើក្រុមហ៊ុននឹងត្រូវបានអនុញ្ញាតិឱ្យចាប់ផ្តើមបន្តការងាររបស់ខ្លួន ឬយ៉ាងណា? ។ នៅក្នុងជម្លោះ ជាមួយក្រុមហ៊ុនរបស់លោក វិញ ហ៊ួរ វាមិនទាន់មានដំណោះ ស្រាយអ្វីនៅឡើយនោះទេរហូតដល់ពេលនេះ ។



នៅក្នុងរឿងព្រេងប្រជាប្រិយខ្មែរ ឈ្មោះ"ប្រាសាទភ្នំជីសូរ"មាន អាចារ្យព្រាហ្មណ៍មួយរូបបានឱ្យពរដល់ ព្រះអង្គម្ចាស់មួយអង្គថា"សូមឱ្យអ្នក មានកម្លាំងដូចស្រមោច មានឫទ្ធិដូចខ្មោច និងមានចិត្តដាច់ដូចមនុស្សស្រី"។

រឿងព្រេងនេះបានធ្វើឱ្យប្រជាជនកម្ពុជាភាគច្រើនជឿថាស្ត្រីពិត ជាអាចខ្លាំងក្លាមែន។

ហេតុដូចនេះហើយ នៅពេលដែលក្រុមហ៊ុនចំនួនពីរបានចាប់ ផ្តើមចាក់ដីលុបសមុទ្រនៅក្នុងឃុំបឹងទូក ខេត្ត កំពត ដើម្បីសាងសង់ កំពង់ ផែពីរនៅទីនោះ អ្នកភូមិដែលរងផលប៉ះពាល់បានសម្រេច ចិត្តជ្រើសរើស ស្ត្រីជាតំណាង របស់ពួកគេក្នុងការតវ៉ាប្រឆាំងនឹងគម្រោងអភិវឌ្ឍន៍នេះ។

អ្នកកស្រី ចាន់ ដារ៉ា ដែលមានអាយុ ៥០ ឆ្នាំ និងជាស្ត្រីម្នាក់ក្នុង ចំណោមសកម្មជនស្ត្រីទាំង ៥ រូប ដែលត្រូវជ្រើសរើសឱ្យធ្វើជាអ្នកតំណាង បានមានប្រសាសន៍ថា អ្នកស្រីបានដឹងអំពីអ្វីដែលអ្នកស្រីបានកំពុងធ្វើ ហើយ វាមិនមែនជារឿងងាយស្រួលឡើយក្នុងការបង្ខំអ្នកស្រីឱ្យបញ្ឈប់ការតវ៉ា របស់គាត់។

អ្នកស្រី ដារ៉ា ក៏បាននិយាយថា ប្រជាជនភាគច្រើននៅទីនេះ បាន ចិញ្ចឹមជីវិតពួកគេ តាមរយៈការនេសាទ នៅទឹករាក់ៗ ដោយប្រើប្រាស់ឧ–បករណ៍បុរាណផ្សេងៗ។

អ្នកស្រីបានពន្យល់ថា នៅពេលដែលក្រុមហ៊ុនទាំងនោះបានចាប់ ផ្តើមចាក់ដីបំពេញលើផ្ទៃដី ៤ គីឡូម៉ែត្រតភ្ជាប់ពីច្រាំងសមុទ្រ ក្នុងឆ្នាំ ២០០៨ វាបានបំផ្លាញតំបន់ នេសាទរបស់ពួកគាត់។ យោងតាមសំដីរបស់អ្នកភូមិទាំង ឡាយបានឱ្យដឹងថា ប្រជាជនភាគ ច្រើនពុំមានទូកធំៗដើម្បីចេញទៅ នេសាទក្នុងទឹកជ្រៅបានឡើយ។ ទង្វើនេះបាន ជំរុញឱ្យអ្នកភូមិធ្វើ ការតវ៉ា។

អ្នកស្រី ដារ៉ា បានបន្ត ទៀតថា អាជ្ញាធរបានប្រើល្បិច និង គម្រាមកំហែងអ្នកតំណាង ទាំងឡាយឱ្យធ្វើ កិច្ចសន្យាកុំបន្តការតវ៉ារបស់ពួកគាត់តទៅទៀត។

អ្នកស្រី ដារ៉ា បាន មានប្រសាសន៍ទៀតថា "ខ្ញុំមិន បាន សារភាពថាខ្លួនខ្ញុំបានធ្វើ ខុសឡើយ ព្រោះខ្ញុំមិនបានសម្លាប់ អ្នកណាម្នាក់ ឬលួចទ្រព្យ សម្បត្តិ អ្នកដទៃឡើយ។ ខ្ញុំធ្វើនេះដើម្បី ប្រជាជន និងដើម្បីខ្លួន ខ្ញុំផ្ទាល់។"

ដោយបានប្រឈមមុខ ទៅនឹងការគម្រាមកំហែងនេះ



*លោកស្រី ចាន់ ដារ៉ា ឈរនៅខាងមុខផ្ទះរបស់គាត់ក្នុងខេត្តកំពត។ គាត់ជាមួយនឹងក្រុមស្ត្រី ដ៏ទៃទៀតត្រូវបានជ្រើសតាំងជាអ្នកដឹកនាំ ក្នុងការតស៊ូដណ្តើមយកសមុទ្ររបស់ពួកគាត់វិញ។*

អ្នកស្រី ដារ៉ា បាននិយាយថា គាត់ជឿជាក់ថា ស្ត្រីទាំងឡាយគួរតែក្រោក ឈរឡើងឱ្យបានរឹងមាំ។ គាត់បានបន្តទៀតថា "អ្នកតំណាងស្ត្រី ជាច្រើន កាន់តែមានចំណេះដឹងច្រើនឡើងថែមទៀត ហើយពួកប្រុសៗកាន់តែមាន ការព្រួយបារម្ភ។"

អ្នកស្រី ឌួង យាង អាយុ ៤៧ ឆ្នាំ និងជាអ្នកតំណាងម្នាក់ផងដែរ ក៏បានយល់ស្របទៅនឹងសំដី ខាងលើ។

អ្នកស្រីបាននិយាយថា "ក្នុងឋានៈជាស្ត្រី ពួកយើងមានភាពងាយ ស្រួលក្នុងការចូលជួបអស់លោក– ឯកឧត្តម ទាំងនោះ។ "

ទោះបីជាយ៉ាងនេះក៏ដោយ ក៏អស់លោក–ឯកឧត្តម (ឬមន្ត្រីរាជ រដ្ឋាភិបាល) នានា ជានិច្ចកាលតែងតែ មិនបានគោរពស្ត្រីទេ។

អ្នកស្រី លឹម ថៅ ដែលមានអាយុ ៤៣ ឆ្នាំ និងជាអ្នក តំណាងមួយរូប ដែលត្រូវបានជ្រើសរើសផងដែរ នោះ បានមានប្រសាសន៍ ថា គាត់ និងអ្នកតំណាងទាំង ៥ រូបផ្សេងទៀត ត្រូវបានគេកោះហៅឱ្យទៅ កាន់សាលាខេត្ត ។

អ្នកស្រីបាននិយាយថា មន្ត្រីទាំងនោះបានប្រាប់គាត់ថា សម្តេច តេជោ ហ៊ុន សែន នឹងមិនទុកឱ្យ ប្រជាពលរដ្ឋស្លាប់នោះទេ ហើយរាជ រដ្ឋាភិបាលនឹងចែកអំណោយដល់ប្រជាពលរដ្ឋទាំងនោះ។

ប៉ុន្តែ អ្នកស្រី ថៅ បានឆ្លើយតបថា អ្នកភូមិមិនចង់បាន អំណោយ នោះទេហើយអ្វីៗដែល ពួកគាត់ ចង់បាន មកវិញនោះ គឺជីវភាព ធម្មតារបស់ពួកគាត់តែប៉ុណ្ណោះ ទេ។

ដោយបានធ្វើត្រាប់ តាមសកម្មភាពរបស់ មន្ត្រីនោះផង ដែរ អ្នកស្រីបាននិយាយថា "បុរស នោះបានរុញតុ ឰស្ទូកាំង។ ខ្ញុំមាន អារម្មណ៍ថា បុរសនោះកំពុងដាក់ សំពាធមកលើខ្ញុំហើយ"។ ទោះបី ជាមានការគម្រាមកំហែងយ៉ាងនេះ ក្តី ក៏នៅ មានព័ត៌មាន ល្អៗមួយចំនួន ផង ដែរ។

ក្រសួងកសិកម្មបាន ចេញលិខិតមួយនៅខែមករា ឆ្នាំ ២០១០បង្គាប់ឱ្យក្រុមហ៊ុនផ្អាក ការ សាងសង់ កំពង់ផែជា បណ្តោះ អាសន្ននៅភូមិកែបថ្មីនិងភូមិទទឹងថ្ងៃ ដោយសារមានកំហុសផ្នែកនីតិវិធី

ក្នុងខណៈពេល ដែល អ្នកស្រី ដារា បាននិយាយ បញ្ចប់ប្រយោគចុងក្រោយ របស់គាត់ ស្រាប់តែមានបុរស

ម្នាក់ដែលមានអាយុប្រហែលនឹងអ្នកស្រីបានដើរចូលមកជិត។ អ្នកស្រីបានឱ្យបប្រាប់ថា បុរសនោះ គឺជាអ្នកផ្តល់ ដំណឹងរបស់អាជ្ញាធរមូលដ្ឋាន មានភារកិច្ចឈ្លបយកការណ៍ពីអ្នកភូមិ។

អ្នកស្រីបានហុចលិខិតរបស់រដ្ឋមន្ត្រីទៅឱ្យបុរសនោះដែលក្រោយមក គាត់ហាក់ធ្វើ ដូចជាប្តូរជំហរ ហើយ បង្ហាញពីការគាំទ្ររបស់គាត់ចំពោះការតវ៉ាទាំងនេះ ប្រសិនបើជាគាត់ពិត ជាអ្នកយកការណ៍មែននោះ។

> "ក្នុងឋានៈជាស្ត្រី ពួកយើងមានភាពងាយស្រួលក្នុងការចូលជួបអស់លោក- ឯកឧត្តមទាំងនោះ។ "

បុរសនោះបាននិយាយថា "ប្រសិនបើ ការអភិវឌ្ឍនៅតែបន្តនោះ អ្វីៗនឹងកាន់តែអាក្រក់។" គាត់បានបន្ថែមថា "ខ្ញុំបារម្ភខ្លាចតែ កូនប្រុស ទាំង ៣ នាក់ និងកូនស្រីម្នាក់ របស់ ខ្ញុំ ត្រូវ បោះបង់ការសិក្សានោះទេ " ។

នៅពេលសួរថា តើគាត់មានយោបល់យ៉ាងណាចំពោះលិខិតនេះ? បុរសនោះឈប់អានលិខិតហើយបែរមកសម្លឹងមើលមុខអ្នកស្រី ដារ៉ា ដើម្បីឱ្យជួយឆ្លើយគាត់ ។

អ្នកស្រីបាននិយាយថា "បើសិនណាជារាជរដ្ឋាភិបាលធ្វើម៉ឺងម៉ាត់ ពួកគេអាចបញ្ឈប់ការអភិវឌ្ឍនេះបាន។ ក៏ប៉ុន្តែជាធម្មតា ពួកគេតែងតែទទួលបានព័ត៌មានមិនត្រឹមត្រូវពីមន្ត្រីថ្នាក់ក្រោម " ។



*ខ្ទមស្បូវរបស់អ្នកស្រី ចាន់ ដារ៉ា ឈរនៅខាងមុខផ្ទះឈើខ្ពស់មួយនៅក្នុងភូមិកែបថ្មី។ ប្រឈមមុខនៅនឹងការបាត់បង់ដែននេសាទ ក្តីសុបិនរបស់អ្នកស្រី ដារ៉ា ក្នុងការសាងសង់ផ្ទះរបស់គាត់ឱ្យបានសមរម្យឡើងវិញ នឹងត្រូវរលាយដូចផ្សែង។*

# អ្នកស្រុកប៊ូស្រារីករាយក្នុងខណៈដែលកសិករទាំងឡាយប្រកបការងារដោយខ្លួនឯង មិនស៊ីឈ្នួលគេ

## មណ្ឌលគីរី



*ផែនទីចង្អុលបង្ហាញតំបន់ការពាររបស់រមណីយដ្ឋានទឹកធ្លាក់ ប៊ូស្រា*

**ករណី: ឃុំប៊ូស្រា ស្រុកពេជ្រចិន្តា ខេត្តមណ្ឌលគីរី**

សម្បទាន: ផ្តល់រយៈពេល ៧០ឆ្នាំសម្រាប់ចំការដំណាំកៅស៊ូ

កាលបរិច្ឆេទ និងទំហំ: ចំនួន ១០.០០០ហិចតា ផ្តល់នៅខែតុលា ឆ្នាំ២០០៨ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ក្រុមហ៊ុន: សហវិនិយោគរវាងក្រុមហ៊ុនបារាំងឈ្មោះសុកហ្វីន (Socfin) និងក្រុមហ៊ុនខ្មែរឈ្មោះ ឃេស៊ីឌី (KCD) ។

គម្រោងអភិវឌ្ឍន៍: ចំការដំណាំកៅស៊ូដោយមានការស្នើសុំទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) ដើម្បីគាំទ្រ ដល់ចំការដំណាំកៅស៊ូជាលក្ខណៈគ្រួសារនៅតំបន់ជិតខាង ។

- ខែឧសភា–ខែកញ្ញា ឆ្នាំ២០០៩: ក្រុមហ៊ុនបានដាំដើមកៅស៊ូ និងបន្តការឈូសឆាយដី ។
- ខែវិច្ឆិកា ឆ្នាំ២០០៩: អង្គការក្រៅរដ្ឋាភិបាលបានផ្តល់អនុសារណៈច្បាប់ដល់សហគមន៍ និងក្រុមហ៊ុន ។
- ខែមករា ឆ្នាំ២០១០: ក្រុមហ៊ុនសុកហ្វីនបានបញ្ឈប់ការឈូសឆាយដី ហើយស្នើសុំឱ្យមានកិច្ចប្រជុំជាមួយ រដ្ឋាភិបាល និងសហគមន៍ដើម្បីធ្វើការចរចារគ្នា ។





*ជនជាតិដើមភាគតិច ពូ នង ដែលជាអ្នកតន្ត្រីករ សុខចិត្តរស់នៅដោយ ប្រកប របរជាអ្នកសុំទាននៅឯរមណីយដ្ឋានទឹកធ្លាក់ ប៊ូស្រា ជាជាងលក់កម្លាំងពលកម្ម ទៅស៊ីឈ្នួលឱ្យក្រុមហ៊ុនដាំកៅស៊ូ។*

អស់ជាច្រើនសតវត្សមកហើយជនជាតិភាគតិចពូនង[១] នៅក្នុងតំបន់ ដាច់ស្រយាលនៃខេត្តមណ្ឌលគីរីបាន និងកំពុងរស់នៅចិញ្ចឹមជីវិតតាមរបៀបតែមួយគត់ ខុសប្លែកពីជនជាតិខ្មែរយ៉ាងច្រើន ដែលរស់នៅជិតខាងគ្នា ដោយប្រពៃណីកសិកម្មជាចំការវិលជុំ និងជំនឿនានារបស់ពួកគេ ក្នុងស្មារតីនៃ អ្នកថែរក្សាទឹកដី និងព្រៃព្រឹក្សានានា។

បច្ចុប្បន្ននេះ ជំនឿ និងប្រពៃណីរបស់ពួកគេអាចនឹងត្រូវបាត់បង់ទាំងស្រុង ដោយហេតុថា ក្រុមហ៊ុន អភិវឌ្ឍន៍ទាំងឡាយ ដែលបានទទួលដីសម្បទានដីសេដ្ឋកិច្ចរួចហើយ បានចូលទៅកាន់តំបន់នោះ ដើម្បីធ្វើការឈូស ឆាយព្រៃពិសិដ្ឋទាំងឡាយ និងដីកសិកម្មជាប្រពៃណី របស់ពួក គេ។

ទន្ទឹមនឹងនេះដែរ អ្វីៗដែលបាននិងកំពុងធ្វើឱ្យជីវិត និងការរស់នៅរបស់ពួកគេ កាន់តែមានភាពតឹង តែងនោះ គឺថា សព្វថ្ងៃនេះពួកគេបានក្លាយខ្លួនទៅជាកម្មករស៊ីឈ្នួលនៅលើទឹកដី ដែលជាកេរ្តិ៍ដំណែលដូនតារបស់ ខ្លួនឯងផ្ទាល់ទៅវិញ។

បន្ទាប់ពីក្រុមហ៊ុនទាំងឡាយបានធ្វើការឈូសឆាយដី និងព្រៃឈើទាំងនោះហើយ ពួកគេបានផ្តល់ ឱ្យអ្នកភូមិ ទាំងឡាយ នូវការងារក្នុងឋានៈជាកម្មករដំណាំចំការ កៅស៊ូរបស់ពួកគេ។

ប៉ុន្តែសំរាប់មនុស្សមួយចំនួនដូចជា ដូ សេក និងអ្នកដទៃទៀត ដែលរស់នៅក្នុងឃុំប៊ូស្រា ដែលគេស្គាល់ថា ទឹកធ្លាក់ពីរជាន់ប្រកបដោយទេសភាពដ៏ស្រស់បំព្រងនៃខេត្តមណ្ឌលគិរី ពួកគេសុខចិត្ត ប្រកបរបររកស៊ីដោយខ្លួនឯង ជាជាងធ្វើជាកម្មករស៊ីឈ្នួលក្រុមហ៊ុន។

ស្ត្រីជាម្តាយមានអាយុ ៤៣ ឆ្នាំ ដែលមានកូនចំនួន៨នាក់ បានត្អូញត្អែរថា "ចំពោះរូបខ្ញុំវិញ ខ្ញុំមិនអាចធ្វើការជាកម្មកររបស់ក្រុមហ៊ុនដែល មានច្បាប់តឹងតែងដូចនេះបានទេ ហើយខ្ញុំប្រាកដជាស្លាប់នៅក្នុងផ្ទះខ្ញុំហើយ "។

តាមរយៈការបកប្រែរបស់កូនស្រីគាត់ពីភាសា ជនជាតិដើមភាគតិចពូនងមកជាភាសាខ្មែរ គាត់និយាយថា" ក្នុងឋានៈជាកសិករឯករាជ្យ យើងអាចឈប់ សំរាកបាន នៅពេលណាយើងមានការនឿយហត់ " ។

ខាត់ ចន្ទី គឺជាកូនស្រីរបស់ ដូ សេក ដែលនាងមានអាយុ ២៧ ឆ្នាំ បាននិយាយថា ពីមុនមកនាងត្រូវគេជួល ធ្វើការបំរើឱ្យក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនចំការដំណាំកៅស៊ូផ្សេងៗ ។ ប៉ុន្តែនាងបាននិយាយថា បន្ទាប់ពីធ្វើការ បានមួយសប្តាហ៍នាងក៏សំរេចចិត្តឈប់ធ្វើការវិញ។

នាងបាននិយាយថា "ពួកយើងត្រូវភ្ញាក់នៅម៉ោង ៥ ព្រឹក ដើម្បីរៀបចំខ្លួនទៅធ្វើការ នៅម៉ោង ៦:៣០ នាទី "។

នាងបាននិយាយថា នាងបានធ្វើការ ៨ ម៉ោងក្នុងមួយថ្ងៃ ដើម្បីដាំកូនឈើកៅស៊ូ ប៉ុន្តែនាងបានត្អូញត្អែរថា រូបនាងមិនអាចស៊ូទ្រាំ ធ្វើការនៅក្រោមកំដៅព្រះអាទិត្យអស់រយៈពេលជាច្រើនម៉ោង ដោយមានឈប់សំរាក់ក្នុង រយៈពេលដ៏ខ្លីតែប៉ុណ្ណោះបានឡើយ។

ប្លឹង ស៊ីន ជាអ្នកជិតខាងរបស់ចន្ទី ដែលមានអាយុ ៥០ ឆ្នាំ បានសួរថែមទៀតទៅលើអ្វីដែលការអភិវឌ្ឍន៍ នេះអាចធ្វើបានដើម្បីបំរើឱ្យជនជាតិដើមភាគតិច ដែលក្រីក្រនៅក្នុងសហគមន៍នេះ។

គាត់បានពន្យល់ថា "ខ្ញុំយល់ហើយថាការអភិវឌ្ឍន៍ គឺដើម្បីកាត់បន្ថយនូវភាពក្រីក្រ ប៉ុន្តែប្រសិនបើ ការអភិវឌ្ឍន៍ធ្វើតែរបៀបនេះពួកគេមិនអាចកាត់បន្ថយភាពក្រីក្របាននោះទេ" ។

**"ពួកយើងត្រូវភ្ញាក់នៅម៉ោង ៥ ព្រឹក ដើម្បីរៀបចំខ្លួនទៅធ្វើការ នៅម៉ោង ៦:៣០ នាទី"... ស៊ូទ្រាំ ធ្វើការ នៅក្រោមកំដៅព្រះអាទិត្យអស់រយៈពេលជាច្រើនម៉ោង ដោយបានឈប់ សំរាក់ក្នុងរយៈពេលដ៏ខ្លីតែប៉ុណ្ណោះ**

អ្នកភូមិទាំងឡាយបាននិយាយថា ក្រុមហ៊ុនចំការកៅស៊ូ នៅខេត្តមណ្ឌលគីរី ក៏ដូចជាសម្បទានដី សេដ្ឋកិច្ចដទៃទៀតជាច្រើននៅទូទាំងប្រទេសកម្ពុជាដែរ ពួកគេគ្រាន់តែបានចូលមកដើម្បីកាប់ឆ្ការព្រៃនានា និងឈូសឆាយដីស្រែចំការ ដោយគ្មានការពិគ្រោះយោបល់ជាមួយសហគមន៍នៅតាមមូលដ្ឋានទេ ដូច្នោះ ហើយវាបង្កឱ្យមានជំលោះដីធ្លីជាទូទៅ។

ប្លឹង ស៊ីន បាននិយាយថា គាត់មិនគិតថា រដ្ឋាភិបាលមានបំណងចង់ដោះស្រាយបញ្ហាជំលោះដីធ្លីជាមួយ ក្រុមហ៊ុនទាំងឡាយនោះទេ។

គាត់បានពោលអះអាងថា "ប្រសិនបើពួកគេធ្វើ ពួកគេគួរតែបានដោះស្រាយបញ្ហាទាំងឡាយជាច្រើនឆ្នាំ កន្លងមកហើយ " ។

ចន្ទី បានបន្ថែមទៀតថា អាជ្ញាធរទាំងនោះបានប្រាប់នាង និងអ្នកភូមិទាំងឡាយឱ្យរងចាំនូវដំណោះស្រាយ ប៉ុន្តែនាងបាននិយាយថា ពួកខ្លួនបានរងចាំអស់រយៈពេលជាយូរមកហើយ ចាប់តាំងពីអាជ្ញាធរទាំងឡាយធ្លាប់ធ្វើការ សន្យាកាលពីខែ មករា ឆ្នាំ ២០០៩ មកម្ល៉េះ។

[១] *ជនជាតិដើមភាគតិចក្រុមនេះហៅជាភាសាខ្លួនឯងថា ពូ នង ដែលមានសំលេងស្រាលជាង និងតាមការពន្យល់នៅក្នុងសៀវភៅ ពូ នង នៅមណ្ឌលគីរី ២០០៥*

នាងបានសួរថា "ប្រសិនបើឥឡូវនេះយើងឃ្លានហើយ តើពួកយើងអាចរងចាំដល់សប្ដាហ៍ក្រោយយ៉ាងដូច ម្ដេចបានទៅ?" ។

ការអភិវឌ្ឍន៍មិនត្រឹមតែបានប៉ះពាល់ រួចមកហើយដល់ក្រពះអ្នកភូមិទាំងឡាយប៉ុណ្ណោះទេ ប៉ុន្តែវាបានធ្វើ ឱ្យមានរបួសយ៉ាងជ្រៅដល់ចិត្តគំនិត និងព្រលឹងរបស់ពួកគេផងដែរ។

> "ខ្ញុំយល់ហើយថាការអភិវឌ្ឍន៍ គឺដើម្បីកាត់ បន្ថយនូវភាពក្រីក្រ ប៉ុន្តែប្រសិនបើ ការអភិវឌ្ឍន៍ ធ្វើតែរបៀបនេះពួកគេមិន អាច កាត់បន្ថយភាពក្រីក្របាននោះទេ"

យោងតាមព័ត៌មានពីអ្នកភូមិបានឱ្យដឹងថា ដំណាំកៅស៊ូបានត្រូវគេដាំដុះនៅលើតំបន់ចំនួន ១០ នៃតំបន់ ពិសិដ្ឋទាំងឡាយរបស់ពួកគេ និងបានធ្វើឱ្យបាត់បង់ដីកប់ ខ្មោចដូនតារបស់ពួកគេចំនួន៦ផង ដែរ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់មកមានតែតំបន់តែមួយគត់ដែលបានប្រគល់ជូនទៅអ្នកភូមិវិញ។

"ពួកគេបានយកម៉ាស៊ីនឈូសឆាយដីកប់ខ្មោចនិង ដាំដើមកៅស៊ូនៅលើផ្នូរខ្មោចទាំងឡាយ" ដូ សេក បាន និយាយដោយរុញដៃទាំងពីររបស់ គាត់ទៅលើមេឃតាមរបៀបដែលមិនគួរឱ្យជឿបាន។

"ប្រសិនបើពួកគេនៅ តែបន្តការឈូសឆាយដីធ្លីតទៅទៀត វានឹងលែងមានកន្លែងស័ក្តសិទ្ធិដែល ត្រូវគោរព បូជាទៀតហើយ " ។



*រូបខាងស្តាំ: លោក ប្លាំង ស៊ីន អាយុ ៥០ឆ្នាំ រស់នៅក្នុងឃុំ ប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី : តើការអភិវឌ្ឍន៍ អាចធ្វើបានដើម្បីបំរើឱ្យជន ជាតិដើមភាគតិច ដែលក្រីក្រនៅក្នុងសហគមន៍នេះ?*

*រូបខាងក្រោម: លោកស្រី ដូ សេក អាយុ៤៣ឆ្នាំ រស់នៅក្នុងស្រុកពេជ្រាដា ខេត្ត មណ្ឌលគីរី : ខ្ញុំប្រាកដជាស្លាប់នៅក្នុងផ្ទះខ្ញុំ ហើយ។*



# ប្រឡាយទឹកបានប្រែក្លាយទៅជាប្រឡាយទឹកភ្នែក

## ពោធិសាត់



*ទីតាំងសំណង់ប្រឡាយទឹកចាប់ផ្តើមនៅក្នុង ឃុំឈើតុំ ដែលជាឃុំមួយក្នុងចំណោមឃុំ ដែលទទួលរងនូវផលប៉ះពាល់ដោយគំរោងនេះ ដែលធ្វើឡើងនៅក្នុងខេត្តកំពង់ឆ្នាំង និងពោធិសាត់*

**ករណី : ឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិសាត់**

<u>គម្រោង:</u> គម្រោងធារាសាស្ត្រត្រូវបានអនុវត្តដោយមន្ទីរគ្រប់គ្រងធនធានទឹក និងឧតុនិយម នៅក្នុងគម្រោង ធារាសាស្ត្រនេះ ប្រាក់កម្ចីបានមកពីធនាគារអភិវឌ្ឍន៍អាស៊ី ។

<u>សហគមន៍ដែលទទួលរងនូវផលប៉ះពាល់:</u> មានគ្រួសារចំនួន ៣៦ នៅក្នុងភូមិទួលត្បែង ឃុំឈើតុំ បានសម្រេច ចិត្តដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅកាន់មន្ទីរខេត្តពោធិសាត់។ ពួកគេបាននិយាយថា ពួកគេមិនទទួលបានដំណោះស្រាយណាមួយពីរដ្ឋាភិបាលឡើយ ។ ផ្ទះអ្នកភូមិជាច្រើន និងដើមឈើហូបផ្លែជារាប់រយត្រូវបានគេកំទេចចោល នៅក្នុងឃុំចំនួន ៧ ទូទាំងស្រុកក្រគរ ខេត្តពោធិសាត់ ។





*លោក អេង សំអាត អាយុ៥០ឆ្នាំ នៅ ឃុំឈើតុម ស្រុកក្រគរ ខេត្តពោធិសាត់: "ពួកគេមិនបានទាំងឱ្យដីបូលកៅស៊ូ មកខ្ញុំផង ហើយទុកសំណងការខូចខាត ធ្វើមិនដឹងមិនឮ"។*

ដោយអង្គុយនៅលើគ្រែឫស្សីក្រោមផ្ទះអ្នកជិតខាង អេង សំអាត ដែលមានអាយុ ៥០ ឆ្នាំ កែសំរួល យ៉ាងប្រុងប្រយ័ត្ន នូវជើង សិប្បនិម្មិតរបស់គាត់ ដែលភ្ជាប់ទៅនឹងជង្គង់ខាងស្តាំ ដើម្បីឱ្យវាត្រូវគ្នាបាន ល្អ។

គាត់សំឡឹងមើលទៅឆ្ងាយ ហើយរៀបរាប់អំពីការបញ្ជូនខ្លួនគាត់ទៅសមរភូមិប៉ៃលិននៅតាមព្រំដែនថៃ កាលពី ២៥ ឆ្នាំមុន ក្នុងឋានៈជាទាហានរបស់រដ្ឋាភិបាលដើម្បីប្រយុទ្ធជាមួយពួកខ្មែរក្រហម

គ្រាន់តែការប្រយុទ្ធបានចាប់ផ្តើមភ្លាម គាត់បានជាន់ទៅលើសត្រូវលាក់ខ្លួនមួយ គឺគ្រាប់មីន ដែលបាន បង្កប់នៅក្នុងដី ដោយពួកខ្មែរក្រហម។

ប៊ុម! មីនបានផ្ទុះឡើង។ វាមិនត្រឹមតែបានផ្ទុះបំបុិងជើងស្តាំរបស់គាត់តែប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំង បានប្រែក្លាយជីវិតរបស់គាត់ឱ្យចេញឆ្ងាយពីភាពជាមនុស្សម្នាធម្មតាម្នាក់ផងដែរ ប៉ុន្តែ អ៊ុំ សំអាត មិនបានចង់ស្លាប់ឡើយ ហើយថែមទាំងបានចាប់ផ្តើមកសាងដំណើរជីវិតដ៏សោកសៅរបស់គាត់ឡើងវិញ។

គាត់បានរស់នៅជាជនពិការអវៈយវៈដ៏សប្បាយរីករាយមួយរូបជាមួយនឹងប្រពន្ធ និងកូនៗរបស់គាត់ ដោយការរកស៊ីចិញ្ចឹមជីវិត ប្រកបមុខរបរតូចមួយ និងលក់ផ្លែឈើបេះបានពីដើមឈើ នៅជុំវិញផ្ទះគាត់ដែលស្ថិតនៅលើមាត់អូរមួយ។

ទោះបីយ៉ាងនេះក៏ដោយ គាត់បាននិយាយថា ជីវិតរបស់គាត់ត្រូវបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង នៅពេលមានគម្រោងធារាសាស្ត្រមួយ បានចាប់ផ្តើមធ្វើឡើងក្នុងភូមិរបស់គាត់ កាលពីបួនខែកន្លងទៅ។

ក៏ដូចគ្នាទៅនឹងផ្ទះដទៃទៀតដែលមានច្រើនជាង ៤០ ខ្នងនៅក្នុងឃុំឈើតុំ ស្រុកក្រគរ ខេត្តពោធិសាត់ ផ្ទះរបស់អ៊ុំ សំអាត មានទីតាំងស្ថិតនៅក្នុងតំបន់ប្រសព្វនៃគម្រោងធារាសាស្ត្រនោះ។

គាត់បានត្រូវគេប្រាប់ឱ្យរើចេញពីតំបន់នោះ។ បានត្រឹមតែបីថ្ងៃបន្ទាប់ពីការជូនដំណឹង ការឈូសឆាយ កំទេចបានត្រូវចាប់ផ្តើមធ្វើឡើង។ កម្មកររបស់ក្រុមហ៊ុនបានបើករថយន្តដឹកដី ម៉ាស៊ីនឈូសឆាយដី និងម៉ាស៊ីនចូកដីកផ្សេងៗ ទៅរំលំផ្ទះរបស់គាត់ហើយបានដកដើមឈើហូបផ្លែរបស់គាត់ចោលទាំងអស់។ ប៉ុន្តែអ្នកភូមិ ទាំងឡាយបាននិយាយថា ពួកគាត់មិនបានទទួលការពិគ្រោះយោបល់អំពីគម្រោងនេះទេ ដែលពួកគាត់ជឿថា វាស្ថិតនៅលើដីរបស់ពួកគាត់ ហើយក៏មិនបានត្រូវគេផ្តល់ដីឡូតិ៍ណាមួយផ្សេងទៀតជាថ្នូរផងដែរ។

អ៊ុំ សំអាត និយាយថា "ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង នៅពេលខ្ញុំបាន ឮសំឡេងគ្រឿងចក្រដែលដូចជាសន្ទឹកផ្គរលាន់ កំពុងរំកិលចូលមក"។

ឥឡូវនេះ សញ្ញាខាងក្រៅនៃភាពក្រខ្សត់អាចត្រូវគេមើលឃើញថា វាកំពុងតែលាតសន្ធឹងតាមភូមិនានា ដែលជាទីតាំងរបស់ផ្ទះអ្នកភូមិទាំងនោះតាំងនៅ។

ដោយមិនបានចេញសំណងឱ្យគឺបាត់បង់អ្វីៗទាំងអស់ សំអាត និយាយថា គាត់មិនចង់រស់នៅតទៅទៀតទេ ។

ដោយរំជួលចិត្តយ៉ាងខ្លាំងពីការបាត់បង់ផ្ទះសំបែង និងរបរចិញ្ចឹមជីវិត គាត់និយាយថា "រូបខ្ញុំបានដេក ទទឹងផ្លូវ ដើម្បីឱ្យរថយន្តដឹកទំនិញកិនខ្ញុំ " ។

គាត់និយាយថា "ខ្ញុំបានសន្សំប្រាក់ចាប់តាំងពីឆ្នាំ ១៩៧៩ មកដើម្បីសង់ផ្ទះនោះ" រហូតដល់ ៥ ឆ្នាំកន្លង មកនេះ នៅពេល ដែលទីបំផុតមានប្រាក់គ្រប់គ្រាន់ដើម្បីចំណាយលើថ្លៃសាងសង់ ។

គាត់ត្អូញត្អែរទាំងកំហឹងថា "ពួកគេមិនបានទាំងឱ្យដីបូលកៅស៊ូ មកខ្ញុំផង ហើយទុកសំណងការខូចខាត ធ្វើមិនដឹងមិនឮ"។

លោក សំអាត និយាយថា គាត់ចំណាយអស់ ៧000 ដុល្លា ដើម្បីសាងសង់ផ្ទះថ្មមួយដែលមានទំហំ ៥ ម៉ែត្រ គុណនឹង ៦ ម៉ែត្រ ដែលព័ទ្ធជុំវិញទៅដោយដើមខ្នុរ ៣0ដើម ដើមដូង និងដើមឈើ ហូបផ្លែផ្សេងៗផងដែរ ។

គាត់និយាយថា "ផ្ទះរបស់ខ្ញុំមានភាពត្រជាក់ត្រជុំហើយមិនរហេមរហាមដូចនេះទេ"។

ក្នុងខណៈដែលការពិភាក្សាបានកន្លងទៅ គ្រួសារដទៃទៀតដែលទទួលរងផលប៉ះពាល់បានចូលរួម ហើយ រៀបរាប់នូវរឿងរ៉ាវស្រដៀងគ្នានេះផងដែរ ។

អ្នកស្រីញែម យិន មានអាយុ ៥0 ឆ្នាំ ដែលមកពីភូមិ ទួលត្បែងដូចសំអាតផងដែរ បាននិយាយថា អ្នកស្រីបានបាត់បង់ផ្ទះឈើដែលមានទំហំ ៤ ម៉ែត្រ គុណ ៨ ម៉ែត្រ រួមជាមួយនឹងខ្នុរ ៨ ដើម និងដូង ៥ ដើមផងដែរ ។

ហើយបន្ទាប់មកទៀត ដីធ្លីទាំងអស់របស់គាត់ត្រូវបានលេបត្របាក់ដោយគំរោងប្រព័ន្ធធារាសាស្ត្រនេះ ។ អ្នកស្រីយិននិយាយថា អ្នកស្រីត្រូវសុំទៅអ្នកជិតខាងដើម្បីសាងសង់ខ្ទមស្លឹកមួយនៅលើដីរបស់ពួកគេ។

# "ពួកគេមិនបាន ទាំងឱ្យដំបូលកៅស៊ូ មកខ្ញុំផង ហើយទុកសំណងការខូចខាត ធ្វើមិនដឹងមិនឮ"

បងស្រីអ្នកស្រីឃឹម ឈ្មោះ ញែម យ៉ឹម ដែលមានអាយុ ៦០ ឆ្នាំ គាត់មានសំណាងជាងពីព្រោះថាគាត់អាចរុញផ្ទះរបស់គាត់ទៅដីកៀនជ្រុង ប៉ុន្តែគាត់និយាយថា គាត់នៅតែបានបាត់បង់ដីដែលនៅសេសសល់ ជាដដែលទេ ។

គាត់និយាយថា "ឥឡូវនេះ ដើមខ្នុរ ដើមដូង និងដើមស្វាយទាំងឡាយរបស់គាត់បានបាត់បង់អស់រលីងហើយ ហើយសូម្បីតែដីសំរាប់ដាំផ្កាក៏គាត់មិនមានផងដែរសព្វថ្ងៃនេះ"។

អ្នកស្រីយ៉ឹមនិយាយថា ប្រសិនបើគេធ្វើការពង្រីកផ្លូវគាត់នឹងបាត់បង់ដីធ្លី និងផ្ទះរបស់គាត់ទាំងអស់ ហើយគាត់បានបន្ថែមទៀតថា "ខ្ញុំមិន ដឹងជាទៅរស់នៅទីណានោះទេ"។

បើទោះបីជាមានការតវ៉ារបស់ពួកគាត់យ៉ាងណាក៏ដោយ ក៏អ្នកភូមិបាននិយាយថា អាជ្ញាធរមូលដ្ឋាន មិនបានអើពើអំពីការបាត់បង់ និង សេចក្តីឈឺចាប់របស់ពួកគេនោះឡើយ។

អ្នកស្រីយិនបានរំឮកពាក្យខ្មែរមួយឃ្លាដែលមន្ត្រីជាន់–ខ្ពស់ម្នាក់ មកពីស្រុកក្រគរ បាននិយាយ ក្នុងដំណើរ ទស្សនកិច្ចរយៈពេលខ្លីទៅកាន់ឃុំដែលទទួលរងការប៉ះពាល់ដូច្នេះថា "ក្បួនទូរចរចេះតែធ្វើដំណើរទៅមុខចំណែក ឯ ឆ្កែចេះតែព្រុស" ។

អ្នកស្រីយ៉ឹម ឆ្លើយតបទាំងខឹងសម្បារយ៉ាងខ្លាំងថា "តើពួកគេអីក៏ព្រហើនម្ល៉េះ ហ៊ានប្រៀបធៀបពួកយើងទៅនឹងសត្វឆ្កែផង ?"។

ឥឡូវនេះ អ្នកភូមិទាំងឡាយ កំពុងគ្រោងរៀបចំនាំយកពាក្យបណ្តឹងរបស់ខ្លួន ទៅកាន់អាជ្ញាធរ ស្រុកដើម្បីទាមទារ សំណង ការខូច–ខាត ចំពោះការបំផ្លិច បំផ្លាញផ្ទះ សំបែង និងទ្រព្យសម្បត្តិរបស់ពួក គាត់។

នៅពេលដែលសួរថា តើពួកគាត់នឹងទទួលបានជោគជ័យដែរឬទេ ? ពួកគាត់ឆ្លើយតបដោយគ្រវីក្បាល ព្រមៗគ្នាថា "ពួកយើងពុំមានក្តីសង្ឃឹមណាមួយឡើយថា ពួកគេនឹងសងការខូចខាតដល់ពួកយើងនោះ " ។



*កម្មករកំពុងធ្វើការ នៅក្នុងការដ្ឋានគំរោងប្រឡាយទឹក ក្នុងឃុំឈើតុំ។ ប្រឡាយធម្មជាតិដែលធ្លាប់មានហូរ នៅក្នុងឃុំ ត្រូវរលាយបាត់ជាមួយនឹងផ្ទះសម្បែងរបស់អ្នកភូមិ។*



*ផ្ទះរបស់លោក សំអាត ដែលត្រូវបានឈូសកំទេចចោលដោយ ម៉ាស៊ីនឈូសដី និង ម៉ាស៊ីនកាយដី របស់ក្រុមហ៊ុន*

# លើកផ្លាកជំនួសទីងមោងដើម្បីបង្អើលអ្នកដណ្តើមយកដីធ្លី

## កោះកុង



*សារត្រូវបានគេសសេរឡើងនៅលើផ្ទាំងការ៉ុង ដើម្បីស្វែងរកជំនួយពីសម្តេចតេជោហ៊ុនសែន*

**ករណី : ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង**

<u>សម្បទាន:</u> ផ្តល់ឱ្យចំការដំណាំអំពៅ និងរោងចក្រផលិតស្ករស ។

<u>កាលបរិច្ឆេទ ទំហំ និងក្រុមហ៊ុន:</u> សម្បទានដីសេដ្ឋកិច្ចចំនួនពីរបានត្រូវគេផ្តល់នៅក្នុងឆ្នាំ ២០០៦ សម្រាប់ដីទំហំ ចំនួន ៩.៧០០ ហិចតា និង ៩.៤០០ ហិចតា ទៅឱ្យក្រុមហ៊ុន ឧស្សាហកម្មស្ករសកោះកុង និងក្រុមហ៊ុនចំការដំណាំ កោះកុង ដែល ជាកម្មសិទ្ធិរបស់សមាជិកព្រឹទ្ធសភាគណៈបក្សប្រជាជន លី យ៉ុងផាត់ (Ly Yong Phat) និងដៃគូ បរទេសនៅក្នុងប្រទេសថៃ និងតៃវ៉ាន់ ។

<u>សហគមន៍ដែលទទួលរងផលប៉ះពាល់:</u> មានប្រជាជនប្រមាណ ៤០០គ្រួសារដែលបាន បាត់បង់ផ្ទៃដីចំនួន ២.០០០ ហិចតា ដោយសារដីសម្បទានសេដ្ឋកិច្ច ។

<u>ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើង:</u>

<u>បច្ចុប្បន្នភាព:</u> ព្រះរាជអាជ្ញាខេត្តកោះកុងមិនបានចាត់ការពាក្យបណ្តឹងដែលអ្នកភូមិនៅក្នុងស្រុកស្រែអំបិល បានចោទប្រកាន់ក្រុមហ៊ុនរបស់សមាជិកព្រឹទ្ធសភាគណៈបក្សប្រជាជនពីបទសម្លាប់ពាហនៈរបស់ពួកគេនោះទេ។



ក្នុងខណៈដែលអ្នកធ្វើដំណើរទាំងឡាយ ធ្វើដំណើរឆ្លងកាត់ភូមិព្រៃនប់តាមបណ្តោយផ្លូវជាតិលេខ ៤ ឆ្ពោះទៅកាន់ខេត្តព្រះស៊ីហនុ អ្នកធ្វើដំណើរខ្លះអាចនឹងភ្ញាក់ផ្អើលដោយឃើញទីងមោង ដែលគេបានដាក់ចំពីមុខផ្ទះប្រជាជនមួយចំនួន ។

អ្នកភូមិមានជំនឿថា ទីងមោងអាចបង្អើលសំណាងមិនល្អ ឬជម្ងឺដំកាត់ ដែលបង្ករឡើងដោយព្រលឹងបីសាចផ្សេងៗ ។

ទោះជាយ៉ាងណាក៏ដោយ ចំពោះអ្នកទាំងឡាយនោះ ដែលមិនបានធ្វើដំណើរទៅកាន់ទីក្រុងដែលស្ថិតនៅមាត់សមុទ្រនៃខេត្តព្រះសីហនុ ហើយបត់ឆ្វេងធ្វើដំណើរតាមបណ្តោយផ្លូវលេខ ៤៨ តំរង់ឆ្ពោះទៅកាន់ខេត្តកោះកុងវិញ ពួកគេនឹងប្រទះឃើញអ្វីមួយ ដែលខុសប្លែកទៅវិញនៅចំពីមុខផ្ទះប្រជាជន នានា នៅពេលដែលពួកគេឆ្លងកាត់ ឃុំជីខលើ ស្រុកស្រែអំបិល ។

នៅទីនោះ អ្នកភូមិនានាបានព្យួរផ្លាកទាំងតូច ទាំងធំ នៅតាមរបងផ្ទះរបស់ពួកគេ ដើម្បីសំដែងការឈឺចាប់របស់ពួកគេ និងបង្អើលអ្នកអភិវឌ្ឍន៍ទាំងឡាយ ដែលនិយាយថា បានយកដីស្រែចំការ របស់ពួកគេឱ្យចាកចេញឆ្ងាយ ។

មានផ្លាកមួយផ្ទាំងបានសរសេរថា "ខ្ញុំបានបាត់បង់ដីចំនួន ១៥ ហិចតា ដោយសារ ក្រុមហ៊ុន លីយ៉ុងផាត់ បានឈូសឆាយដីធ្លីរបស់ខ្ញុំ ហើយបានប្រែក្លាយវា ទៅជាចំការដំណាំអំពៅ សូម សម្តេច ហ៊ុន សែន មេត្តាជួយដល់ខ្ញុំផង"។

មានផ្លាកសញ្ញាខ្លះទៀតប្រើប្រាស់កំណាព្យ ជាភាសាខ្មែរ ដែល ជាបំណងរបស់អ្នកភូមិដើម្បីធ្វើឱ្យ ការតវ៉ារបស់ពួកគេកាន់តែមានការចាប់អារម្មណ៍ថែមទៀត ។

ផ្លាកមួយបានសរសេរថា "អ្នកដឹកនាំល្អនឹងធ្វើឱ្យប្រជាជនមានបាន រីឯអ្នកដឹកនាំលោភលន់នឹងធ្វើឱ្យប្រជាជនក្រខ្សត់" ដោយបានចោទ ប្រកាន់ផងដែរដល់ក្រុមហ៊ុនលីយ៉ុងផាត់ពីបទ "ចោរបំផ្លិចបំផ្លាញម្នាក់ ដែលបានលួចប្លន់ដីធ្លីទាំងអស់របស់ពួក យើង"។

ចាប់តាំងពីជម្លោះបានកើតឡើងនៅឆ្នាំ ២០០៦ មក ភឿង ណាត ដែលមានអាយុ ៦២ ឆ្នាំ បាននិយាយថា អ៊ុំស្រី បានធ្វើផ្លាកអស់ពី ៧ ទៅ ៨ ផ្លាករួចមកហើយ ព្រមទាំងបានធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ អស់ចំនួន ៦ លើក ដើម្បីអំពាវនាវដល់រដ្ឋាភិបាលឱ្យជួយផងដែរ ។

គាត់បាននិយាយថា "ពួកយើងចេះតែបន្តការតវ៉ាប្រឆាំងតែ ប៉ុណ្ណោះ ប៉ុន្តែពួកយើងមិនដឹងថាតើពួកគេនឹងប្រគល់ដីឱ្យយើងវិញឬអត់ នោះទេ"។



*អ៊ុំស្រី ណាត បានលក់ដីរបស់គាត់ទាំង១៤ហិចតា*
*ហើយបែរមកធ្វើស្រែលើដីមួយដុំ តូចវិញ*

អ៊ុំស្រី ណាត ដែលបានបាត់បង់ដីចំនួន ១៤ ហិចតា ដោយសារក្រុមហ៊ុន បានថ្លែងថា វាគឺជាការតស៊ូ មួយប្រកបដោយការឈឺចាប់បំផុត ដែលដីរបស់ខ្លួនត្រូវដណ្តើមយកដោយពាណិជ្ជករដ៏មានអំណាចម្នាក់ ដែលជាសមាជិកព្រឹទ្ធសភាម្នាក់របស់គណបក្សប្រជាជនផងដែរ។

គាត់បានត្អូញត្អែរថា "ពួកយើងគឺជាអ្នកក្រីក្រ និងល្ងង់ខ្លៅ។ ពួកយើងគឺជាមនុស្សតូចតាច ហើយបានសាកល្បងយកក្បាលរបស់ពួកយើងទៅទង្គិចនឹងភ្នំ"។

គាត់បាននិយាយបន្ថែមទៀតថា "ដោយគ្រាន់តែធ្វើស្រែចំការលើដីតិចតួចដូច្នោះ ខ្ញុំហូបមិនគ្រប់គ្រាន់ទេ" ។

គាត់បានបន្តទៀតថា "ពួកយើងមិនចង់ទៅរស់នៅក្នុងភូមិគ្រឹះនៅកន្លែងណាផ្សេងទៀតទេ ពួកយើង គ្រាន់តែស្នើសុំពួកគេទុកឱ្យយើងរស់នៅទីនេះតែប៉ុណ្ណោះបានហើយ" ។

ប៉ុន្តែ សំរាប់អ្នកភូមិនៅក្នុងឃុំជីខ វាមិនត្រឹមតែមនុស្សទេដែលយល់ឃើញថាមានការលំបាកក្នុងការរស់នៅនោះ វាមានការលំបាកសំរាប់សត្វផងដែរ ។

ម៉ុក ជ័យ ដែលមានអាយុ ៥៦ ឆ្នាំ មកពីភូមិឆ្វ នៅក្នុងឃុំដូចគ្នានេះ បាននិយាយថា "ពួកគេមិន គ្រាន់តែយកដីធ្លីរបស់ខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងបានបាញ់សម្លាប់ក្របីខ្ញុំអស់បីក្បាលទៀតផងដែរ"។

មឹងជ័យ ដែលបានបាត់បង់ដីទាំង អស់របស់គាត់ចំនួន ៣ ហិចតា បាននិយាយថា ទាហានទាំងឡាយរបស់ ក្រុមហ៊ុនដែលយាមការពារចំការ ដំណាំអំពៅបានបាញ់ សត្វពាហនៈណាដែលបានដើរចូលទៅក្នុងបរិវេណក្រុមហ៊ុននោះ ។

គាត់បាននិយាយថា "តុលាការបាននិយាយថាគ្មានភស្តុតាង ហើយខ្ញុំខឹងសម្បារជាខ្លាំង" ។

ភឿង ណាត បានសម្រេចចិត្តបោះបង់ចោលសត្វពាហនៈ ដែលគាត់បានទិញពីលើកមុន ដូច្នេះការខកខានរបស់តុលាការក្នុងការស្វែងរកភស្តុតាង គឺមិនមានជាបញ្ហាថាតើសត្វគោ ឬក្របីទាំងឡាយ របស់គាត់ត្រូវ បានគេសម្លាប់ឡើយ ។

អ៊ុំស្រីបានបន្ថែមថា "ខ្ញុំបានលក់គោ និងក្របីទាំងអស់របស់ខ្ញុំ ពីព្រោះវាគ្មានកន្លែងសំរាប់ឱ្យពួកវាស៊ី ស្មៅទៀតទេ"។

នៅមានបញ្ហាធ្ងន់ធ្ងរជាងនេះទៅទៀតគឺថា យ៉ាងហោចណាស់អ្នកភូមិពីរនាក់មិនត្រឹមតែបានបាត់បង់ដីធ្លី និងសត្វពាហនៈតែប៉ុណ្ណោះទេ

ប៉ុន្តែថែមទាំងបានបាត់បង់នូវជីវិតផ្ទាល់ខ្លួនរបស់ពួកគេទៀតផងដែរ ។

លោក អេត សុខ ដែលមានអាយុ ៤០ ឆ្នាំ បាននិយាយថា ប្រពន្ធរបស់គាត់ដែលទើបតែឆ្លងទន្លេរួច បានស្លាប់នៅថ្ងៃដែលរូបនាងបានទៅមើលដីរបស់ខ្លួន ដែលត្រូវបានក្រុម – ហ៊ុនធ្វើការឈូសឆាយរួច ហើយ។

សុខ បានជឿជាក់ថា ប្រពន្ធខ្លួនបានរន្ធត់ចិត្តជាខ្លាំង ដោយបានឃើញការ បំផ្លិចបំផ្លាញដីស្រែចំការរបស់នាងរហូត ដល់នាងធ្លាក់ខ្លួនឈឺ ហើយបណ្តាលឱ្យលាប់ស្លាប់ភ្លាមៗ ។

អាន អ៊ីន ជាអ្នកជិតខាងសុខ គឺជាអ្នកធ្វើការតវ៉ាម្នាក់និយាយឥតសំចៃ ដែលបានព្យាយាមថតយករូប–ភាពគ្រឿងចក្រឈូសឆាយដែលកំពុងបំផ្លិចបំផ្លាញដីរបស់អ្នកភូមិ ត្រូវបានកាប់រហូតដល់ស្លាប់ ដោយជន មិនស្គាល់មុខម្នាក់ ។

> "ពួកគេបានសម្លាប់គាត់ដើម្បីបំបិទភស្តុតាង ប្រសិនបើតុលាការមានភាពឯករាជ្យ ពួកគេពិតជា អាចរកយុត្តិធម៌ឱ្យរូបខ្ញុំជាមិនខានឡើយ"

អាន លឿង ដែលមានអាយុ ៦១ ឆ្នាំ គឺជាបងប្រុសរបស់ អាន អ៊ីន បាន និយាយថា ការសម្លាប់ប្អូនប្រុសពៅរបស់គាត់ ពិតជាជាប់ទាក់ទីនទៅ នឹងសេចក្តីក្លាហានរបស់អាន អ៊ីន ដែលដើរតួក្នុងការតវ៉ា ។

លឿងបាននិយាយថា "ពួកគេបានសម្លាប់គាត់ដើម្បីបំបិទភស្តុតាង ប្រសិនបើតុលាការមានភាពឯករាជ្យ ពួកគេពិតជាអាចរកយុត្តិធម៌ឱ្យរូបខ្ញុំជាមិនខានឡើយ" ។

លឿង បាននិយាយថា ការស្លាប់របស់ប្អូនប្រុសគាត់បានកាត់បន្ថយចំនួនសមាជិកគ្រួសាររបស់គាត់ពី ៧ នាក់ មកត្រឹម ២ នាក់តែប៉ុណ្ណោះ។ បងប្អូនប្រុស ស្រីរបស់គាត់ចំនួន ៤ នាក់ទៀត ត្រូវបានគេសម្លាប់ ដោយពួកខ្មែរក្រហមនៅក្នុងរជ្ជកាលដ៏ភ័យរន្ធត់ ។

សព្វថ្ងៃនេះ គាត់បាននិយាយថា ប្អូនស្រីតែមួយគាត់របស់គាត់បានបាត់បង់ដីធ្លីរបស់នាងអស់ ហើយបានធ្វើការផ្លាស់ប្តូរទីលំនៅទៅរស់នៅក្នុងខេត្តពោធិ៍សាត់ ជាទីកន្លែងដែលនាងបានព្យាយាមរកស៊ីចិញ្ចឹមជីវិតដោយការនេសាទត្រី ចំណែកឯ លឿង វិញ បានព្យាយាមតស៊ូ រស់នៅតទៅទៀត ជាមួយនឹងដីមួយភាគប្អូនហិចតារបស់ខ្លួន ដែលនៅ សេសសល់ ។

គាត់បាននិយាយថា "ខ្ញុំមានមនុស្ស ៨ នាក់នៅក្នុងផ្ទះ ហើយពួកយើងមានតែស្រូវ ៧ ថាំង តែប៉ុណ្ណោះ ដែលបានច្រូតកាត់ពីដី មួយដុំតូច"។

ដោយបានចង្អុលទៅកាន់ចំការដំណាំអំពៅដែលពីមុនមកដីគាត់ ស្ថិតនៅទីនោះ គាត់បានបន្តទៀត ថា "ពីមុនមក ពួកយើងមានដីស្រែចំការ (ដែលក្រុមហ៊ុនបានដណ្តើមយក) ពួកយើងមានហូបគ្រប់គ្រាន់"។

ដោយហេតុថាក្តីសង្ឃឹមរបស់ពួកគេក្នុងការទាមទារដីធ្លីត្រឡប់មកវិញបានអន់ថយ អ្នកភូមិទាំង នេះនឹងបន្តព្យួរផ្លាកតវ៉ារបស់ពួកគេ ដោយក្តីសង្ឃឹមថា នៅថ្ងៃណាមួយ មានអ្នកណាម្នាក់គេនឹងយកចិត្តទុកដាក់ក្នុងរឿងនេះជាមិនខានឡើយ ។




*ផ្ទាំងបដា ចង្អុលបង្ហាញទិសដៅទៅកាន់ទីតាំងក្រុមហ៊ុន ចំការដំណាំ កោះកុង ដែលត្រូវបានគេដាក់នៅលើចិញ្ចើមផ្លូវហាយវេថ្មីឆ្ពោះទៅកាន់ខេត្តកោះកុង*

# ក្នុងខណៈពេលដែលភ្លៀងចាប់ផ្ដើមធ្លាក់ ទឹកភ្នែករបស់អ្នកភូមិក៏ចាប់ផ្ដើមហូរដែរ

## សៀមរាប



*ប្រយុទ្ធប្រឆាំងទៅនឹងភាពភ័យខ្លាចអាជ្ញាធរដែនដី ប្រជាជនបាននាំគ្នាប្រជុំស្ងាត់ៗ ដើម្បីពិភាក្សាពីស្ថានភាព ឪពុក ប្ដី បង-ប្អូន ប្រុស របស់ពួកគាត់ដែលបានជាប់ពន្ធនាគារ និងរិះរកមធ្យោបាយដើម្បីឱ្យគេដោះលែងពួកគេមកវិញ។*

**ករណី : ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប**

ជម្លោះ: ជម្លោះទៅលើផ្ទៃដីចំនួន ៤៧៥ ហិចតា រវាងប្រជាជនចំនួន ១៧៥ គ្រួសារ និងពាណិជ្ជករក្នុងស្រុក ដែលមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយមន្ត្រីស្រុក និងមន្ត្រីខេត្ត ។

ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើង:

បច្ចុប្បន្ននេះ អ្នកភូមិទាំងឡាយបានសុំ យ៉ាងហោចណាស់ផ្ទៃដីចំនួន ១00 ហិចតានៃដីស្រែប្រាំងរបស់ពួកគេ ត្រូវប្រគល់ជូនទៅពួកគេវិញ ។

-អាជ្ញាធរបានបដិសេធន៍នូវសំណើសុំនេះដោយពួកគេបាននិយាយថា សព្វថ្ងៃនេះវា គឺជាដីព្រៃដែលត្រូវបានរក្សាធ្វើជាជម្រកត្រីពង ថ្វីបើអ្នកភូមិទាំងឡាយបានអះអាងថា ពួកគាត់បានបន្តធ្វើស្រែនៅលើដីស្រែនោះ ក៏ដោយ ។



ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ អ្នកភូមិនៅទូទាំងឃុំជីក្រែង ជាញឹកញាប់តែងតែ បានឮសូរនូវ ភ្លេងប្រពៃណីខ្មែរដ៏លាន់រំពងពីប្រដាប់បំពងសំលេង ក្នុងខណៈពេល ដែលឪពុកម្តាយ ធ្វើពីធី រៀបអាពាហ៍ពិពាហ៍ឱ្យដល់កូន ប្រុស – ស្រីរបស់ខ្លួន ។

ក៏ប៉ុន្តែ មានអ្វីមួយដែលកំពុងតែបានបាត់បង់។ សំឡេងតាអាចារ្យខាងព្រះពុទ្ធសាសនាដ៏ល្បីមួយរូប ដែលជាធម្មតាត្រូវគេអញ្ជើញឱ្យធ្វើជាអ្នកចាត់ចែងរៀបចំពិធីមង្គលការផ្សេងៗ លែងត្រូវបានគេស្តាប់ឮតទៅទៀតហើយ។

បើរាប់ទៅអស់រយៈពេល ៣៦៥ ថ្ងៃហើយដែលលោកតាអាចារ្យ សឹម លាភ ដែលមានអាយុ ៦២ ឆ្នាំ ត្រូវបានគេដាក់ក្នុងពន្ធនាគារក្រុងសៀមរាប។ គាត់បានត្រូវចាប់ខ្លួន និងចោទប្រកាន់ពីបទ "បង្ខាំងមនុស្សដោយខុសច្បាប់" ក្រោយពេលកើតមានប្បត្តិ ហេតុមួយ ដែលក្នុងពេលនោះ លោកតា លាភ និងអ្នកភូមិផ្សេងទៀតជាច្រើននាក់បានឡោមព័ទ្ធជនរំលោភបំពានពីររូប ដែលបានលុកលុយចូលមកធ្វើ ស្រែលើដីស្រែ របស់អ្នកភូមិ ក្នុងគោលបំណងឃាត់ខ្លួន ពួកគេទុករង់ចាំប៉ូលីសមកដល់។

ទោះបីជាយ៉ាងណាក៏ដោយ លោកតា លាភ មិនមែនជាកសិករតែម្នាក់ទេ ដែលត្រូវចាប់ខ្លួននិងបញ្ជូនទៅ ពន្ធនាគារនោះ។

ក្នុងខែ មីនា ឆ្នាំ ២០០៩ កសិករទាំងឡាយនៅភូមិជីក្រែង បាន



*កិច្ចប្រជុំស្ងាត់ៗ បានធ្វើឡើងនៅក្រោមផ្ទះរបស់តំណាងសហគមន៍*

កំពុងច្រូតកាត់ផលស្រូវរបស់ពួកគាត់ ខណៈពេលដែលមានមន្ត្រីនគរបាលច្រើនជាង ១០០ នាក់ បានឆ្មក់ចូលទៅក្នុងវាលស្រែរបស់ពួកគាត់ ហើយបានបាញ់ប្រហារ ទៅលើកសិករជាច្រើន ដែលគ្មានអាវុធ ដោយធ្វើឱ្យគ្នាគាត់ ៤ នាក់ទទួលរងរបួសផងដែរ។

អ្នកភូមិទាំងនោះបាននិយាយថា ពួកគាត់បានធ្វើស្រែនៅលើដីនោះអស់រយៈពេលជាច្រើនឆ្នាំក្នុងអំឡុង ទសវត្សឆ្នាំ ១៩៨០។ ពួកគាត់បាននិយាយទៀតថា បន្ទាប់ពីពួកគាត់បានបោះបង់ដីស្រែរបស់ខ្លួន ស្ទើរតែពីរទសវត្សរួចមក ពួកគាត់ក៏ចាប់ផ្តើមបន្តធ្វើស្រែឡើងវិញនៅលើដីចាស់នោះក្នុងឆ្នាំ ២០០៥ ។

ការវាយឆ្មក់របស់ក្រុមនគរបាល បានត្រូវធ្វើឡើងដើម្បីបញ្ឈប់អ្នកភូមិកុំឱ្យច្រូតកាត់ផលស្រូវរបស់ពួក គាត់នៅលើដីជម្លោះ។ ជាផ្នែកមួយនៃការវាយឆ្មក់នេះ មានកសិករចំនួន ៤៦ នាក់ បានត្រូវចាប់ខ្លួន ហើយត្រូវបោះ ចូលទៅក្នុងរថយន្តត្រាក់ទ័រ ដោយដៃទាំងពីររបស់ពួកគេត្រូវជាប់ចំណងចងភ្ជាប់ទៅខាងក្រោយខ្នង។

ខណៈពេល ដែលមនុស្សភាគច្រើនបានត្រូវដោះលែងមកវិញក្នុងរយៈពេលដ៏ខ្លីបន្ទាប់ពីការចាប់ខ្លួនមក បុរសចំនួន ៩ នាក់ ដោយរួមបញ្ចូលទាំង លោកតា លាភ ផងបានត្រូវគេបញ្ជូនទៅកាន់ពន្ធនាគារ ហើយ

"ពួកយើងមិនមាននរណាម្នាក់ជួយរកស៊ុចិញ្ចឹមជីវិតឡើយ"..."ពួកយើងមិនមានសេសសល់ដីទាល់តែសោះ ពីព្រោះពួកគេបានដកហូត យកដីរបស់ពួកយើងអស់ហើយ"

ត្រូវនៅជាប់ឃុំឃាំងចាប់តាំងពីពេលនោះមក។

ស្ថិតនៅក្នុងសភាពធ្លាក់ខ្លួនឈឺ ហើយស្លេកស្លាំង និងមានស្នាមក្រហមមូលៗនៅជាប់នឹងថ្ងាស ដោយសារការជប់ខ្យល់ ដែលជាការអនុវត្តតាមប្រពៃណីប្រើសម្រាប់ព្យាបាលជំងឺ ភរិយារបស់លោកតា លាភ គឺលោក យាយ ណន់ ហឿង ដែលមានអាយុ ៥៦ ឆ្នាំ បានមានប្រសាសន៍ថា ជីវិតរបស់លោកយាយ ស្ថិតនៅក្នុងស្ថានភាពមិនប្រាកដប្រជា ចាប់តាំងពីមានការចាប់ខ្លួនប្តីរបស់លោកយាយមក ។

គាត់និយាយបន្ថែមទៀតថា "ពួកយើងមិនមាននរណាម្នាក់ជួយរកស៊ុចិញ្ចឹមជីវិតឡើយ"។ ហើយប្តីរបស់ លោកយាយ គឺជាអ្នករកស៊ុចិញ្ចឹមគ្រួសារទាំងមូល។

លោកយាយបានបន្តទៀតថា "ពួកយើងមិនមានសេសសល់ដីទាល់តែសោះ ពីព្រោះពួកគេបានដកហូត យកដីរបស់ពួកយើងអស់ហើយ"។ ទាំងនេះបានបង្ខំឱ្យលោកយាយ និងអ្នកភូមិ ផ្សេងៗទៀត ត្រូវទៅធ្វើការជាកម្មករស៊ុឈ្នួលគេ ដើម្បីរកបានប្រាក់ចំណូលដ៏ស្តួចស្តើង។

លោកយាយ ហឿង បាននិយាយទៀតថា ជាមួយនឹងប្រាក់ដែលរកបានគាត់បានធ្វើដំណើរបានបី–បួនដងទៅក្រុងសៀមរាបដើម្បីទៅមើលប្តីគាត់ ។

គាត់បានត្អូញត្អែរថា ប្ដីរបស់គាត់ធ្លាក់ខ្លួនឈឺដោយសារជំងឺលើសឈាម និងមិនបានហូបចុកគ្រប់គ្រាន់។

លោកយាយមានប្រសាសន៍ថា "គាត់គ្រាន់តែបានហូបបបរសតែប៉ុណ្ណោះ ពីព្រោះគាត់មិនអាចហូបម្ហូបរឹងៗបាននោះទេ ។ ខ្ញុំចង់តែស្រែកយំទេ"។

លោកយាយ ហឿង បាននិយាយទៀតថា ក្រៅពីការបាត់បង់ដីស្រែរបស់ពួកគាត់ ពួកនគរបាល ក៏បាន "លួច" លុយចំនួន ១,៥០០ ដុល្លារ និង លុយខ្មែរចំនួន ៣ លាន ៥ សែន រៀលផងដែរ ដែលគ្រួសារគាត់ បានសន្សំទុក អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។

អ្នកភូមិផ្សេងៗទៀតដែលមានញាតិសន្តានត្រូវចាប់ខ្លួននិងដាក់ ក្នុងពន្ធនាគារក៏បានទទួលរងទុក្ខវេទនា ស្រដៀងៗគ្នា នះផងដែរ។

អ្នកភូមិដែលរស់នៅជិតខាងជាមួយលោកយាយ ហឿង គឺអ្នកស្រី ល័ក្ខ ញាញ់ ដែលមានអាយុ៣០ ឆ្នាំ បាននិយាយថា អ្នកស្រីកំពុងមានផ្ទៃពោះពីរខែ នៅពេល ដែលប្ដីគាត់បានត្រូវចាប់ខ្លួនកាលពី មួយឆ្នាំមុន។

អ្នកស្រីនិយាយទៀតថា ប្ដីរបស់អ្នកស្រីគឺលោក ម៉ា សេក ដែលមានអាយុស្របាលនឹងអ្នកស្រី បានត្រូវវាយដំ ដោយពួកនគរបាល ហើយ ធ្វើឱ្យគាត់បែកក្បាល មុនពេលត្រូវចាប់ខ្លួន និងបញ្ជូនទៅដាក់ក្នុងពន្ធនាគារ ។

ដោយកំពុងបីកូននៅជាប់នឹងដើមទ្រូង អ្នកស្រីបានត្អូញត្អែរថា "ខ្ញុំទទួលរងការលំបាកលំបិនគ្រប់បែប យ៉ាងទាំងអស់ "។

អ្នកស្រីបានពន្យល់ថាប្ដីរបស់គាត់មិនអាចផ្គត់ផ្គង់អ្នកស្រីក្នុងពេលអ្នកស្រីមានផ្ទៃពោះឡើយ ហើយគាត់ ក៏មិនបានឃើញកូនរបស់ពួកគេនៅពេលកូនបានកើតមកផងដែរ។

អ្នកស្រី ញាញ់ បាននិយាយថា នៅពេលដែលកូនគាត់ធំល្មម គាត់បានយកកូននេះទៅជួបឪពុករបស់វានៅ ក្នុងពន្ធនាគារ។

ដោយធ្វើត្រាប់នូវសកម្មភាពរបស់ខ្លួន អ្នកស្រីបាននិយាយថា "ខ្ញុំបានលើកកូនខ្ញុំ ដើម្បីឱ្យគាត់អាចថើប កូនបានតាមចន្លោះចំរឹងដែក ហើយ គាត់ក៏បានផ្ដាំផ្ញើខ្ញុំឱ្យថែរក្សាខ្លួន និងកូនផងដែរ "។

ដោយមានទឹកភ្នែកជោរជន់ពេញក្នុងក្រឡង់ភ្នែក អ្នកស្រីបានបន្តនិយាយថា "ខ្ញុំបានត្រឹមតែស្រែកយំ ប៉ុណ្ណោះ ហើយខ្ញុំមិនអាចនិយាយ អ្វីបានឡើយ "។

ដូចអ្នកស្រី ញាញ់ ផងដែរ អ្នកស្រី វ៉ាន គន់ មានអាយុ ២៩ ឆ្នាំ បាននិយាយថា គាត់កំពុងតែមានផ្ទៃពោះ នៅពេលដែលប្ដីរបស់អ្នកស្រីបានត្រូវបានគេចាប់ខ្លួន។

**អ្នកភូមិទាំងនោះបាននិយាយថា ពួកគាត់បានធ្វើស្រែនៅលើដី នោះអស់រយៈពេលជាច្រើនឆ្នាំក្នុងអំឡុង ទសវត្សឆ្នាំ ១៩៨០**

អ្នកស្រីបាននិយាយបន្តថា ដោយសារតែអ្នកស្រី និងប្ដីរបស់គាត់ សុទ្ធតែជាកូនកំព្រា អ្នកស្រីពិតជាមានការលំបាកណាស់ ក្នុងការសម្រាលកូន និងថែ រក្សាខ្លួនគាត់និងកូនៗទាំងបួន តែម្នាក់ឯង។

គាត់បានមានប្រសាសន៍ទៀតថា "កូនៗរបស់ខ្ញុំនៅតូចខ្លាំងណាស់ ដូច្នេះខ្ញុំមិនអាចធ្វើការងារបានច្រើនឡើយ" ។

អ្នកស្រី គន់ ក៏បាននិយាយទៀតថា ជារៀងរាល់ពេល ដែលអ្នកស្រីរកប្រាក់បាន គាត់បានធ្វើដំណើរទៅមើលប្ដីគាត់ ជាមួយអ្នកជិតខាងដទៃទៀត ដែលបានធ្វើដំណើរទៅជួបសាច់ញាតិរបស់ពួកគេ នៅក្នុងពន្ធនាគារ ផងដែរ។

គាត់បាននិយាយថា "កូនប្រុសៗរបស់ខ្ញុំបានស្រែកយំនៅពេលពួកគេបានឃើញឪពុកខ្លួន ហើយ បន្ទាប់ មក ឪពុករបស់ពួកគេក៏យំតាម ផងដែរ"។

ដូចជាអ្នកភូមិផ្សេងទៀត ផងដែរ អ្នកស្រី គន់ និង លោកយាយ ហឿង បាននិយាយថា ពួកគាត់ចង់ឱ្យតុលាការធ្វើការដោះលែងប្ដីរបស់ពួកគាត់ ហើយបន្ទាប់មក ពួកគាត់នឹងអាចផ្ដោតយកចិត្តទុកដាក់ ទៅលើការទាមទារយកដីធ្លីរបស់ខ្លួនមកវិញ ។

លោកយាយ ហឿង បាននិយាយទាំងក្ដីអស់សង្ឃឹមថា "ប៉ុន្តែខ្ញុំមិនដឹងថា តើពួកគេនឹងដោះលែង រូបគាត់មកវិញដែរ ឬទេ ?"

# “ពួកយើងទាំងអស់គ្នានឹងស្លាប់ ប្រសិនបើពួកយើងពុំមានដីធ្លីទេនោះ”

## ខេត្តបាត់ដំបង



*ក្នុងសភាពចាស់ជរា និងឯកោ លោកយាយ សន (ខាងឆ្វេង) មិនអាចនាំយកទឹកពីកន្លែងដ៏សែនឆ្ងាយបានទេ។ ប្រភពទឹកដែលជិតជាងគេបំផុតសំរាប់ប្រើប្រាស់ដាំស្លរ និងបោកគក់គឺនៅក្នុងត្រពាំងមួយដែលស្ថិតនៅចំងាយប្រមាណ ប្រាំពីរគីឡូម៉ែត្រពីផ្ទះ។*

**ករណី: ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង**

ជម្លោះ: ជម្លោះដែលមានរយៈពេល ១៣ឆ្នាំ រវាងពាណិជ្ជករបីរូបដែលមានទំនាក់ទំនងគ្នាយ៉ាងល្អ និងប្រជាជនចំនួន ៣៨ គ្រួសារ ទៅលើផ្ទៃដីចំនួន ១២៥ ហិចតា ។

ព្រឹត្តិការណ៍ ឬហេតុការណ៍សំខាន់ៗដែលកើតមានឡើង:

– ក្នុងឆ្នាំ ២០១០នេះ: ក្រសួងការពារជាតិបានចុះទៅពិនិត្យដើម្បីដោះស្រាយជម្លោះដីធ្លី ។

– អ្នកភូមិបាននិយាយថា ពាណិជ្ជករនេះបានផ្តល់ពួកគេនូវដីថ្មីចំនួន ៨០ ហិចតា ជាថ្នូរនឹងដីរបស់ពួកគាត់ ដែលត្រូវបានរឹបអូសយក តែទោះជាយ៉ាងណាក៏ដោយ ក៏ដីនោះស្ថិតនៅឆ្ងាយពីផ្ទះរបស់ពួកគាត់ ហើយការដាំដុះតម្រូវឱ្យមានធ្វើការឈូសឆាយព្រៃឈើរបស់ពួកគេជាបន្ថែមទៀតដែលពួកគេមិនសុខចិត្ត។ ជាងនេះទៅទៀត ផ្ទៃដីចំនួន ៥ ហិចតាដែលគេផ្តល់ឱ្យគឺស្ថិតនៅក្នុងជម្លោះដាច់ដោយឡែកជាមួយ ភូមិដទៃទៀតដែលបានអះអាងថាដីនោះគឺជាដីរបស់ពួកខ្លួន ។



លោកយាយ ចាន់ សន មានអាយុ ៧០ ឆ្នាំ ដោយស្លៀកសារុងចាស់ ហើយ ពាក់អាវពណ៌បៃតងចាស់ កំពុងអង្គុយបត់ជើងតាមប្រពៃណីខ្មែរ លើរនាបឈើក្នុងខ្ទមស្បូវមួយ ដែលគ្មានទ្វារ និងផ្ទៃមុខបង្ហាញនូវភាពអន្ទង់អន្ទោច។

ជាស្ត្រីចំណាស់ខ្មែរមួយរូប លោកយាយមើលទៅដូចជាមនុស្សម្នាក់ដែលអ្នកភូមិទាំងពួង ប្រាថ្នាចង់ប្រាស្រ័យទាក់ទងជាមួយ។ ប៉ុន្តែលោកយាយ សន មិនចង់ទៅក្បែរមនុស្សម្នាទាំងឡាយនោះឡើយ។

លោកយាយបានត្អូញត្អែរថា "សព្វថ្ងៃនេះ ខ្លួនខ្ញុំមិនបានងូតទឹកអស់រយៈពេល ២ ថ្ងៃហើយ ខ្លួនខ្ញុំមាន ក្លិនស្អុយ ហើយខ្ញុំមិនហានដើរទៅជិតអ្នកផងទាំងពួងឡើយ ដោយសារតែក្លិនអាក្រក់របស់ខ្ញុំ។"

កាលពី ២ ឆ្នាំមុន លោកយាយ និងអ្នកភូមិដទៃទៀតធ្លាប់ងូតទឹកយ៉ាងហោចណាស់ ពីរដងក្នុងមួយថ្ងៃ ដោយដងទឹកពីស្រះក្បែរនោះនៅក្នុងភូមិរបស់ពួកគាត់ស្ថិតក្នុងស្រុកគាស់ក្រឡ ខេត្តបាត់ដំបងហើយជាទីកន្លែង ដែលពួកគាត់បានមករស់នៅចាប់តាំងពីឆ្នាំ ១៩៩៩ មកម្ល៉េះ។

> ដោយរកចំណូលបានតិចជាង ២,០០០ រៀល (៥០ សេន បើគិត ជាដុល្លារ) ក្នុងមួយថ្ងៃ ពួកគាត់និយាយថា វាស្ទើរតែមិនអាចទៅរួចទេ ដើម្បីធ្វើឱ្យចាយបានគ្រប់គ្រាន់នោះ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មានអ្នកជំនួញដ៏មានស្តុកស្តម្ភម្នាក់បានអះអាងថា ខ្លួនគេគឺជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើដីដែលជាទីតាំងដីស្រះទឹកនោះ។ ឈ្មួញនោះបាន បង្ហាញប័ណ្ណកម្មសិទ្ធិដែលខ្លួនបង្កើតឡើង ប្រៀបបាននឹងការប្រើ វេទមន្ត ហើយបានបញ្ជូនកម្មករ និងគ្រឿងចក្រទៅឈូសឆាយដី និងចាក់ដី បំពេញស្រះទឹករបស់អ្នកភូមិទាំងនោះ។

ចាប់តាំងពីពេលនោះមក អ្នកភូមិទាំងឡាយនិយាយថា ពួកគេបានប្រឈមមុខទៅនឹងការខ្វះខាតទឹកយ៉ាងខ្លាំង។

ប្រភពទឹកនៅជិតបំផុត ដែលពួកគេអាចប្រើដើម្បីដាំស្លនិងបោកគក់ គឺស្រះទឹកមួយទៀត ដែលស្ថិតនៅចម្ងាយប្រហែល ៧ គីឡូម៉ែត្រពីទីនេះ។

ដោយខ្លួនជាមនុស្សចាស់ និងរស់នៅឯកោផងនោះ លោកយាយ សន មិនអាចទៅដងទឹកឱ្យបានច្រើន ពីស្រះដែលមានចម្ងាយឆ្ងាយបែបនេះបានទេ។

ប៉ុន្តែអ្វីៗដែលធ្វើឱ្យជីវិតរបស់គាត់ និងប្រជាជនផ្សេងទៀតកាន់តែអាក្រក់បំផុតនោះ គឺការគំរាមកំហែង ពីគ្រោះទុរ្ភិក្ស ដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ននេះ ដោយសារតែការបាត់បង់វាលស្រែ ដែលត្រូវរឹបអូសដោយឈ្មួញនោះ។

អ្នកជិតខាងលោកយាយ សន ឈ្មោះ ព្រំ បុប្ផ ដែលមានអាយុ ៤២ ឆ្នាំ មានប្រសាសន៍ថា "កាលពីពួកយើងនៅមានដីធ្លីនៅឡើយ ឱ្យសិរាប់ការដាំដុះឱ យ៉ាងហោចណាស់ ខ្ញុំមានស្រូវ ២០ បាវ នៅក្នុងជង្រុក។"

នៅពេល លោកយាយ សន និយាយសារភាពថា ខ្លួនគាត់នៅសល់អង្ករតែ ២កំប៉ុងតែប៉ុណ្ណោះក្នុងពាង គាត់បាននិយាយតបទៅលោកយាយ សន វិញថា "ឥឡូវនេះ ខ្ញុំនៅសល់អង្ករតែ ៥ កំប៉ុងប៉ុណ្ណោះ ហើយពួក យើងមានគ្នារហូតដល់ទៅ ៨ នាក់នៅក្នុងផ្ទះ។"

បន្ទាប់ពីពួកគាត់មិនអាចធ្វើស្រែលើដីផ្ទាល់របស់ខ្លួនបាន អ្នកភូមិជាច្រើននិយាយថា ពួកគាត់បាន ព្យាយាមរករបរចិញ្ចឹមជីវិត ដោយសារការកាត់ស្បូវ ហើយយកមកក្រងធ្វើជាស្លឹកកណ្តុបសំរាប់លក់។

ដោយរកចំណូលបានតិចជាង ២,០០០ រៀល (៥០ សេន បើគិតជាដុល្លារ) ក្នុងមួយថ្ងៃ ពួកគាត់និយាយថា វាស្ទើរតែមិនអាចទៅរួចទេ ដើម្បីធ្វើឱ្យចាយបានគ្រប់គ្រាន់នោះ។

ដោយគ្មានប្រាក់គ្រប់គ្រាន់ ដើម្បីទិញអង្ករហូប អ្នកភូមិភាគច្រើន បានប្តូរពីការហូបបាយ ទៅជាហូបបបរ ដោយលាយជាមួយរុក្ខជាតិតូចៗ ឬស្លឹកឈើ ជាដើម។

លោកយាយ ទន់ សាំង ដែលមានអាយុ ៧០ ឆ្នាំ ត្អូញត្អែរថា "វាគួរឱ្យកំសត់ខ្លាំងណាស់ ហើយឥឡូវនេះ ពួកយើងកំពុងជួបប្រទះនឹងភាពអត់ឃ្លានហើយ "។

មុត វី មានអាយុ ៥៥ ឆ្នាំ និយាយកាត់ថា "ឥឡូវនេះវាអាក្រក់ជាងក្នុងរបបខ្មែរក្រហមទៅ ទៀត។ ពួកខ្មែរក្រហមបានសម្លាប់ពួក យើងភ្លាមៗ។ ប៉ុន្តែឥឡូវពួកគេទុកយើងឱ្យស្លាប់ ដោយសន្សឹម ៗ"។

ជាការពិតណាស់ វាអាចជា ការស្លាប់ដោយសន្សឹមៗ ជាពិសេសចំពោះករណីប្តីរបស់លោកយាយ សាំង ដែលបានធ្លាក់ខ្លួនឈឺដេកលើ គ្រែ ហើយគ្មានលុយ ដើម្បីទិញថ្នាំ ព្យាបាលទៀត។

អ្នកភូមិជាច្រើនបាននិយាយថា ពួកគាត់ពឹងផ្អែកលើរុក្ខជាតិឱសថដែលបានមកពីក្នុងព្រៃ ដើម្បីយកធ្វើជាថ្នាំព្យាបាលនៅពេលពួកគាត់មានជម្ងឺ ព្រោះថាខ្លួនមិនមានប្រាក់បង់សំរាប់ការព្យាបាលបែបសម័យឡើយ។

បន្ទាប់ពីអស់រយៈពេលបីឆ្នាំនៃការតវ៉ា ដោយមិនបានទទួលជោគជ័យអ្វីឡើយ នៅក្នុងការទាមទារដីរបស់ ពួកគាត់មកវិញនោះ អ្នកភូមិទាំងនោះបានបន្សល់ទុកនូវភាពភ័យខ្លាចនៃសុបិន្តអាក្រក់ចំពោះអនាគតរបស់ ពួកគាត់។

លោក យាយ សាំង មានចម្ងល់ថា "ខ្ញុំចង់សួរថា តើហេតុអ្វីបានជាពួកគេចេះតែដកហូតយកដីធ្លីរបស់ ពួកយើង ហើយមិនទុកឱ្យយើងធ្វើស្រែដូច្នេះទៅវិញ? ពួកយើងទាំងអស់គ្នានឹងស្លាប់ ប្រសិនបើជាពួកយើងពុំមានដីធ្លីទេនោះ " ។

# “ខ្ញុំគ្រាន់តែចង់បានដីពុកខ្ញុំ និងវាលស្រែខ្ញុំត្រឡប់មកវិញតែប៉ុណ្ណោះ”

## កំពង់ឆ្នាំង



*កុមារី សា សុខា នាំមុខលោកយាយខ្វាក់ភ្នែក និងលោកតាកោងខ្នងរបស់នាងលំនៅដ្ឋានរបស់ពួកនាងដែលបានប្រែក្លាយទៅជាកូនខ្ទមមួយ បន្ទាប់ពីក្រុមប៉ូលីសបានរំលាយចោលក្នុងពេលចុះអនុវត្តសាលក្រម។*

**ករណី : ភូមិឡពាង ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង**

កាលបរិច្ឆេទ ទំហំ និងក្រុមហ៊ុន: ក្រុមហ៊ុន ឃេឌីស៊ី (KDC) គឺជាក្រុមហ៊ុនអចលនវត្ថុរបស់លោកជំទាវ ជា ខេង (Chea Kheng) ភរិយា របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល គឺឯកឧត្តម ស៊ុយ សែម ។ អ្នកភូមិបាននិយាយថាផ្ទៃដីចំនួន ១៤៤ ហិចតារបស់ពួកគេត្រូវបានក្រុមហ៊ុន ឃេឌីស៊ី ដណ្តើមយក ។

សហគមន៍ដែលទទួលរងនូវផលប៉ះពាល់: មានប្រជាជនចំនួន ១០៨ គ្រួសារ នៅក្នុងភូមិឡពាង ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ព្រឹត្តិការណ៍ ឬហេតុការណ៍សំខាន់ៗដែលកើតមានឡើង:

នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១០ អ្នកភូមិទាំងឡាយបានជួបប្រជុំពិភាក្សាជាមួយលោកជំទាវ ជា ខេង ដែលពេលនោះ លោកជំទាវ ជា ខេង បានសន្យាថានឹងស្វែងរកដំណោះស្រាយទៅនឹងជម្លោះបន្ទាប់ពីចូលឆ្នាំខ្មែរ នៅខែមេសារួច ។



កុមារី ស សុខា មានអាយុ ១២ ឆ្នាំ ដែលស្លៀកសំលៀកបំពាក់ជាឯកសណ្ឋានកូនសិស្ស គឺសំពត់ខៀវស៊ើកលើអាវសដៃខ្លី កំពុងត្រៀមខ្លួនរួចជាស្រេចដើម្បីទៅកាន់សាលារបស់នាងនៅភូមិឡពាង្គ ឃុំតាជេស ស្រុកកំពងត្រឡាច ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅចំងាយប្រមាណ ៦០ គីឡូម៉ែត្រ នៅប៉ែងខាង ជើងនៃរាជធានីភ្នំពេញ ។

## ...មន្ត្រីតុលាការ មិនចង់ដោះស្រាយ ករណី ដែល ជាប់ ទាក់ទិនទៅនឹង មន្ត្រីជាន់ ខ្ពស់នោះទេ...

សព្វថ្ងៃនេះ កុមារីរូបនេះចូលរៀននៅក្នុងថ្នាក់ទី ៤ ហើយ។ នាង និងមិត្តភ័ក្ត្ររួមថ្នាក់របស់នាង មានសុបិន្តដ៏ធំមួយគឺ ចង់ក្លាយខ្លួនទៅជាគ្រូបង្រៀន ជារូបវិទូ ឬក៏ធ្វើជាវិស្វករ ប្រសិនបើពួកគេបានបញ្ចប់ការសិក្សារបស់ខ្លួន ។

ប៉ុន្តែសំរាប់សុខាវិញ ខ្លួននាងមានបំណងប្រាថ្នាជាបន្ទាន់មួយដែលនាងត្រូវបួងសួងឱ្យបានសម្រេចនាពេល នេះ ។

ដោយមានលាយឡំនឹងទឹកភ្នែកនាងផងនោះ នាង សុខា បានអំពាវនាវថា "ឥឡូវនេះ រូបនាងខ្ញុំ គ្រាន់តែចង់បានឪពុកនិងវាលស្រែរបស់នាងខ្ញុំត្រឡប់មកវិញតែប៉ុណ្ណោះ ។ វាគឺជារឿងអយុត្តិធម៌ណាស់ "។

ចំពោះគ្រួសាររបស់សុខា និងអ្នកភូមិដទៃទៀតដែលបានទទួលរងនូវការប៉ះពាល់នេះ ពួកគេមាន អារម្មណ៍ថាតុលាការបានជ្រើសរើសយកការប្រព្រឹត្តអំពើអយុត្តិធម៌ប្រឆាំងនឹងពួកគេ ហើយផ្តល់ "យុត្តិធម៌" ដើម្បីជាប្រយោជន៍ដល់ភរិយារបស់លោករដ្ឋមន្ត្រីម្នាក់ដែលបានដណ្តើមយក ដីស្រែចំការរបស់ពួកគេ ហើយឪពុក សុខាត្រូវបានគេចាប់ដាក់គុក ថែមទៀត ។

គ្រួសារនាង និងអ្នកភូមិទាំងអស់ដែលទទួលរងនូវការប៉ះពាល់មានជំនឿថា អ្វីៗទាំងអស់ គឺត្រូវបានគេ ប្រឌិតឡើងទាំងស្រុង ។

កាលពីខែ វិច្ឆិកា ឆ្នាំ ២០០៧ កន្លងទៅ ឪពុករបស់សុខា គឺលោក ស សុង មានជម្លោះ ជាមួយនឹងកសិករម្នាក់ទៀត នៅពេលដែលលោក សុង បានព្យាយាមហាមឃាត់បុរសនោះ មិនឱ្យភ្ជួរដីរបស់គាត់។ បុរសទាំងពីរនាក់ក៏បាន បង្កឱ្យមានរបួសតិចតួចនៅក្នុងជម្លោះនោះ ។

សាក្សីនានាបាននិយាយថា គូរបដិបក្ខរបស់លោក សុង បានអង្វរគាត់កុំឱ្យធ្វើការប្ដឹងផ្តល់រូបខ្លួនបន្ទាប់ ពីការប្រយុទ្ធគ្នាហើយ ប៉ុន្តែវាគឺជារឿងមួយដែលមិនគួរឱ្យជឿទាល់តែសោះដែលថា គឺរូប សុង ឯនោះវិញទេដែលត្រូវបានគេចាប់ខ្លួននៅ ៥ ថ្ងៃក្រោយមកទៀត ។

កសិករម្នាក់ទៀតដែលមកពីភូមិផ្សេងទៀតចំងាយប្រហែល ១០ គីឡូម៉ែត្រពីទីនោះ បានដាក់ពាក្យ បណ្ដឹងនៅឯតុលាការខេត្តកំពង់ឆ្នាំង ហើយតុលាការនេះក៏បានទទួលផងដែរពាក្យបណ្ដឹងមួយទៀតប្រឆាំងនឹងលោក ស សុង ពីលោកជំទាវ ជា ខេង ដែលជាភរិយារបស់ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ពីបទរំលោភបំពានទៅលើទ្រព្យសម្បត្តិរបស់គាត់ ។

ដោយមិនបានធ្វើការស៊ើបអង្កេតអ្វីឡើយ ឪពុករបស់សុខាត្រូវបានគេចោទប្រកាន់ពីបទការប៉ុនប៉ង មនុស្សឃាត និង រំលោភបំពានទៅលើទ្រព្យសម្បត្តិរបស់ភរិយារដ្ឋមន្ត្រី ។

តុលាការបានផ្តន្ទាទោស និង កាត់ទោសរូបគាត់ឱ្យជាប់គុកចំនួន ១១ ឆ្នាំកន្លះ ហើយរហូតមកដល់ ពេលនេះ គាត់បានជាប់គុកអស់រយៈ ពេល ៣ ឆ្នាំមកហើយ ។

ប៉ុន្តែជម្លោះលើដីធ្លីរបស់លោក ស សុង ដែលបានតុលាការប្រគល់ជូនទៅឱ្យភរិយាលោករដ្ឋមន្ត្រី ត្រូវបានមន្ត្រីសិទ្ធិមនុស្សនានា និងអ្នកភូមិទាំងឡាយចាត់ទុកថាគឺជារឿងមួយអយុត្តិធម៌ណាស់ ។

លោកតា ឆេត ឆន គឺជាតារបស់សុខាដែលមានអាយុ៩៩ឆ្នាំ និង ជាឪពុកក្មេករបស់លោក ស សុង បានិយាយថា គ្រួសាររបស់ គាត់បាន មកតាំងទីលំនៅក្នុងភូមិឡពាងអស់រយៈពេលស្ទើរតែកន្លះសតវត្ស មកហើយ។

គាត់បាននិយាយថា "រូបខ្ញុំបានមករស់នៅលើដីខ្ញុំ ចាប់តាំងតែពីពេលដែលរូបខ្ញុំមានអាយុទើបតែ ៥០ ឆ្នាំមកម្ល៉េះ"។

នៅក្នុងជម្លោះដីធ្លីជាមួយភរិយារដ្ឋមន្ត្រីនេះ លោកតា ឆន បាននិយាយថា គ្រួសារគាត់មិនត្រឹមតែ បានបាត់បង់ដីស្រែចំការចំនួន ២ហិចតាប៉ុណ្ណោះទេ ប៉ុន្តែគាត់បានបាត់បង់ផ្ទះមួយខ្នង និង ដីភូមិចំនួន ២ ហិចតាផងដែរ ដែលមានដើមដូង ដើមស្វាយ ដើមខ្នុរ និងដើមក្រូច ឆ្មារ សរុបទាំងអស់ប្រមាណ ៣០០ ដើម ។

ក្នុងការអនុវត្តសាលក្រមរបស់តុលាការ គាត់បាននិយាយថានគរបាលម្នាក់បានទាត់គាត់ចំក និងបណ្តាលឱ្យគាត់ធ្លាក់ពីលើផ្ទះ ហើយគាត់បាននិយាយថារបួសទាំងឡាយបានធ្វើឱ្យគាត់កោងខ្នងចាប់តាំងពីពេលនោះមក ។

ស្រដៀងគ្នានេះដែរ គាត់បាននិយាយថា ប្រពន្ធរបស់គាត់ក៏ត្រូវបានគេទាត់ធាក់ផងដែរ ហើយធ្លាក់ពី លើផ្ទះដូចគ្នា ហើយ បន្តិចក្រោយមកបានធ្លាក់ខ្លួនទៅជាពិការភ្នែក។

លោកតា ឆន បាននិយាយថា "ពួកគេបានលួចមាន់ ទា និង ឈើក្តាររបស់គាត់អស់រលីងគ្មានសល់"។

លោកតា ឆន បានមានប្រសាសន៍ទៀតថា គ្រួសារគាត់ធ្លាប់មានជីវភាពរីករាយជាមួយនឹងការលក់ផ្លែឈើ ដែលបានមកពីចំការ និង ការដាំដុះស្រូវនៅលើដីរបស់គាត់ ។

ដោយបង្ហាញពោះខ្វងរបស់គាត់ គាត់បាននិយាយបន្ថែមថា "សព្វថ្ងៃនេះខ្ញុំហូបបបររៀងរាល់ថ្ងៃ ជាមួយសមាជិក ៥ នាក់នៅក្នុង គ្រួសារ"។

គាត់បាននិយាយថា ភរិយាលោករដ្ឋមន្ត្រីបានបញ្ជូនកម្មករមករុះរើផ្ទះរបស់គាត់ និងបានកំទេចចោល ដំណាំរបស់គាត់ ព្រមទាំងចាក់ដីលុបស្រះទាំងពីររបស់គាត់ផងដែរ ។

បន្ថែមទៅលើការបាត់បង់ដីរបស់គ្រួសារនាង កុមារីសុខាបាននិយាយថា មានមិត្តភ័ក្ត្ររួមថ្នាក់របស់ នាងមួយចំនួនបានសើចចំអកឡកលើយឱ្យនាងចំពោះរឿងដែលឪពុកនាងត្រូវគេឃាត់ខ្លួន និង ចាប់ដាក់គុកនេះ។

នាងបានថ្លែងថា "មនុស្សមួយចំនួនបាននិយាយថា ឪពុកខ្ញុំបានលួចដីរបស់អ្នកដទៃ ហេតុដូច្នេះហើយ ទើបគាត់ត្រូវគេដាក់គុក"។

កុមារីបានបន្តទៀតថា "ខ្ញុំបានប្រាប់ពួកគេថា ឪពុកខ្ញុំបានរស់នៅលើដីនោះជាយូរយាមកហើយ ចាប់តាំងពីពេលដែលខ្ញុំមិនទាន់កើតមកម្លេះ ។ គាត់មិនបានលួចដីរបស់អ្នកណាម្នាក់ឡើយ "។

ទោះបីជាយ៉ាងណាក៏ដោយ ក៏នាងបាននិយាយថា អ្នកដទៃទៀតដែលបានដឹងការពិត ពួកគេមាន ការអាណិតអាសូរចំពោះ រូបនាងជាខ្លាំង ។

លោក សំ ចាន់គា ជាអ្នកស៊ើបអង្កេតម្នាក់របស់សមាគមសិទ្ធិមនុស្ស អាដហុក បាននិយាយថា ករណី ដែលទាក់ទិន ទៅនឹងឪពុករបស់ នាង សុខា និងអ្នកភូមិដទៃៗទៀត នៅក្នុងភូមិឡពាង គឺជាឧទាហរណ៍ មួយ នៃគុក ល្មោនយុត្តិធម៌ ។

ដោយគ្រវីក្បាលផង គាត់បាននិយាយថា "ករណីនៅភូមិឡពាងបានបង្ហាញឱ្យឃើញនូវអំពើអយុត្តិធម៌ យ៉ាងជាក់ស្តែងបំផុត " ។

គាត់បានបន្តទៀតថា មន្ត្រីតុលាការមិនចង់ដោះស្រាយករណីដែល ជាប់ ទាក់ទិនទៅនឹង មន្ត្រីជាន់ខ្ពស់នោះទេ ដូចជាករណីដែលមាន ទៅក្នុងភូមិ ឡពាងនេះជាដើម ។

> "ពីរបី លើកមកហើយ នៅពេលដែលយើង បានទៅ ជួបចៅក្រមអំពីករណីឡពាង ពួកគេបានដើរចេញទៅបាត់។ ឥឡូវ នេះ យើងមិនអាចធ្វើតាមផ្លូវច្បាប់ ទៀត បានឡើយ"

គាត់បានត្អូញត្អែរថា "ពីរបី លើកមកហើយ នៅពេលដែលយើងបានទៅ ជួបចៅក្រមអំពីករណីឡពាង ពួកគេបានដើរចេញទៅបាត់។ ឥឡូវនេះ យើងមិនអាចធ្វើតាមផ្លូវច្បាប់ ទៀត បានឡើយ " ។

លោក ចាន់គាជឿជាក់ថា គ្រប់ជម្លោះដីធ្លីអាចនឹងត្រូវបានដោះស្រាយ ប្រសិនបើរាជរដ្ឋាភិបាលមាន បំណងចង់ដោះស្រាយ ។

គាត់បាននិយាយថា "ប្រសិនបើរាជរដ្ឋាភិបាលមានឆន្ទៈក្នុងការដោះស្រាយបញ្ហាទាំងឡាយ គឺគេអាច ធ្វើបាន"។

ចំពោះកុមារីសុខាវិញ មិនថាតើមានមនុស្សអាណិតអាសូរដល់រូបនាង ឬអត់នោះទេ នាងមិនខ្វាយខ្វល់នឹង រឿងនោះឡើយ។ នាងគ្រាន់តែមានការព្រួយបារម្ភជាចំបងអំពីឪពុករបស់នាង ដែលត្រាំត្រែងនៅក្នុងគុក តែប៉ុណ្ណោះ ។

នាងបានរៀបរាប់អំពីការទៅលេងសួរសុខទុក្ខ ឪពុកនាងនៅលើកចុងក្រោយកាលពីមួយខែកន្លងទៅថា "គាត់មានជម្ងឺ និងបានសុំពួកយើងឱ្យផ្ញើថ្នាំជូនគាត់ ហើយគាត់បានប្រាប់នាងខ្ញុំឱ្យនៅផ្ទះជួយមើលថែរក្សាតាយាយ របស់ខ្ញុំផង"។

បងស្រីរបស់សុខាឈ្មោះ ស សារឿន ដែលមានអាយុ ១៨ ឆ្នាំ បានមកដល់ដោយមានទូល ពំនូកចំបើងនៅលើក្បាលដើម្បីឱ្យគោស៊ី។ សារឿន ក៏បានទៅសួរសុខទុក្ខឪពុករបស់នាងនៅក្នុងគុក កាលពីមួយខែមុន នេះដែរ ។

ដោយបានព្យាយាមទប់ទឹកភ្នែក មិនឱ្យហូរផងនោះ នាង សារឿន បាននិយាយថា "នៅពេលដែលរូបនាងខ្ញុំ បានឃើញគាត់ នាងខ្ញុំនិយាយមិនរួចនោះទេ គាត់មានជម្ងឺ ហើយគេនៅតែ ដាក់គុករូបគាត់ទៀត "។

ដោយហេតុតែគេ បានលួចប្លន់ដី ស្រែផ្ទាល់ខ្លួនអស់ នាង សារឿន បាននិយាយថា ម្តាយនាងត្រូវបានគេជួល ឱ្យធ្វើជាអ្នកច្រូតស្រូវ នៅឯភូមិ មួយទៀត ដែលមានចំងាយ ៤០ គីឡូម៉ែត្រ ពីផ្ទះរបស់នាង ។

នៅពេលដែលម្តាយនាងរកបានប្រាក់គ្រប់គ្រាន់សំរាប់ថ្លៃឈ្នួលរថយន្តតាក់ស៊ី នាងសារឿនបាននិយាយថា ម្តាយនាងអាចនឹងនាំ រូបនាងឬប្អូនស្រីនាងទៅលេងឪពុកនៅមន្ទីរឃុំឃាំងបាន ។

នាង សារឿន ក៏ដូចជាប្អូនស្រីរបស់នាង បាននិយាយថានាងចង់ឃើញគ្រួសារនាងបានមករស់នៅជួបជុំគ្នាឡើងវិញ និងដីស្រែចំការរបស់ នាងត្រូវបានគេប្រគល់មកវិញផងដែរ ។

នាងបាននិយាយថា "រូបនាងចង់បានទាំងឪពុកនាង និងទាំងដីធ្លីរបស់នាងមកវិញ "។

ក៏ប៉ុន្តែលោកយាយរបស់នាងបានឆ្លើយតបថា "ឪពុកនាងនឹងត្រូវបានគេដោះលែង រងចាំដល់ ១០ឆ្នាំ ទៀតឯណោះ"។

នាងសារឿនបានឆ្លើយតបថា "នាងកើតទុក្ខខ្លាំងណាស់នៅពេល ដែលឃើញគ្រួសារនាង ត្រូវព្រាត់ ប្រាស់ គ្នាយ៉ាងដូចនេះ"។

# ការបំបាត់ព្រៃពីបុរាណ និងការឆក់យកនូវមធ្យោបាយចិញ្ចឹមជីវិតជាប្រពៃណី របស់អ្នកភូមិ

## កំពង់ឆ្នាំង



*រ៉ូ ពុធារី កំពុងតែត្បាញកន្ទេល ពីសំបកផ្តៅនៅក្នុងផ្ទះរបស់នាង ក្នុងឃុំពេជ្រចង្វា។ ទោះបីជាយ៉ាងណាក៏ដោយ ជីវភាព និងប្រពៃណីទំនាមទំលាប់របស់ប្រជាជន នឹងត្រូវបាត់បង់ក្នុងពេលឆាប់ៗនេះនៅពេលដែលក្រុមហ៊ុនកំទេចព្រៃចោលអស់។*

**ករណី: ឃុំពេជចង្វារ ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង**

សម្បទាន: កិច្ចសន្យាចំនួនពីរដែលមានរយៈពេល ៧0ឆ្នាំត្រូវបានផ្តល់ឱ្យសម្រាប់ដាំដើមប្រេងខ្យល់ និងអាកាស្យាដែលមានការលូតលាស់យ៉ាងឆាប់រហ័សដើម្បីធ្វើជាវត្ថុធាតុដើមផលិតក្រដាស់ និងរោងចក្រ ក្រដាស់ទំនើប ដែលរួមមានទាំងគម្រោងធារាសាស្រ្តធំៗផងដែរ ។

– កាលបរិច្ឆេទ ទំហំ និងក្រុមហ៊ុន: ដីសម្បទានសេដ្ឋកិច្ចដែលបានផ្តល់នៅក្នុងឆ្នាំ២000 ជាង ៣១0.000 ហិចតា (ជាដីដែលត្រួតស៊ីគ្នាតាមព្រំប្រទល់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិសាត់) ទៅឱ្យក្រុមហ៊ុនភាពីមិចចំកាត់ ដែលមានម្ចាស់ជាសមាជិកព្រឹទ្ធសភាគណៈបក្សប្រជាជន ឈ្មោះ ឡាវ ម៉េងឃិន (Lau Meng Khin) និងភរិយារបស់គាត់ឈ្មោះ ចើង សុភាព (Cheung Sopheap) ជានាយកក្រុមហ៊ុន។

– សហគមន៍ដែលទទួលរងផលប៉ះពាល់: ភូមិរាប់រយនៅក្នុងឃុំចំនួនប្រហែល ៥0 ក្នុងស្រុកចំនួន ៤ ខេត្តកំពង់ឆ្នាំ (គឺស្រុកសាមគ្គីមានជ័យ ស្រុកទឹកផុស ស្រុករលាប្អៀរ និងស្រុកបរិបូរ) និងស្រុកចំនួន៣ទៀតនៅក្នុងខេត្តពោធិសាត់ (គឺស្រុកភ្នំក្រវាញ ស្រុកសំពៅមាស និងស្រុកក្រគរ) អ្នកភូមិទាំងឡាយពឹងផ្អែកទៅ លើព្រៃឈើដើម្បីប្រមូលនូវអនុផលព្រៃឈើ និងលែងសត្វគោក្របីឱ្យស៊ីស្មៅ។



បន្ទាប់ពីរដូវច្រូតកាត់បានកន្លងផុតទៅ រ៉ូ ពុធរី មានអាយុ ២២ ឆ្នាំ និងអ្នកភូមិដទៃទៀត តែងតែទៅ កាន់ព្រៃក្រោយភូមិរបស់នាង ដើម្បីរកអុសដុត ជីកដំឡូងព្រៃ រកផ្សិត និងបេះផ្លែឈើព្រៃ ដើម្បីបំពេញបន្ថែម ចំណីអាហាររបស់ពួកគេ។

ក្នុងកំឡុងពេលចូលឆ្នាំថ្មី រដូវបុណ្យភ្ជុំបិណ្ឌ ឬនៅពេលមានពិធីបុណ្យសព នាងនិងអ្នកភូមិក៏ទៅ កាន់ព្រៃនោះផងដែរ ដើម្បីប្រារព្ធពិធីសាសនា នៅឯគុហារ ដែលមានរូបសំណាក់ព្រះពុទ្ធដែលគេបានសាងសង់ឡើង រាប់ ទសវត្សកន្លងមកហើយ។

នៅមុនពេលដែលបុរសម្នាក់ចូលស្ដីដណ្ដឹងស្រ្ដីម្នាក់ធ្វើជាប្រពន្ធនោះ ក្រុមគ្រួសារអនាគតភរិយាតម្រូវឱ្យ អនាគតកូនកម្លោះទៅចូលព្រៃដើម្បីកាប់ ឈើ យកមកសង់ផ្ទះមួយខ្នង ។

ទោះបីជាយ៉ាងណាក៏ដោយ របៀបរបបរស់នៅសំរាប់អ្នកភូមិនៅ ក្នុងឃុំពេជ្រចង្វា ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំងនេះមិនយូរមិនឆាប់នឹងក្លាយ ទៅជារឿងមួយដែលធ្លាប់មានកាលពី អតីតកាលប៉ុណ្ណោះ។ ដោយហេតុថា ក្រុមហ៊ុនចិនមួយមានគំរោងកំទេច ចោលគ្រប់ព្រៃពីបូរាណកាលរបស់ ពួកគេហើយដាំដើមប្រេង ខ្យល់ជិនួសវិញ ដើម្បីផ្គត់ផ្គង់ដល់រោងចក្រផលិត ក្រដាសមួយនៅពេលអនាគតខាងមុខនេះ នៅទីកន្លែងនោះតែម្ដង។

## "វាដូចជាការបំផ្លិចបំផ្លាញខ្លួនឯង តាមរយៈការបំផ្លិចបំផ្លាញ ព្រៃឈើរបស់ខ្លួន"

រួមជាមួយនឹងការបាត់បង់នូវរបៀបរបបរស់នៅជាប្រពៃណីរបស់ ពួកគេ ពុធរី បានថ្លែងថា ក្រុមអ្នកភូមិ ក៏នឹងបាត់បង់ផងដែរនូវសេចក្ដីថ្លៃថ្នូររបស់ ពួកគេក្នុងឋានៈជាកសិករឯករាជ្យ ប្រសិនបើពួកគេមិនអាចរកស៊ី ចិញ្ចឹមជីវិត របស់ពួកគេពីព្រៃឈើនោះ ហើយត្រូវបង្ខំចិត្តធ្វើជាកម្មករស៊ីឈ្នួលឱ្យក្រុមហ៊ុន មិនខាន។

នាងបាននិយាយថា "អ្នកភូមិចង់ធ្វើជាម្ចាស់លើខ្លួនឯង ហើយមិនចង់ ធ្វើជាខ្ញុំបំរើរបស់ក្រុមហ៊ុននោះទេ"។

មនុស្សជាច្រើនដែលបានបំរើការរយៈពេលដ៏ខ្លីឱ្យក្រុមហ៊ុននោះបានលាឈប់ ដោយមិនទទួលប្រាក់កំរៃ ដោយលើកហេតុផលថា ការងារលំបាក និងច្បាប់តឹងរឹង តំរូវឱ្យអនុវត្ត តាមអ្នកគ្រប់គ្រងជាជនជាតិចិនដោយបាន គោះ ជួងដូចជាកាលសម័យខ្មែរក្រហម ដើម្បីហៅប្រជាជនឱ្យទៅធ្វើការងារ។

នៅពេលដែលក្រុមហ៊ុនបានចូលមកដល់ និងបានចាប់ផ្ដើមកាប់រំលំ ព្រៃឈើនៅឆ្នាំ ២០០៤ ប្រជាជន បានចាប់ផ្ដើមធ្វើការ តវ៉ាប្រឆាំង។

ថ្វីបើមានហេតុការណ៍នេះ និងមានមូលហេតុផ្សេងៗទៀតក៏ដោយក៏ការតស៊ូដែលមានរយៈពេល៦ឆ្នាំនេះ មិនទាន់មានលទ្ធផលណាមួយឡើយទេ។

តាមពិតយោងតាមទីតាំងភូមិសាស្ត្រ ព្រៃឈើទាំងនេះស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ដែលជាខេត្តដែលមាន ព្រំប្រទល់ជាប់នឹងខេត្តកំពង់ឆ្នាំង។

ចំពោះប្រជាជននៅក្នុងឃុំពេជ្រចង្វា ដែលស្ថិតនៅក្នុង ខេត្តកំពង់ឆ្នាំង ពុធរី បាននិយាយថា ការនេះធ្វើឱ្យ ការតស៊ូរបស់ពួកគេ ដើម្បីទាមទារព្រៃសហគមន៍របស់ពួកគេមកវិញមានការលំបាក។

នាងបានត្អូញត្អែរថា អាជ្ញាធរឃុំមិនបានគាំទ្រដល់ពួកយើងនោះទេ "ដោយបានធ្វើការពន្យល់ថា អាជ្ញាធរ ឃុំពោធិ៍សាត់បានប្រាប់ទៅពួកគេថា ឃុំមិនអាចធ្វើការ ទៅលើបញ្ហាដែលស្ថិតនៅក្រៅការគ្រប់គ្រងរដ្ឋបាលរបស់ ខ្លួនបានឡើយ "។

"ពួកគេបាននិយាយថា ប្រសិនបើប្រជាជនតវ៉ា ពួកគេមិនទទួលខុសត្រូវចំពោះផលវិបាកជាប្រយោល ដែលកើតឡើង ពីទង្វើរបស់គេចំពោះ ពួកយើងទេ" ជួប តឿន ដែលមានអាយុ ៤២ ឆ្នាំ បាននិយាយបន្ថែម ដែលគាត់បានចូលរួមជាមួយ ពុធរី និងអ្នកដទៃទៀតដើម្បីពិភាក្សានូវបញ្ហានេះ។

ប៉ុន្តែអ្នកភូមិទាំងឡាយ នៅឃុំអន្សាចំបក់ជិតខាងគ្នាដែលនៅ ក្នុងខេត្តពោធ៌សាត់មិនបានទទួលដំណោះស្រាយច្បាស់លាស់ ណាមួយនៅឡើយដែរ បើទោះបីជាព្រៃឈើនោះស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចគ្រប់គ្រងរបស់អាជ្ញា ធរមូលដ្ឋានក៏ដោយ។

នៅពេលដែលបានសួរថា តើនាងមានក្ដីសង្ឃឹមនឹងបានទទួលព្រៃមួយផ្នែកដែលក្រុមហ៊ុនបាន ដណ្ដើមយក នោះឬទេ ថង ធា ដែលមានអាយុ ៣៥ ឆ្នាំ បាននិយាយថា "ខ្ញុំមិនដឹងទេ។ ពួកយើងគ្រាន់ តែរង់ចាំមើលតែប៉ុណ្ណោះ"។

នាងបាននិយាយថា អ្នកភូមិទាំងឡាយនៅក្នុងឃុំរបស់នាងបានពឹងពាក់អាស្រ័យលើព្រៃនោះ សំរាប់មុខ ងារជាច្រើនដូចជា ពួកគេបានប្រើប្រាស់វាធ្វើជាកន្លែងតាំងលំនៅថ្មីរបស់សត្វពាហនៈរបស់ពួកគេ នៅពេល ដែលភូមិ ទាំងឡាយ ត្រូវទទួលរងនូវទឹកជំនន់ដោយការឡើងទឹកទន្លេសាប ហើយក៏ប្រើប្រាស់វាសំរាប់រកអនុផល ព្រៃឈើផងដែរ។

នាងបានបន្តទៀតថា "ព្រៃឈើទាំងនោះ គឺជាឆ្នាំងបាយរបស់ពួកយើង"។

ធាបាននិយាយថា អ្នកស្រុកមួយចំនួនត្រូវបានគេជួលដើម្បីកាប់រំលំព្រៃឈើឱ្យក្រុមហ៊ុនចិន ប៉ុន្តែចំពោះ រូបនាង និងអ្នកដទៃទៀតវិញគំនិតនៃការកាប់រំលំដើមឈើរបស់ខ្លួនឯង គឺដូចជារឿងកំប្លែងដ៏អាក្រក់មួយ។

"វាដូចជាការបំផ្លិចបំផ្លាញខ្លួនឯង តាមរយៈការបំផ្លិចបំផ្លាញព្រៃឈើរបស់ខ្លួន" នាងបាននិយាយផង និងសើចផង។ ទោះជាយ៉ាងណាក៏ដោយ ក៏ការបន្តធ្វើការតវ៉ាអាចនឹងមានផលត្រឡប់មកវិញផងដែរ។

"ខ្ញុំខ្លាចថា ខ្ញុំនឹងមានគ្រោះថ្នាក់ចរាចរតាមផ្លូវដោយមិនដឹងខ្លួនទេ" សុខ ចំរើន ដែលមានអាយុ៤២ ឆ្នាំ បាននិយាយ ដោយបានឱ្យយោបល់ថា ការកើនឡើងនៃ "គ្រោះថ្នាក់នានា" អាចនឹងកើតមានឡើង ហើយក៏ជាយុទ្ធសាស្ត្របង្អើលដែលគេបានប្រើប្រាស់ដើម្បីបំបិតសំលេងរបស់អ្នកភូមិ។

# អ្នកភូមិព្រៃពាយកំពុងបាត់បង់នូវក្តីសង្ឃឹម

## កំពត



*អ្នកភូមិកុំតែសិក្សាផែនទីភូមិសាស្ត្រ ដើម្បីចង្អុលបង្ហាញទីតាំងដីស្រែចំការរបស់ពួកគាត់ដែលបានរុករានដោយម៉ាស៊ីនឈូសដីរបស់ក្រុមហ៊ុន*

**ករណី: ភូមិព្រៃពាយ ឃុំត្រពាំងប្លាំង ស្រុកឈូក ខេត្តកំពត**

<u>សម្បទាន:</u> បានផ្តល់ឱ្យទៅចំការដំណាំកសិ-ឧស្សាហកម្ម ។

<u>កាលបរិច្ឆេទ ទំហំ និងក្រុមហ៊ុន:</u> ដីសម្បទានសេដ្ឋកិច្ចចំនួន ៩.៨០០ ហិចតា ត្រូវបានផ្តល់នៅក្នុងឆ្នាំ ២០០៦ ទៅឱ្យក្រុមហ៊ុនវើដទ្រីស្តាអិនធើថាយមិនកម្ពុជា ចំកាត់ ( World Tristar Entertainment Co, Ltd) ។

<u>សហគមន៍ដែលទទួលរងផលប៉ះពាល់:</u> មានប្រជាជនជាង ៦០០ គ្រួសារនៅក្នុងភូមិព្រៃពាយ ឃុំត្រពាំងប្លាំង ស្រុកឈូក ខេត្តកំពត ។

<u>ព្រឹត្តិការណ៍ ឬហេតុការណ៍សំខាន់ៗដែលកើតមានឡើង:</u>

<u>– ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១០:</u> តុលាការខេត្តកំពតបានកោះហៅ តំណាងអ្នកភូមិចំនួន ៥ រូប មកពីភូមិ ព្រៃពាយ ដើម្បីពិភាក្សាការ ចោទប្រកាន់ ដែលបានប្តឹងចំពោះពួកគេ គឺការចោទប្រកាន់ពីបទការបំផ្លិច បំផ្លាញដោយចេតនា ប្រឆាំងនឹងគម្រោងអភិវឌ្ឍន៍អនុមតិដោយរដ្ឋាភិបាល ដែលដឹកនាំដោយក្រុមហ៊ុន វើលទ្រីស្តា (World Tristar) ។ ដើម្បីចៀសវាងកុំឱ្យជាប់ពន្ធធនាគារ អ្នកតំណាងទាំងប្រាំនាក់ ត្រូវធ្វើសន្យាបញ្ឈប់នូវរាល់សកម្មភាព និងការតវ៉ារបស់ពួកខ្លួន ។

– អ្នកតំណាងថ្មីទាំងឡាយរបស់ភូមិត្រូវបានជ្រើសរើសឡើងនៅនឹងកន្លែងរបស់ពួកគេ ។

– <u>ក្នុងឆ្នាំ ២០១០:</u> អាជ្ញាធរស្រុកឈូកបានប្រាប់អ្នកភូមិទាំងឡាយឱ្យដាក់ពាក្យបណ្តឹងជាមួយនឹង គណៈកម្មាធិការទទួលបន្ទុកដំណោះស្រាយជម្លោះដីធ្លី ។



កាលសម័យគ្រប់គ្រងដោយអាណានិគមនិយមបារាំង ដែលមានរយៈពេលជាង ១០០ ឆ្នាំ កន្លងមកហើយ គេនិយាយថា មានគ្រួសារអ្នករស់នៅក្រៅច្បាប់ចំនួនពីរគ្រួសារបានរត់ភៀសខ្លួនពីការដេញតាម ចាប់របស់បារាំង ពីបទឧក្រិដ្ឋ ដែលស្វាមីរបស់ពួកគេបានប្រព្រឹត្តនៅទីរួមខេត្តកំពត។

ពួកគេបានទៅដល់ភ្នំដាច់ស្រយាលមួយនៅជាយខេត្តកំពត ដែលមានសត្វដំរី សត្វខ្លា និងសត្វព្រៃដទៃ ទៀតដើរត្រាច់ចរណ៍ នៅក្នុងព្រៃក្រាស់ៗ។ ពេលវេលាចេះតែកន្លងផុតទៅ មានមនុស្សជាច្រើនបានមកតាំងលំនៅ នៅទីនោះ និងបានត្រួសត្រាយផ្លូវឱ្យមានការបង្កើតភូមិក្បែរជើងភ្នំនោះ។

អស់រយៈពេលជាងមួយសតវត្សក្រោយមក ភូមិនោះបានក្លាយទៅជាកន្លែងភៀសខ្លួនសំរាប់ក្រុមរស់នៅ ក្រៅច្បាប់ថ្មី គឺអ្នកប្រយុទ្ធរបស់ខ្មែរក្រហមរហូតដល់ពេលដែលពួកគេត្រូវបានធ្វើសមាហរន្តកម្មចូលទៅក្នុងសង្គម ជាតិវិញនៅក្នុងឆ្នាំ ១៩៩៧ ។

អ្នកភូមិទាំងឡាយបាននិយាយថា ថ្វីបើជីវិតជាកសិករបន្ទាប់ពីការធ្វើសមាហរន្តកម្មហើយ មានការលំបាកក៏ដោយ ក៏ពួកគេមានអាហារ ហូបគ្រប់គ្រាន់ ហើយមិនមានការ ព្រួយ–បារម្ភអំពីអនាគតរបស់ពួកគេឡើយ។

> ស្រី អុន បានបញ្ជាក់ថា ពួកគេនឹងជួបប្រទះការអត់ឃ្លាន ឬត្រូវផ្លាស់ទីកន្លែង ទៅកាន់កន្លែងផ្សេងទៀត ដើម្បីស្វែងរកការងារធ្វើ។
>
> "ប៉ុន្តែពួកយើងមិនដឹងថា តើត្រូវទៅទីណានោះទេ" ស្វាយ ច្រេប ពន្យល់ដោយការភ័យខ្លាច។

ទោះបីជាយ៉ាងណាក៏ដោយ អ្វីៗទាំងអស់បានផ្លាស់ប្តូរអស់រយៈពេល ៤ឆ្នាំកន្លងមកហើយនៅពេលដែល រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឱ្យក្រុមហ៊ុនមួយ ដើម្បីធ្វើការអភិវឌ្ឍន៍តំបន់នោះ ដែលបច្ចុប្បន្ននេះ គេហៅថាជាភូមិព្រៃពាយ ឃុំត្រពាំភ្លាំង ស្រុកឈូក ខេត្តកំពត។

នៅពេលដែលព្រៃទាំងឡាយបានបាត់បង់ទៅ សត្វខ្លា ដំរី និងសត្វព្រៃ ដទៃទៀតក៏បានវិនាសសាបសូន្យផងដែរ។ ឥឡូវនេះ អ្នកភូមិទាំងឡាយនិយាយថា ដីស្រែទាំងឡាយក៏កំពុងបាត់បង់ផងដែរ ដោយសារតែការអភិវឌ្ឍន៍នេះ។

អ្នកភូមិទាំងឡាយកំពុងពិភាក្សាគ្នាអំពីផលប៉ះពាល់នៃការអភិវឌ្ឍន៍ និងវិធីសាស្ត្រដើម្បីតវ៉ាយកដីធ្លីរបស់ពួកគេមកវិញ នៅក្រោមផ្ទះឈើមួយខ្នង។

សឿន ស្រីអូន មានអាយុ ២៧ ឆ្នាំ ដែលទើបតែមកដល់ដោយមានពរកូននៅជាប់នឹងចង្កេះ បានសួរថា "តើគេមានឈូសឆាយដីចំការល្ហុងរបស់អ្នកទេ?"។

ស្វាយ ច្រេប មានអាយុ ៤៤ ឆ្នាំ បានឆ្លើយតបថា "រឿងនេះគឺជាអ្វីដែលខ្ញុំព្រួយបារម្ភ ឥឡូវនេះដីស្រែ របស់ពូ ខន ត្រូវបានគេឈូសឆាយអស់ហើយ"។

ដោយមានផ្ទៃពោះ និងទំនងជាខ្វះអាហាររូបត្ថម្ភផងនោះ ស្វាយ ច្រេប នឹងត្រូវឆ្លងទន្លេនៅក្នុងពេលឆាប់ៗ ខាងមុខនេះហើយ ហើយអនាគតនាងក៏ដូចជាអនាគតរបស់អ្នកជិតខាងផងដែរ គឺពោពេញទៅដោយសេចក្តីស្រងេះស្រងោច។

ស្រី អុន បានបញ្ជាក់ថា ពួកគេនឹងជួបប្រទះការអត់ឃ្លាន ឬត្រូវផ្លាស់ទីកន្លែង ទៅកាន់កន្លែងផ្សេងទៀត ដើម្បីស្វែងរកការងារធ្វើ។

"ប៉ុន្តែពួកយើងមិនដឹងថា តើត្រូវទៅទីណានោះទេ" ស្វាយ ច្រេប ពន្យល់ដោយការភ័យខ្លាច។

ស្រី អុន បានឆ្លើយតបថា "ពួកយើងចេះតែធ្វើស្រែចំការប៉ុណ្ណោះ ហើយមិនចេះរបៀបរកស៊ីដូច មនុស្សនៅតាមទីផ្សារនោះទេ។

ស្វាយ ច្រេប បានធ្វើការសន្និដ្ឋាន ដោយដកដង្ហើមធំថា "ដូច្នេះពួកយើងប្រាកដជាស្លាប់ជាមិនខានឡើយ"។

អ្វីៗដែលធ្វើឱ្យការតស៊ូរបស់ពួក គេមានការលំបាកកាន់តែខ្លាំងឡើងនោះ គឺថា កំលាំងរួបរួមជួរមុខរបស់ អ្នកភូមិត្រូវបានបែកបាក់។ វាស្រដៀងទៅនឹងអ្វីៗ ដែលបាន កើតឡើងនៅឯកន្លែងផ្សេងទៀតដែរ អ្នកភូមិ ទាំងឡាយជឿជាក់ថាអាជ្ញាធរ ទាំង ឡាយបាន និងកំពុងតែប្រើប្រាស់ យុទ្ធសាស្ត្ររួម មួយដើម្បីបញ្ចប់ជំលោះ ដីធ្លី ទាំងឡាយ គឺយុទ្ធសាស្ត្រមួយ ដែលសព្វថ្ងៃនេះ ភាសិត ខ្មែរនិយាយថា "ចាប់ខ្លួនម្នាក់ដើម្បី បំភិតបំភ័យមនុស្ស ១០០ នាក់ ដទៃផ្សេងទៀត"។

នៅពេលដែលជំលោះដីធ្លីបានផ្ទុះឡើងជាមួយក្រុមហ៊ុន World Tristar Entertainment កម្ពុជាចំកាត់ក្នុង ឆ្នាំ ២០០៦ អ្នកភូមិទាំងឡាយបានធ្វើការប្រឆាំងតវ៉ា។ តុលាការបានកោះហៅតំណាងអ្នកភូមិចំនួន ៥ នាក់ និងប្រាប់ពួកគេឱ្យផ្តិតមេដៃព្រមទាំងសន្យាថាឈប់ធ្វើការតវ៉ា បើមិនដូច្នោះទេ នឹងប្រឈមមុខនឹងការចាប់ខ្លួន ជាមិនខានឡើយ។

អ្នកទាំង ៥ នាក់ បានចុះចាញ់ ហើយសុខចិត្តធ្វើតាមអ្វីៗ ដែលតុលាការបានបង្គាប់ឱ្យធ្វើ។

បន្ទាប់ពីអតីតសកម្មជនទាំងឡាយបានក្លាយជាអសកម្ម អ្នកភូមិទាំងអស់បានជ្រើសរើសអ្នកតំណាងថ្មី ប៉ុន្តែអ្នកតំណាងថ្មីទាំងអស់ក៏មិនសូវមានសង្ឃឹមច្រើនណាស់ណាដែរ។

សិទ្ធ ចាន់ណា មានអាយុ៣០ ឆ្នាំ ជាអ្នកតំណាងថ្មីនិងមានសកម្មភាពខ្លាំងក្លាជាងគេ បានត្អូញត្អែរថា "សព្វថ្ងៃនេះក្តីសង្ឃឹមរបស់ខ្ញុំនៅសល់តែ ២០ ទៅ ៣០ ភាគរយប៉ុណ្ណោះ ហើយក្តីសង្ឃឹមទាំងនេះ វាលែង មានទៅហើយ"។

នាងនិយាយថា អ្នកភូមិនានាហាក់ដូចជាបាត់បង់នូវទំនុកទុកចិត្តរបស់ពួកគេអស់ហើយ "ពីព្រោះតែការ គំរាមកំហែងទាំងឡាយ និងអ្នកនៅពីខាងក្រៅ ដែលបានបង្ខូចទឹកចិត្ត និងស្មារតីរបស់ពួកគេ"។

# ការប្រយុទ្ធលើកចុងក្រោយរបស់អ្នកភូមិជ័យជំនះដើម្បីដីធ្លីរបស់ខ្លួន

## ក្រចេះ



*ពួកក្មេងៗនាំគ្នាលេងនៅក្បែរផ្ទះរបស់ពួកគេដោយពុំបានដឹងថា ពួកគេនឹកគ្មានដីសំរាប់ធ្វើស្រែចំការ នៅពេលដែលពួកគេធំឡើង ដោយសារតែដីស្រែពីដូនតារបស់ពួកគេ ត្រូវបានក្រុមហ៊ុនកាន់កាប់ នៅឡើយទេ។*

**ករណី : ឃុំស្រែចារ ឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ**

<u>សម្បទាន:</u> បានផ្តល់ទៅឱ្យក្រុមហ៊ុនចំការដំណាំកៅស៊ូ

<u>កាលបរិច្ឆេទ ទំហំ និងក្រុមហ៊ុន:</u> ដីសម្បទានសេដ្ឋកិច្ចបានផ្តល់នៅក្នុងខែឧសភា ឆ្នាំ២០០៨ ចំនួនជិត ៧៦៩ ហិចតា ទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ ស៊ីអាយវី (CIV Development Company) និង ក្រុមហ៊ុន ដាយយ៉ុង (Daiyong Company)។

<u>សហគមន៍ដែលទទួលរងផលប៉ះពាល់:</u> មានគ្រួសារជនជាតិដើមភាគតិចស្ទៀងជាង ២៥០គ្រួសារ នៅក្នុងភូមិ ចំនួន ៤ (គឺភូមិមានជ័យ ភូមិក្របី ភូមិចូលរោង ភូមិ ក្បាល លំពៅ និង ភូមិដីក្រហម) ។

<u>ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើង:</u>

<u>នៅក្នុងខែមករា ឆ្នាំ២០១០:</u> ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានសម្របសម្រួលឱ្យមានកិច្ចប្រជុំមួយរវាងអាជ្ញាធរខេត្តក្រចេះ និងអ្នកភូមិជនជាតិដើមភាគតិចស្ទៀង ។ ក្នុងកំឡុងពេលកិច្ចប្រជុំនេះ អាជ្ញាធរខេត្ត បានសន្យានឹងអ្នកភូមិថា ពួកគេនឹងស្នើសុំក្រុមហ៊ុន ស៊ីអាវី និង ក្រុមហ៊ុន ដាយយ៉ុង ឱ្យបញ្ឈប់ការឈូសឆាយដីរបស់អ្នកភូមិ រហូតដល់មានការ សម្រេចជាចុង ក្រោយមួយត្រូវ បានធ្វើឡើងលើដីជម្លោះនេះ។ ក្រុមហ៊ុនបាន បញ្ឈប់ជាបណ្តោះអាសន្ន ប៉ុន្តែបានចាប់ផ្តើម បន្តសកម្មភាពឡើងវិញ ។



ការប្រយុទ្ធរបស់ពួកគេគឺមានភាពស្រដៀងគ្នាទៅនឹងការសំដែងកីឡាកាសអាមេកាំង ដែលបុរស មានសាច់ដុំដូចយក្សតទល់ជាមួយនឹងគូរបដិបក្សមួយតូច ដែលមានមាឌត្រឹមតែពាក់កណ្តាលខ្លួនគេតែប៉ុណ្ណោះ។

នៅក្នុងជម្លោះដីធ្លីក្នុងភូមិមានជ័យ ("ជ័យជំនះ") ដែលស្ថិតនៅតាមព្រំប្រទល់ប្រទេសវៀតណាម គឺជាការប្រយុទ្ធរវាងអ្នកភូមិជនជាតិដើមភាគតិចស្មៀងដែលក្រីក្រ និងគ្មានអំណាច ជាមួយនឹងក្រុមហ៊ុនដែលមានប្រាក់ និងអំណាចដែលគាំទ្រដោយរាជរដ្ឋាភិបាល ។

ដោយមិនខ្វល់ទៅនឹងមាឌ និងកំលាំងរបស់គូរបដិបក្សដ៏មានអំណាចរបស់ខ្លួនអ្នកភូមិទាំងឡាយនិយាយថាពួកគេនឹងបន្តការវាយប្រហារនៅក្នុងសមរភូមិចុងក្រោយនេះ ដើម្បីដីធ្លីជនជាតិដើមភាគតិចរបស់ពួកគេ ដែលពួកគេជឿថា ក្រុមហ៊ុនអភិវឌ្ឍន៍ទាំងឡាយបានដណ្តើមយកទៅយ៉ាងអយុត្តិធម៌បំផុត។

សារ៉ែន កែត គឺជាសកម្មភាពជនមួយរូបក្នុងចំណោមសកម្ម–ជនទាំងឡាយ ដែលរហូតមកដល់ពេលថ្មីៗ នេះបានតំណាងឱ្យអ្នកភូមិទាំងឡាយទាក់ទងទៅនឹងជំលោះដីធ្លី បានអះអាងថា "វាគឺជាទឹកចុងក្រោយ ទោះបីជា ឈ្នះ ឬចាញ់ក្តី វានឹងជាការប្រយុទ្ធចុងក្រោយផងដែរ។"

ដោយបានចោទប្រកាន់ពីតុលាការខេត្តក្រចេះ ពីបទប្លន់ដោយគ្រាន់តែបានហាមឃាត់ម៉ាស៊ីនឈូស ឆាយរបស់ក្រុមហ៊ុនមិនឱ្យ ធ្វើការឈូសឆាយលើដីធ្លីរបស់ពួកគេនោះ សារ៉ែន កែត និងអតីតអ្នកតំណាងដទៃទៀត ចំនួន ៣ នាក់ ត្រូវបានគេជំរុញដោយបង្ខំឱ្យធ្វើការដកខ្លួនចេញឈប់ធ្វើជាអ្នកតំណាងរបស់អ្នកភូមិ ហើយ អនុញ្ញាតិឱ្យក្រុមតំណាងថ្មីមួយដែលត្រូវជ្រើសតាំងឡើង។

យ៉ុ នឿន គឺជាតំណាងម្នាក់ក្នុងចំណោមអ្នកតំណាងថ្មីទាំង ១០ នាក់ ដែលបានជំនួសអតីតអ្នកតំណាងទាំង ៤ នាក់ បានបេជ្ញាចិត្តដើម្បីព្យាយាមយកដីធ្លីរបស់ពួកគេពីក្រុមហ៊ុនទាំងឡាយត្រឡប់មកវិញ ។

នាងបាននិយាយថា "ពួកយើងសុខចិត្តស្លាប់ ជាជាងទុកឱ្យពួកគេយកដីធ្លីរបស់ពួកយើង" ។

"ដីរបស់យើង" ឬ "ដីរបស់គេ" គឺជាប្រធានបទនៃជំលោះទៅលើដីធ្លីនៅក្នុងឃុំស្រែចារ ស្រុកស្នួល ដែលរដ្ឋាភិបាលបានលក់ទៅឱ្យក្រុមហ៊ុនចំការកៅស៊ូ ក្រោមពាក្យស្លាកថាសម្បទានដីសេដ្ឋកិច្ច។

សារ៉ែន បាននិយាយថា "ថ្វីបើពួកយើងគ្មានប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លីក៏ដោយ តាមប្រវត្តិដីនេះ គឺជា ដីរបស់ជនជាតិដើមភាគតិច (ដែលពួកគេបាន និងកំពុងរស់នៅជាច្រើនជំនាន់មកហើយ)"។

ទាំងប្រជាជននៅក្នុងភូមិច្បារអំពៅ និងជនរួមជាតិស្មៀងនៅក្នុងភូមិមានជ័យ មានអារម្មណ៍ថា ទាំងរាជ រដ្ឋាភិបាល ទាំងក្រុមហ៊ុនទាំងឡាយពួកគេបានធ្វើកិច្ចសន្យាគ្មានបានការដែលថា ដើម្បីប្រគល់ដីត្រឡប់មកវិញ ហើយបន្ទាប់ មកពួកគេបានរំលោភនូវកិច្ចសន្យា ដែលពួកគេបានធ្វើនោះ។

សារ៉ែន បាននិយាយថា គាត់បានចាញ់ល្បិចកលក្រុមហ៊ុនដែលបានចេញលិខិតមួយ ដែលចុះហត្ថលេខា ដោយមេក្រុមកម្មករ និងមានការទទួលស្គាល់ដោយមន្ត្រីភូមិ ឃុំ ស្រុកនិងខេត្ត ដែលក្នុងលិខិតនោះសរសេរថា ក្រុមហ៊ុននឹងប្រគល់ដីរបស់គាត់មកវិញ ជាថ្នូរនឹងកិច្ចសន្យាដែលគាត់ឈប់បន្តការប្រឆាំងតវ៉ា តទៅទៀត។

ទោះបីជាយ៉ាងនោះក្តី គាត់បាននិយាយថា ក្រុមហ៊ុនបានបោះបង់ចោលកិច្ចព្រមព្រៀងនេះ នៅពេលដែល អតីតមេកម្មកររបស់ខ្លួនបានឈប់បំរើការងារឱ្យក្រុមហ៊ុនផងដែរ។

គាត់បាននិយាយថា "ក្រោយមកពួកគេនៅតែយកដីគាត់ដដែល"។

មួម ផន គឺជាអ្នកតំណាងដែលមានអាយុ ២៦ ឆ្នាំ មកពីភូមិច្បារអំពៅ បាននិយាយថា នាងមាន អារម្មណ៍ថា ក្រុមហ៊ុនបាននិងកំពុង ព្យាយាមយកដីរបស់នាងផងដែរ បើទោះជាដីនោះមិនមាននៅក្នុងផែនទីផ្តល់ ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនក៏ដោយ។

នាងបាននិយាយថាអាជ្ញាធរខេត្តបានប្រាប់នាងថានាងគឺជាម្ចាស់ត្រឹមត្រូវនៃដីធ្លីរបស់នាងក្នុងកំឡុងកិច្ច ប្រជុំមួយនៅទីរួមខេត្ត។

ទោះបីជាយ៉ាងណាក៏ដោយ នាងបាននិយាយថា បន្ទាប់ពីរូបនាងត្រឡប់មកផ្ទះវិញបាន ១០ថ្ងៃក្រោយមក រូបនាងបានឃើញថា បង្គោលឈើដែលនាងបានដាំធ្វើសញ្ញាសំគាល់នៅលើដីនាង ត្រូវកម្មករក្រុមហ៊ុនបានដកចោល។

ក្នុងកំឡុងពេលចាប់ផ្តើមធ្វើការតវ៉ាប្រឆាំង ផន បាននិយាយថា មានកម្មករម្នាក់ក្នុងចំណោមកម្មកររបស់ ក្រុមហ៊ុនបានបើកត្រាក់ទ័រមួយគ្រឿង និងបានរុញម្តាយនាងនឹងប្រដាប់ជីករបស់វា ហើយបានធ្វើឱ្យរូបគាត់សន្លប់ លែងដឹងខ្លួនផងដែរ។

ថ្វីបើមានហេតុការណ៍យ៉ាងនេះក៏ដោយក៏នាងមានជំនឿថារាជ–រដ្ឋាភិបាលបានដឹងពីបញ្ហារបស់នាង ហើយនឹងជួយនាងក្នុងការ ការពារដីធ្លី ។

នាងបានថ្លែងទៀតថា "ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាជួយខ្ញុំនាងខ្ញុំនឹងមានសង្ឃឹមច្រើន"។

ប៉ុន្តែ សារ៉ែន និងអ្នកភូមិដទៃៗទៀតនៃភូមិជ័យជំនះដែលបានប្រយុទ្ធប្រឆាំងនឹងក្រុមហ៊ុនអភិវឌ្ឍន៍ដែលមានប្រាក់និងអំណាចដ៏ច្រើននោះជឿជាក់ថា ទោះបីជាយ៉ាងណាក៏ដោយ ពួកគេប្រហែលជាគ្មាន ជោគជ័យទេមើលទៅ គឺវាផ្ទុយពីអ្វី ដែលឈ្មោះភូមិត្រូវបានគេហៅនោះ។

# ភាពស្មៀមស្ងាត់ក្លែងក្លាយនៅខេត្តកំពង់ស្ពឺ

## កំពង់ស្ពឺ


សាលាដំបូងខេត្តកំពង់ស្ពឺ

ដីការបស់តុលាការខេត្តកំពង់ស្ពឺ កោះហៅលោក សាន ថូ ឱ្យចូលបង្ហាញខ្លួនដើម្បីផ្តល់ចំលើយ ក្នុងបទប៉ុនប៉ង មនុស្សឃាត ដោយសារតែលោកបាន ដឹកនាំប្រជាជនទៅធ្វើការតវ៉ាប្រឆាំងនឹងការដណ្តើមយកដីរបស់ក្រុមហ៊ុន។

**ករណី : ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ:**

សម្បទាន: ដីសម្បទានសេដ្ឋកិច្ចចំនួនពីរ សម្បទានមួយបានផ្តល់ចំពោះក្រុមហ៊ុនចំការដំណាំអំពៅ ។

កាលបរិច្ឆេទ ទំហំ និងក្រុមហ៊ុន: ដីសម្បទានសេដ្ឋកិច្ចមួយបានផ្តល់នៅក្នុងឆ្នាំ២០១០ ដីចំនួន ១០.០០០ ហិចតាទៅឱ្យក្រុមហ៊ុនស្ករសភ្នំពេញ ដែលជាកម្មសិទ្ធិរបស់លោកជំទាវ គីម ហ៊ាង (Kim Heang) ភរិយាសមាជិកព្រឹទ្ធសភារបស់គណៈបក្សប្រជាជន លី យ៉ុងផាត់ (Ly Yong Phat) ក្រុមហ៊ុនស្ករសកំពង់ស្ពឺ ដែលជាកម្មសិទ្ធិរបស់សមាជិកព្រឹទ្ធសភា លី យ៉ុងផាត់ ។

សហគមន៍ដែលទទួលរងនូវផលប៉ះពាល់: មានភូមិចំនួន ១០ នៅក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើង:

– នៅថ្ងៃទី ១៨ ខែមិនា ឆ្នាំ២០១០: មានការប្រឆាំងតវ៉ាដ៏ធំមួយ (បន្ថែមទៅនឹងការតវ៉ាជាច្រើនទៀត) ដែល ក្នុងនោះសំណង់អាគារឈើរបស់ក្រុមហ៊ុនត្រូវបានភ្លើងឆេះ ។ ក្រុមហ៊ុនបានប្តឹងអ្នកតំណាងក្នុងភូមិចំនួន ៤រូប ពី បទញុះញង់ឱ្យមានអំពើហឹង្សា និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។

– នៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ២០១០: មានអ្នកភូមិចំនួន ៦០០នាក់បានធ្វើ បាតុកម្មរយៈពេលបីថ្ងៃ ដោយឡោមព័ទ្ធជុំវិញតុលាការខេត្តកំពង់ស្ពឺ និង បិទផ្លូវជាតិលេខ ៤ ដើម្បីទាមទារឱ្យមានការដោះលែងអ្នកភូមិ ដែលជាប់ឃុំឃាំង ចំនួនពីររូប (គឺលោក យូ ថូ និងលោក ឃីម វុទ្ធី) ។



– អាជ្ញាធរបានប្រគល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីឱ្យគ្រួសារមួយចំនួននៅក្នុងភូមិ ប៉ុន្តែក្រុមហ៊ុនមិនអនុញ្ញាតិឱ្យ ពួកគេធ្វើការដាំដុះលើដីធ្លីរបស់ពួកគេឡើយ។

ក្នុងខណៈដែលព្រះសូរិយារៀបលិចបាត់ទៅហើយនោះ មានរថយន្តធំៗមួយខ្សែ ដែលដឹកទៅដោយ គ្រឿងចក្របានបន្លឺសូរ ទ្រហឹងតាមបណ្តោយផ្លូវដែលមានធូលីហុចយ៉ាងសំពោងនៅក្នុងឃុំអមឡាំង ខេត្តកំពង់ស្ពឺ ដោយបន្សល់នូវធូលីដីដែលធ្វើឱ្យស្ទើរតែមើលមិនឃើញផ្ទះប្រជាជនទាំងឡាយ និងផ្លូវ។

អ្នកដំណើរទាំងឡាយបានបញ្ឈប់នូវយានជំនិះរបស់ខ្លួនសិន ហើយអ្នកភូមិនានាបានប្រញាប់ប្រញាល់ គ្របមុខរបស់ខ្លួនជាមួយនឹងក្រមា បង់ក ឬអ្វីៗដែលគេអាចរកបាន ដើម្បីការពារមិនឱ្យធូលីចូលភ្នែកនិងស្ទួត។ ពីរបីនាទីក្រោយមក បន្ទាប់ពីរថយន្តទាំងឡាយបានឆ្លងកាត់ទៅ ទើបគេអាចមើលឃើញផ្លូវ និង ភូមិនានា ឡើងវិញហើយអ្វីៗទាំង អស់ក៏បានត្រឡប់ទៅរកសភាពធម្មតាវិញផងដែរ ។

លើកលែងតែខ្យល់ជំនោរចេញដែលបក់ស្លឹកឈើទាំងឡាយឱ្យទង្គិចគ្នាទៅវិញទៅមកគ្មានឈប់ឈរ ភូមិដ្ឋានរួមទាំងអ្នក ភូមិមានសភាពស្ងប់ស្ងាត់ ប៉ុន្តែសេចក្តីស្ងប់នេះបានបិទបាំងនូវរឿងសោកសៅដែលថា រថយន្ត ដែលបានឆ្លងកាត់នោះតំណាងឱ្យរឿងរ៉ាវ ជម្លោះដីធ្លីរវាងអ្នកភូមិ និងក្រុមហ៊ុនដំណាំចំការអំពៅ ដែលមាន ម្ចាស់ជាមហាសេដ្ឋីដ៏មានអំណាចម្នាក់ ហើយក្លាយជាសមាជិកព្រឹទ្ធសភា។

> វាមានតែ ភាពក្រេវក្រោធ ភាពស្អប់ខ្ពើម ភាពអយុត្តិធម៌ ការខកចិត្ត និងភាពភ័យខ្លាចដែលអាចរៀបរាប់នូវការរំជួលចិត្ត របស់ពួកគេបាន

ចំណែកឯនៅក្នុងចិត្តគំនិតរបស់អ្នកភូមិជាច្រើននៅទីនោះគឺមិនមាន ភាពស្ងប់ស្ងាត់នោះទេ។ វាមានតែ ភាពក្រេវក្រោធ ភាពស្អប់ខ្ពើម ភាពអយុត្តិធម៌ ការខកចិត្ត និងភាពភ័យខ្លាចដែលអាចរៀបរាប់នូវការរំជួលចិត្ត របស់ពួកគេបាន ។

ដោយមានការហូរចូលនៅគ្រឿងចក្រទៅក្នុងស្រុក របស់ខ្លួន ធ្វើឱ្យអ្នកភូមិទាំងឡាយមានអារម្មណ៍ថា ក្រុមហ៊ុន កំពុងតែធ្វើសង្គ្រាមអភិវឌ្ឍន៍ក្នុងទ្រង់ទ្រាយធំមួយ ។

ដោយបានជ្រើសរើសស្ថិតនៅក្នុងសភាពស្ងៀមស្ងាត់ ធ្វើឱ្យអ្នកភូមិស្ថិតនៅក្នុងសភាពមិនប្រាកដប្រជា ឡើយ ។

ប៉ុន្តែវាមានមូលហេតុដ៏ល្អមួយដែលស្ថិតនៅពីក្រោយនៃភាពប្រកាន់នូវចរិកដ៏ស្ងៀមស្ងាត់នេះ ។

ពីមុនមកនៅពេលដែលអ្នកភូមិទាំងឡាយបានព្យាយាមបញ្ឈប់ម៉ាស៊ីនមិនឱ្យឈូសឆាយដីធ្លីរបស់ខ្លួន ក្នុងចំណោមពួកគេ មានមនុស្សចំនួន ៦ នាក់ត្រូវបានតុលាការខេត្តកោះហៅ និងចោទប្រកាន់ពីបទ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្រុមហ៊ុន ប៉ុន្តែអ្នកទាំង ៦ នាក់នោះ បានបដិសេធនូវការចោទប្រកាន់នេះ ។

អ្នកស្រី ចាយ កញ្ញា ជាអ្នកភូមិដែលមានអាយុ ៤៩ ឆ្នាំ ដែលមកពីភូមិអង្កុញ ស្រុកថ្ពង់ បាននិយាយថា គាត់ត្រូវបានគេរិះគន់យ៉ាងខ្លាំងអំពីការមិនចេះរៀបចំឥរិយាបទនៅក្នុងតុលាការ ប៉ុន្តែគាត់ បាននិយាយថា ខ្លួនគាត់មិនបានយល់ដឹងអំពីនីតិវិធីច្បាប់ទាំងនេះទេ ។

លោកស្រី កញ្ញា បាននិយាយថា ខ្លួនខ្ញុំមិនបានយល់អំពីអ្វីដែលពួកគេចង់ឱ្យរូបខ្ញុំនិយាយនោះទេ"។ រូបគាត់ ផ្ទាល់ ក៏ត្រូវបានគេចោទប្រកាន់ ពីបទបានជាប់ទាក់ទងនឹងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្រុមហ៊ុនដែរ ថ្វីបើរូបគាត់ បានកំពុងអង្គុយក្រោមដើមឈើមួយសោះ នៅពេលដែលមានឧប្បត្តិហេតុបានកើតឡើងក៏ដោយ ។

នៅពេលនេះគាត់បាននិយាយថា អ្នកភូមិជាច្រើនមានការភ័យខ្លាចយ៉ាងខ្លាំងក្នុងការតវ៉ាជាមួយក្រុមហ៊ុន នេះ ។

គាត់បាននិយាយទៀតថា "សព្វថ្ងៃនេះពួកគេកំពុងឈូសឆាយដីធ្លីរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនហ៊ានទៅទីនោះទេ បើមិនដូច្នោះទេ ពួកគេនឹងចោទប្រកាន់រូបខ្ញុំ (ពីបទប្រឆាំងនឹងក្រុមហ៊ុន)។ រូបខ្ញុំមិនចង់ឱ្យគេចាប់ខ្លួនខ្ញុំ ទេ (ពីព្រោះ)កូនៗរបស់ខ្ញុំ នៅក្មេងណាស់"។

អ្នកស្រី វង្ស ធីតា មានអាយុ ២១ឆ្នាំ និងជាម្តាយដែលមានកូន ២នាក់ បាននិយាយរៀបរាប់ថា នាងត្រូវបានតុលាការកោះហៅ នៅពេលដែលកូននាងទើបតែមានអាយុ ៦ ខែម្ល៉េះ ។

នាងបាននិយាយថា "ពួកគេបានសួរនាងខ្ញុំថា តើអ្នកឯងបានធ្វើអ្វីខ្លះ?"។

នាងបាននិយាយថា" ខ្ញុំឆ្លើយថា ខ្ញុំមិនបានធ្វើអ្វីបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្រុមហ៊ុនទេ ។ ខ្ញុំរវល់តែលក់ទឹកត្នោត"។

អ្នកស្រី ធីតា បាននិយាយថា គ្រួសារនាងបានបាត់បង់ដីចំនួន ២ ហិចតា ដោយសារក្រុមហ៊ុន ។

នាងបានថ្លែងថា "ឪពុកម្តាយនាងបានធ្វើការដាំដុះលើដីនោះចាប់តាំងពីមុនពេលដែលរូបនាងបានកើតមកម្ល៉េះ"។

ក្រោមការហ៊ុមព័ទ្ធទៅដោយគ្រឿងចក្រ កងកំលាំងដ៏ច្រើនលើសលប់ និងគួរឱ្យភ័យខ្លាច ព្រមទាំង ខ្លាចក្រុមហ៊ុនប្តឹងផ្តល់ចំពោះពួកគេផងនោះ អ្នកភូមិជាច្រើនមានអារម្មណ៍ថា ការតស៊ូដើម្បីដីធ្លីរបស់ ពួកគេគឺស្ថិតនៅក្នុងភាពមិនប្រាកដប្រជាឡើយ ។

លោកស្រី កញ្ញា បានថ្លែងរៀបរាប់ថា "ខ្ញុំគ្មានសង្ឃឹមទេដែលថា ពួកគេនឹងប្រគល់ដីមកឱ្យខ្ញុំវិញនោះ"។

លោក សាន្ត ផូ គឺជាគ្រូបង្រៀនម្នាក់ មានអាយុ ៤0 ឆ្នាំ ដែលតុលាការបានកោះហៅមកសាកសួរផងដែរ បានរៀបរាប់ថា គាត់កំពុងតែបង្រៀនសិស្សនៅឯសាលារៀន នៅពេលដែលឧប្បត្តិហេតុបានកើតឡើង ហើយបន្ទាប់មក ខ្លួនគាត់ក៏បានជិះម៉ូតូទៅមើល។

ដោយហេតុតែមានការភយ័ខ្លាចអំពីការចោទប្រកាន់ស្រដៀងគ្នានេះ គាត់បាននិយាយថា អ្នកភូមិ មិន ហ៊ានធ្វើអ្វីទាំងអស់ ហើយបានប្រកាន់យកនូវវិធីរង់ចាំមើលតែប៉ុណ្ណោះ។

# យន្តការផ្សេងៗក្នុងការដោះស្រាយជម្លោះ

ជាទ្រឹស្តីអ្នកទាំងឡាយនោះដែលជាប់ទាក់ទងទៅនឹងជម្លោះដីធ្លី ឬវិវាទផ្សេងៗ ពួកគេមានជម្រើសជាច្រើន ដើម្បីដោះ–ស្រាយនូវជម្លោះដែលអាស្រ័យទៅលើថា តើដីដែលមាន បញ្ហានេះត្រូវបានគេធ្វើការចុះបញ្ជី ឬក៏មិនទាន់ធ្វើការចុះបញ្ជី នៅឡើយទេ? ជារើយៗ រឿងនេះ បង្ករជាមូលហេតុមួយដែលធ្វើឱ្យមានការយល់ច្រឡំ ចំពោះអ្នកប្តឹងតវ៉ាទាំងឡាយ ប៉ុន្តែជាការពិតណាស់ ចំពោះជម្លោះ នានាទៅលើដីធ្លីដែលមិនទាន បានចុះបញ្ជី ពាក្យបណ្តឹងទាំងឡាយ ត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដី ហើយចំពោះ ជម្លោះទៅលើដីធ្លីដែលបានធ្វើការចុះបញ្ជីរួចហើយ ពាក្យ បណ្តឹងត្រូវដាក់ទៅតុលាការ។[៤៨] អាជ្ញាធរជាតិ ទទួលបន្ទុកដោះស្រាយវិវាទដីធ្លីក៏ធ្វើការផងដែរ ដើម្បីដោះស្រាយវិវាទ ដីធ្លី ប៉ុន្តែអំណាច យុត្តាធិការ និងភស្តុតាង ជាក់ស្តែងនៃការ បំពេញការងារ របស់គណៈកម្មការចំពោះដំណោះស្រាយជម្លោះនានា គឺមិនមានភាពច្បាស់សាល់ទេ ។

### គណៈកម្មការសុរិយោដី

រាល់ជម្លោះណាមួយទាក់ទងទៅនឹងដីធ្លី ដែលមិនទាន់បានធ្វើការចុះបញ្ជីនៅឡើយ ឧទាហរណ៍ដូចជា ដីដែលបានកាន់កាប់ ឬដីរបស់សហគមន៍ជនជាតិដើមភាគតិច គួរត្រូវបានដាក់ជូនទៅគណៈកម្មការសុរិយោដី។[៤៩] សមាសភាព និងភារៈកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសុរិយោដី មានកំណត់នៅក្នុងអនុក្រិត្យ។[៥០] គណៈកម្មការសុរិយោដី មានបីថ្នាក់ គឺ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ឬខ័ណ្ឌ គណៈកម្មការ សុរិយោដីថ្នាក់ខេត្ត ឬក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ជាដំបូងពាក្យបណ្តឹងទាំងឡាយត្រូវដាក់ជូនទៅ គណៈកម្មការ សុរិយោដីថ្មីថ្នាក់ស្រុក ឬខ័ណ្ឌ ដែលមានអំណាចត្រឹមតែ ធ្វើការសម្រុះ–សម្រួល តែប៉ុណ្ណោះ។[៥១] ប្រសិន បើគ្មានដំណោះស្រាយណាមួយទៅនឹង ជម្លោះនោះទេ ពាក្យបណ្តឹងគួរតែបញ្ជូនទៅគណៈកម្មការ សុរិយោដីថ្នាក់ខេត្ត ឬក្រុង ដែលជាថ្មីម្តងទៀតត្រូវបានគេធ្វើការផ្សះផ្សាតែប៉ុណ្ណោះ។[៥២] ក្នុងករណីដែលធ្វើការផ្សះ ផ្សាមិនបានទទួលជោគជ័យទេនោះ រឿងក្តីនេះ គួរត្រូវបាន គេ បញ្ជូនទេ ៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលជាអ្នក នឹងត្រូវ ធ្វើការកាត់សេចក្តីរឿងជម្លោះ។[៥៣] នៅពេលដែល ទទួលបានសេចក្តីសំរេចរបស់គណៈកម្មាការសុរិយោដីថ្នាក់ ជាតិហើយ អាជ្ញាធរសុរិយោដីគួរធ្វើការចុះបញ្ជីដីឱ្យស្រប ទៅតាមនោះផងដែរ ។ ប្រសិនបើភាគី–ណាមួយមិនពេញ ចិត្តចំពោះ សេចក្តីសំរេចរបស់គណៈកម្មការថ្នាក់ជាតិ ដូច្នោះ ភាគីនោះអាចប្តឹងទៅតុលាការដើម្បីធ្វើការវិនិច្ឆ័យឡើងវិញ។[៥៤]

ក្នុងការអនុវត្តជាក់ស្តែង គេអាចមើលឃើញយ៉ាងច្បាស់ថា គណៈកម្មការសុរិយោដីជានិច្ចកាលមិនគោរពទៅតាមនីតិវិធី សមស្របដែលមានចែងនៅក្នុងច្បាប់នោះទេ។ សហគ–មន៍ មួយចំនួនដែលបានដាក់ពាក្យសុំឱ្យមានដំណោះស្រាយ ពាក្យបណ្តឹង របស់ពួកគេត្រូវបានបញ្ជូនទៅតុលាការ ក្រុងដោយមិន–សមស្រប ឬដោយសារបញ្ជីសំនុំរឿងធ្វើមិន ហើយ ត្រូវបានគេមើលឃើញថាពាក្យបណ្តឹងរបស់ពួកគេ ត្រូវបញ្ជូនត្រឡប់មកគណៈកម្មការសុរិយោដីថ្នាក់ក្រោមវិញ។ ប្រភពមួយដែលធ្វើការជា–មួយរដ្ឋាភិបាលបាននិយាយថា នៅក្នុងឆ្នាំ២០០៩ មានពាក្យបណ្តឹង ជិត ៥.០០០ ដែលបានប្តឹងទៅគណៈកម្មការសុរិយោដីចាប់តាំងពីពេលដែលគណៈកម្មការ នេះត្រូវបានគេបង្កើតឡើងមក។ ពាក្យបណ្តឹងចំនួន ១.៨០០ កំពុងតែរងចាំនៅឡើយ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនមានការព្រួយបារម្ភអំពីភាពអស់មត្ថភាព របស់គណៈកម្មការសុរិយោដីដែលគេមើល ឃើញយ៉ាងច្បាស់ នៅក្នុងការជម្លោះ ដីធ្លីដែលមានការពាក់ព័ន្ធទៅនឹងមន្ត្រីជាន់ខ្ពស់។[៥៥] ជម្លោះជាច្រើនដែលត្រូវបានគេធ្វើការដោះស្រាយគឺ គ្រាន់តែជាជម្លោះទាក់ទងទៅនឹង ព្រំប្រទល់រវាងអ្នកជិតខាងតែប៉ុណ្ណោះ។ វាពិសូវមាន ដំណោះស្រាយ ដែលជម្លោះទាំងឡាយ ទាក់ទង ទៅនឹង បុគ្គលម្នាក់ជាមួយនឹង សហគមន៍ នោះទេ។ នៅពេលបាន ប្រឈម មុខទៅនឹងកង្វះវិធាការ របស់គណៈកម្មការសុរិយោដី ជាញឹកញាប់ សហគមន៍នានាបាន ប្តឹង ទៅតុលាការ ហើយតុលាការគ្រាន់តែនិយាយថា ជម្លោះនោះមិនស្ថិតនៅក្នុង យុត្តាធិការ របស់ខ្លួន និងបញ្ជូនពាក្យបណ្តឹងត្រឡប់ទៅ គណៈកម្មការសុរិយោដីវិញ ។

---

[៤៨] *សូមមើលសេចក្តីប្រកាសរួមរបស់ក្រសួងយុត្តិធម៌ និងក្រសួងដែនដីនគររូបនីយកម្មស្តីពីកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីទាក់ទងនឹងជម្លោះដីធ្លីឆ្នាំ២០០៣ ។*
[៤៩] *ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រាទី៤៧ ។*
[៥០] *អនុក្រិត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រឹត្តិទៅរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០២ ។*
[៥១] *អនុក្រិត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រិត្តិទៅរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០២ មាត្រា៦ ។*
[៥២] *អនុក្រិត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រិត្តិទៅរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០២ មាត្រា១៥ ។*
[៥៣] *អនុក្រិត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រិត្តិទៅរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០២ មាត្រា១៩ ។*
[៥៤] *អនុក្រិត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រិត្តិទៅរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០២ មាត្រា២៣ ។*
[៥៥] *ឯកសារបញ្ជាក់ពីគោលជំហររបស់អង្គការក្រៅរដ្ឋាភិបាលឆ្នាំ២០០៧–២០០៨ ។*

ដូច្នោះសហគមន៍ទាំងឡាយមានអារម្មថា វាគ្មាន ជម្រើសណាដទៃទៀតនោះទេ ក្រៅពីយកពាក្យបណ្តឹង របស់ពួកគេទៅកាន់គេហដ្ឋានរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ជាញឹកញាប់ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី តែងតែទទួលពាក្យបណ្តឹងទាំងនេះ ប៉ុន្តែវាមិនប្រាកដថា តើពាក្យបណ្តឹងទាំងនេះធ្លាប់ត្រូវគេបញ្ជូនទៅកាន់ខុទ្ទកាល័យរបស់គាត់ដែរឬទេ? ទីប្រឹក្សាទាំងឡាយពុំសូវត្រួតពិនិត្យតាមដាននូវជម្លោះដីធ្លីទាំងនេះនោះណាស់ ។

### តុលាការ

ដូចដែលបានរៀបរាប់ដូចខាងលើមកហើយថានៅពេលដែលមានការមិនពេញចិត្ត ទៅនឹងសេចក្តីសម្រេច របស់គណៈកម្មការសុរិយោដី ភាគីមួយអាចប្តឹងទៅតុលាការបាន។[៥៦] នៅ ក្នុងករណីនេះតុលាការគួរពិនិត្យពាក្យបណ្តឹងហើយវាយ តម្លៃថា តើវាត្រឹមត្រូវតាមនីតិវិធីឬទេ? តើមានជម្លោះខាង ផលប្រយោ–ជន៍ ឬក៏តើគណៈកម្មការសុរិយោដីប្រព្រឹត្តិហួសពីអំណាចរបស់ ខ្លួនឬទេ? ប្រសិនបើ មានបញ្ហាដូច្នេះមែន គណៈកម្មការសុរិយោដីត្រូវចាត់ វិធានការស្របទៅតាមការណែនាំរបស់តុលការ។[៥៧]

រាល់ជម្លោះទាំងឡាយណាដែលទាក់ទងទៅនឹងដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិរួចហើយ គួរត្រូវប្តឹងទៅតុលាការ ក៏ដូចជាប្រសិនបើមានជម្លោះដែលទាក់ទងទៅនឹង "ជម្លោះកិច្ចសន្យាអំពី ដីធ្លីដែលមិនទាន់បានចុះបញ្ជី ដូចជាជម្លោះទទួលមរតក កិច្ចសន្យាលក់ ឬទិញ កិច្ចសន្យាជួល និងបញ្ចាំជាដើម"។[៥៨]

### អាជ្ញាធរជាតិទទួលបន្ទុកដំណោះស្រាយជម្លោះដីធ្លី

អាជ្ញាធរជាតិទទួលបន្ទុកដំណោះស្រាយជម្លោះដីធ្លី ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ដោយព្រះរាជក្រឹត្យ។ វាមានយុត្តាធិការ ទៅលើរឿងក្តីទាំងឡាយដែល "ហួសពីយុត្តាធិការ" របស់គណៈកម្មការសុរិយោដី[៥៩] ប៉ុន្តែទោះបីជា យ៉ាង ណាក្តី ដូចដែលបានបង្ហាញខាងលើមកហើយ វាគ្មាន ករណីជម្លោះដែលហួសពីយុត្តាធិការរបស់គណៈកម្មការ សុរិយោដី ឬរបស់តុលាការនោះទេ ។

អាជ្ញាធរនេះមិនបានបង្កើតនូវបទប្បញ្ញត្តិ ឬនីតិវិធី នោះទេ និងមានសមាសភាពសុទ្ធសឹងជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ រួមទាំងឥសរៈជននគរបាល និងយោធាជាន់ខ្ពស់ ដែលមាន សាវតានិងឋានន្តរសក្តិ ធ្វើឱ្យពួកគេមិនសមស្រប ទៅនឹងតួនាទី ដ៏មានសារៈសំខាន់ និងគួរឱ្យចាប់អារម្មណ៍ ជាពិសេស ការពិចារណាទៅលើករណីចាប់យកដីធ្លីរបស់មន្ត្រី ជាន់ខ្ពស់ជាច្រើន ដែលទាក់ទងទៅនឹងឥសរៈជនយោធា។[៦០]

អង្គការលីកាដូ (LICADHO) វាយតម្លៃថា មានប្រជាជនច្រើនជាង ៣.៥០០ គ្រួសារ បានជាប់ទាក់ទិនទៅនឹង ជម្លោះដីធ្លីដែលពាក់ព័ន្ធទៅនឹងយោធា ឬនគរបាលក្នុងឆ្នាំ ២០០៨។[៦១]

អាជ្ញាធរជាតិទទួលបន្ទុកដំណោះស្រាយជម្លោះដីធ្លី គឺជាស្ថាប័នមិនសូវមានសកម្មភាព ហើយ សម្តេចនាយក រដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់បញ្ហានេះ ដោយខ្លួនឯងផ្ទាល់ នៅក្នុងដំណើរការរៀបចំបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំ ២០០៨ ។

---

[៥៦] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៤៧ និង អនុក្រឹត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រឹត្តិទៅរបស់គណៈកម្មការសុរិយោដីឆ្នាំ២០០២ មាត្រា២៣ ។

[៥៧] អនុក្រឹត្យលេខ៤៧ ស្តីពីការបង្កើតនិងការប្រព្រឹត្តិទៅរបស់គណៈ កម្មការសុរិយោដីឆ្នាំ២០០២ មាត្រា២៣ ។

[៥៨] សេចក្តីប្រកាសរួមរបស់ក្រសួងយុត្តិធម៌ និងក្រសួងដែនដីនគរ រូបនីយកម្មស្តីពីកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការ សុរិយោដី ទាក់ទងនឹងជម្លោះដីធ្លីឆ្នាំ២០០៣ មាត្រា៤។

[៥៩] ព្រះរាជក្រឹត្យស្តីអំពីអាជ្ញាធរជាតិទទួលបន្ទុកដំណោះស្រាយជម្លោះ ដីធ្លីឆ្នាំ២០០៦ មាត្រា៣។

[៦០] ក្នុងចំណោមសមាជិក ២០ នាក់ មាន ៦ នាក់គឺជាតំណាងពីស្ថានប័ន យោធា ឬនគរបាល ព្រះរាជក្រឹត្យស្តីអំពីអាជ្ញាធរជាតិទទួលបន្ទុក ដំណោះស្រាយជម្លោះដីធ្លីឆ្នាំ២០០៦ មាត្រា១ ។ សូមមើលផងដែរ សារព័ត៌មាន ឌឹ ខែមបូឌា ដេលី "ក្រុមដោះស្រាយជម្លោះដីធ្លីប្រកប ដោយវាទប្បដិវាទ មានមេដឹកនាំថ្មី"។

[៦១] សារព័ត៌មានភ្នំពេញប៉ុស្តិ៍ "ប្រជាជនចំនួន ៣.៥០០ គ្រួសារបានរងផល ប៉ះពាល់នៅឆ្នាំនេះ ដោយការចាប់យកដីធ្លីដែលទាក់ទងទៅនឹង យោធា" ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៩។

# ពាក្យបណ្ដឹងសហគមន៍

មានពាក្យបណ្ដឹងទាក់ទងទៅនឹងជម្លោះដីធ្លីជាបន្តបន្ទាប់ត្រូវបាន គេដាក់ជូនទៅអាជ្ញាធរខេត្ត និងអាជ្ញាធររដ្ឋាភិបាលថ្នាក់ ជាតិនៅ ក្នុងខែមិថុនា និងខែតុលា ឆ្នាំ២០០៨ ហើយនៅ លើកទី៣ ដែលមានពាក្យ បណ្ដឹង ចំនួន ៣២ មកពី ខេត្តចំនួន ១៩ ត្រូវបានដាក់ជូននៅក្នុងខែសីហា ឆ្នាំ២០០៩។ ថ្វីបើពាក្យបណ្ដឹងទាំងនេះមិនបានឆ្លុះបញ្ចាំងឱ្យឃើញនូវ ចំនួនសរុបនៃ ប្រជាជនដែលបានទទួលរងផលប៉ះពាល់ដោយសារដីសម្បទានសេដ្ឋកិច្ច ដោយសារការ ជន្លៀសដោយបង្ខំ និងដោយសារការចាប់យកដីធ្លីនៅក្នុងប្រទេសកម្ពុជា ក៏ពាក្យបណ្ដឹងទាំងនោះបង្ហាញឱ្យឃើញ នូវកំរិតព្រួយ បារម្ភដែលចេះតែកើនឡើងនៅក្នុងសហគមន៍នានាដែលដី កសិកម្មត្រូវ បានគេជួល នៅក្នុងករណីជាច្រើនដោយអ្នក ស្រុកមិនបានដឹង តាមរយៈដីសម្បទានសេដ្ឋកិច្ចដែលនឹត្រូវបានគេធ្វើការផ្លាស់ប្ដូរទៅជាចំការដំណាំ ផ្សេងៗ ការធ្វើអាជីវកម្ម រ៉ែនានា និងរម្មណីដ្ឋានទេសចរណ៍ជាដើម ។

របាយការណ៍នៃអង្គការឯករាជ្យ ស្ដីអំពីដីសម្បទានសេដ្ឋកិច្ច ទាំងឡាយ គឺមានភាពទូលំទូលាយ ហើយស្ទើរ តែមានភាពអវិជ្ជមាន ទាំងស្រុង។ ធនាគារពិភពលោក កម្មវិធី អភិវឌ្ឍន៍ របស់អង្គការ សហប្រជាជាតិ និងការិយាល័យ ឧត្ដមស្នងការ របស់អង្គការសហប្រជាជាតិ ទទួល បន្ទុកសិទ្ធិមនុស្ស បានលើក ឡើងនូវការព្រួយបារម្ភអំពីកិត្យានុកូលភាព នៃដីសម្បទានសេដ្ឋកិច្ចជាច្រើន ហើយបានចោទសួរ នូវតម្លៃរបស់វាជាលិខិតតូបករណ៍សម្រាប់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច និងបាន គូសបញ្ជាក់ អំពីការជាប់ ទាក់ទិនទៅនឹង ការរំលោភលើ សិទ្ធិមនុស្សផងដែរ ។

ពាក្យបណ្ដឹងរបស់សហគមន៍ទាំងនេះត្រូវបានប្ដឹង ដោយផ្ទាល់ដោយបុគ្គលទាំងឡាយ និងសហគមន៍នានាដែលបានទទួលរង នូវការប៉ះពាល់។ ពួកគេសំដែងឱ្យឃើញការយល់ដឹង ដែលចេះតែកើនឡើង នៅក្នុងចំណោមប្រជាជនកម្ពុជានៅតាមជនបទ អំពីបញ្ហាផ្លូវច្បាប់ទាំងឡាយ ជុំវិញដី សម្បទានសេដ្ឋកិច្ច ព្រមទាំងសិទ្ធិរបស់ពួកគេ ស្រប ទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ពាក្យបណ្ដឹងទាំង ឡាយក៏ឆ្លុះបញ្ចាំងផងដែរពីការ កើនឡើងនូវកំរិតមិនពេញចិត្តក្នុងការប៉ុនប៉ងដោះស្រាយជម្លោះ ផ្សេងៗដែលផ្ដើមចេញពីដីសម្បទានសេដ្ឋកិច្ច និងជម្លោះដីធ្លីដទៃៗ ទៀត នៅឯថ្នាក់មូលដ្ឋាន។ ពាក្យបណ្ដឹងទាំងនោះមានប្រភពមកពី ខេត្តចំនួន ៦ ផ្សេងៗគ្នា ប៉ុន្តែមានប្រធានបទប្រហាក់ប្រហែលគ្នាមួយគឺថា សហគមន៍ ដែលក្រីក្រគ្មានអំណាចត្រូវបានគេកំពុងជំរុញឱ្យធ្លាក់ ទៅក្នុងភាពក្រីក្រថែមទៀត ដោយសារដីសម្បទានសេដ្ឋកិច្ច និងដោយសារការចោទ ប្រកាន់អំពីការចាប់យកដីធ្លី ហើយការព្យាយាមរបស់ពួកគេ ដើម្បីស្វែងរកដំណោះ ស្រាយនានាត្រូវបានជួបប្រទះការបំ ផិតបំភ័យ ការបង្ខិតបង្ខំ និងការប្ដឹងផ្ដល់ ហើយជូន កាលជួបប្រទះទៅនឹង អំពីហឹង្សារទៀតផង។ អ្វីៗ ដែលមាននៅខាងក្រោមនេះ គឺជាការពិពណ៌នាដោយ សង្ខេបនូវពាក្យ បណ្ដឹងមួយចំនួនក្នុងឆ្នាំ ២០០៨ ។ ពាក្យបណ្ដឹងទាំងស្រុងអាចរកបាន (ជាភាសាខ្មែរ និងអង់គ្លេស) នៅការិយាល័យឧត្តមស្នងការរបស់អង្គការ សហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅទីក្រុងភ្នំពេញ ។

<u>កំណត់សំគាល់:</u> ច្បាប់ភូមិបាលកម្ពុជាបានអនុម័ត្តនៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០១ ។ មានមនុស្សជាច្រើន បានចាត់ទុកវាថាមានការរីកចំរើនជាបណ្ដើរៗ និងនិយាយថា វិបត្តិដីធ្លីនៅកម្ពុជាភាគច្រើនបណ្ដាល មកពីការបរាជ័យមិនបានអនុវត្តន៍ច្បាប់ភូមិបាល ឱ្យបានត្រឹមត្រូវ។ ចំពោះព័ត៌មានបន្ថែមស្ដីអំពីច្បាប់ភូមិបាលកម្ពុជា សូមមើលរបាយការណ៍ស្ដីអំការបាត់បង់ដីធ្លី ទំព័រ 65-70 (Losing Ground, pages 65-70)



ការបណ្តេញចេញដោយបង្ខំ
និងការគំរាមកំហែងនៅកម្ពុជា